# ទស្សនាវដ្ដីសមិទ្ធផលអំពី
# កិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ

ទស្សនាវដ្ដីសមិទ្ធផលអំពីកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ គឺជាកម្រងប្រមូលផ្ដុំលទ្ធផលនូវរាល់កិច្ចការទាំងឡាយដែលអាជ្ញាធរជាតិអប្សរា និងគ្រប់ដៃគូសហប្រតិបត្តិការអន្តរជាតិ បានខិតខំបំពេញតាំងពីថ្ងៃដំបូង ដែលរមណីយដ្ឋានអង្គរបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ជាងនេះទៅទៀត ទស្សនាវដ្ដីនេះបានផ្ដល់ជូនមិត្តអ្នកអាននូវឱកាសស្វែងយល់អំពី តម្លៃលេចធ្លោជាសកលរបស់រមណីយដ្ឋានអង្គរ និងរាល់ការខិតខំប្រឹងប្រែងទាំងឡាយជាប្រវត្តិសាស្ត្ររបស់អាជ្ញាធរជាតិអប្សរាក្នុងក្របខណ្ឌជាតិ និងអន្តរជាតិដើម្បីធានាការការពារនិងអភិវឌ្ឍន៍ ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។

រមណីយដ្ឋានអង្គរត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ ក៏ប៉ុន្តែដោយស្នងចេញពីឆន្ទៈដ៏មោះមុតក្នុងការធានាឲ្យបាននូវការថែរក្សា និងការការពារប្រាង្គប្រាសាទអង្គរដែលជាមរតកដូនតានិងមនុស្សជាតិ និងដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការយូណេស្កូគណៈកម្មាធិការអាយស៊ីស៊ីអង្គរ អាជ្ញាធរជាតិអប្សរានិងដៃគូអន្តរជាតិ បានកំណត់ផែនការការងារយុទ្ធសាស្ត្រជាអាទិភាពជាក់លាក់ ដើម្បីធ្វើការជួសជុលសង្គ្រោះបន្ទាន់នូវប្រាង្គប្រាសាទនានា ដែលប្រឈមនឹងគ្រោះថ្នាក់ខ្លាំងៗ។ ក្នុងរយៈពេល១០ឆ្នាំពេលគឺ នៅក្នុងសម័យប្រជុំពេញអង្គលើកទី២៨នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នាទីក្រុងSuzhou ប្រទេសចិន រមណីយដ្ឋានអង្គរ ត្រូវបានគណៈកម្មាធិការនេះដកចេញពីបញ្ជីប្រឈមនឹងគ្រោះថ្នាក់។

ក្រៅតែពីការផ្ដោតទៅលើកិច្ចការអភិរក្សប្រាង្គប្រាសាទ ទស្សនាវដ្ដីនេះក៏រំលេចនូវការងារគន្លឹះផ្សេងៗទៀត ដូចជាការគ្រប់គ្រងទឹក ការងារស្ដារឡើងវិញប្រព័ន្ធធារាសាស្ត្របុរាណនាសម័យអង្គរ ការរីកចម្រើននៃវិស័យទេសចរណ៍ ការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ការអភិរក្សវត្តអារាមនិងគំនូរនៅតាមជញ្ជាំងវត្ត និងការងារបណ្ដុះបណ្ដាលអ្នកជំនាញជាតិឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

# មាតិកា







| | |
|---|---|
| ព្រះរាជសារ ព្រះបរមរតនកោដ្ឋ | ៤ |
| សារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ៦ |
| សារលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៨ |
| សារស្វាគមន៍ ឯកឧត្តម ស៊ុំ ម៉ាប់ អគ្គនាយកអាជ្ញាធរជាតិអប្សរា | ១០ |
| នទិសកថា | ១២ |
| បទសម្ភាសជាមួយឯកឧត្តមសាស្ត្រាចារ្យ អាហ្សេទីន បេសាអ៊ីច | ១៣ |
| អំពីបេតិកភណ្ឌ | ១៧ |
| បេតិកភណ្ឌពិភពលោក | ១៨ |
| អំពីអាជ្ញាធរជាតិអប្សរា | ២៧ |
| កិច្ចការអភិរក្ស និងជួសជុលនៅប្រាសាទអង្គរវត្ត | ៣៤ |
| គម្រោងជួសជុល ស្ពានហាលទាងលិច នៃប្រាសាទអង្គរវត្ត | ៣៦ |
| ចម្រឹងបង្ហូរនៅប្រាសាទអង្គរវត្ត | ៣៦ |
| ជួសជុលប្រាំងកសិន្ធុ នៃប្រសាទអង្គរវត្ត | ៣៧ |
| ការជួសជុល ប្រាសាទបាយ័ន្ត | ៤០ |
| ការជួសជុល ប្រាសាទភ្នំបាខែង | ៤៤ |
| ប្រាសាទបាពួន | ៤៥ |
| ការងារអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម | ៤៧ |
| ការជួសជុលអភិរក្ស ប្រាសាទចៅសាយទេវតា | ៤៨ |
| គម្រោងជួសជុល ប្រាសាទ ព្រះពិធូរ | ៥០ |
| ការជួសជុលបង្អាន់ដៃនាគប្រាសាទបន្ទាយសម្រែ | ៥១ |
| គម្រោងជួសជុល ប្រាសាទព្រះគោ | ៥៤ |
| ការជួសជុលព្រះវិហារវត្តបូណ៌ | ៥៦ |
| ការជួសជុលព្រះវិហារ អារញ្ញសាគរ | ៥៨ |
| ការជួសជុលព្រះវិហារបាគង | ៥៩ |
| កំណាយនៅភ្នំគូលែន | ៦០ |
| ទូកបុរាណដ៏កម្រដំបូងបំផុត-ចាស់ជាងគេក្នុងតំបន់អង្គរ | ៦២ |
| ឧស្សាហកម្មកុលាលភាជន៍តំបន់អង្គរ | ៦៤ |
| ការប្រទះឃើញព្រះបដិមា កែសផ្យុត្រ ព្រះពុទ្ធស្តេចថ្មី | ៦៦ |
| គម្រោងស្រាវជ្រាវ ភេទសិតសរិទ្ធ | ៦៧ |
| ការប្រគល់វត្ថុបុរាណជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក | ៦៧ |
| ការថែរក្សាជំនឿ សាសនា តាមទំនៀមអ្នកអង្គរ | ៦៩ |
| ពិធីបួងក្រឡាន | ៧០ |
| ពិធីបួងសួងសុំទឹកភ្លៀងអ្នកស្រុកអង្គរនៅប្រាសាទនាគព័ន្ធ | ៧១ |
| សារមន្ទីរក្នុងកិច្ចអភិរក្ស | ៧២ |
| សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ | ៧៤ |
| ពិព័រណ៌ព្រះពុទ្ធបដិមា (ប្រាសាទបន្ទាយក្តី) | ៧៥ |
| ពិព័រណ៌ពលកប់សព (កោះតាមាស និងព្រៃក្មេង) | ៧៥ |
| ពិព័រណ៌ភាជន៍ដាក់ធាតុ (ប្រាសាទ គោកប៉ាទ្រី) | ៧៥ |
| សារមន្ទីរសេព្វទស្សន៍អង្គរ | ៧៦ |
| សារមន្ទីរកុលាលភាជន៍នៅភូមិតានី | ៧៦ |
| សារមន្ទីរភេយនភណ្ឌប្រពៃណីអាស៊ី | ៧៧ |
| ទីលាន Parvis ប្រាសាទបន្ទាយស្រី | ៨០ |
| ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត | ៨២ |
| ទិវាយោគៈអន្តរជាតិ | ៨៥ |
| កីឡារត់ម៉ារ៉ាតុងអន្តរជាតិ | ៨៥ |
| ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានអង្គរ | ៨៨ |
| ទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ | ៩០ |
| ផែនការគ្រប់គ្រងទេសចរណ៍ និងគោលនយោបាយ | ៩០ |
| ការគ្រប់គ្រងភ្ញៀវក្នុងរមណីយដ្ឋានអង្គរ | ៩០ |
| ប្រព័ន្ធធារាសាស្ត្រអង្គរ | ៩២ |
| ការធ្វើឱ្យប្រសើរឡើងវិញនូវប្រព័ន្ធធារាសាស្ត្រសម័យបុរាណ | ៩៤ |
| កសិន្ធុទឹកទីក្រុងអង្គរធំ | ៩៥ |
| ស្រះស្រង់ | ៩៦ |
| កសិន្ធុទឹកប្រាសាទអង្គរវត្ត | ៩៦ |
| បារាយណ៍ខាងជើង | ៩៦ |
| អាងស្តុកទឹកប្រាសាទនាគព័ន្ធ | ៩៧ |
| កសិន្ធុទឹកប្រាសាទព្រះខ័ន | ៩៧ |
| បារាយណ៍ខាងលិច | ៩៩ |
| ការកសាងប្រព័ន្ធធារាសាស្ត្រ | ១០០ |
| ការថែរក្សានិងស្តារឡើងវិញព្រៃឈើនៃរមណីយដ្ឋានអង្គរ | ១០២ |
| សត្វទោចម្ដងនៅក្នុងព្រៃតំបន់រមណីយដ្ឋានអង្គរ | ១០៤ |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ១០៦ |
| វិថីសម្តេចវិបុលបញ្ញា សុខ អាន | ១០៨ |
| ការជួសជុលកំណាត់ផ្លូវធំធំ | ១១១ |
| ភូមិធម្មជាតិរុនតាឯក ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព | ១១២ |
| អ្នកបន្តវេននៅអង្គរ | ១១៦ |
| មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ | ១១៧ |













ព្រះករុណាព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ**

*អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

*ព្រះរាជឱង្ការរបស់ព្រះអង្គក្នុងការអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យជួយស្រោចស្រង់អង្គរ*

*"ខ្ញុំត្រូវធ្វើការអំពាវនាវសុំជំនួយអន្តរជាតិ ដើម្បីជៀសវាងគ្រោះមហន្តរាយ ហើយខ្ញុំសូមសម្តែងកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅក្រៃលែងដល់មហាប្រទេសជាមិត្ត ដែលបានធ្វើការឆ្លើយតបប្រកបដោយសប្បុរសធម៌។ ការជួយស្រោចស្រង់អង្គរមហាប្រទេសជាមិត្តបានប្រគល់អតីតកាលដ៏រុងរឿងជូនប្រជាជាតិខ្មែរវិញ ហើយបានធ្វើឲ្យប្រទេសជាតិខ្មែរមានការទុកចិត្តកាន់តែខ្លាំងទៅលើអនាគតរបស់ខ្លួន ។"*




សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្លែងនៅវិមានពហុកីឡាដ្ឋានជាតិ ថ្ងៃទី១០ កក្កដា ២០១៧ អបអរសាទរ «តំបន់ប្រាសាទសំបូរព្រៃគុក» ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។

- ខ្ញុំសូមអំពាវនាវឲ្យមានការចូលរួមចលនាការពារវប្បធម៌ជាតិទាំងរូបី និងអរូបី។ សូមកុំសម្លាប់មេមាន់ដើម្បីតែការឆ្ងាញ់មួយពេល សូមរក្សាមេមាន់ចិញ្ចឹមយកកូន ឬយកស៊ុត ទើបមានប្រយោជន៍ច្រើន។ ចំណុចនេះ អ្នកទាំងអស់គ្នាត្រូវចូលរួមការពារនូវសម្បត្តិវប្បធម៌របស់យើង ប្រៀបដូចជាប្រាង្គប្រាសាទ និងតំបន់ដែលត្រូវបានចាត់ទុកជាជាតំបន់ការពារទាំងឡាយ ធ្វើយ៉ាងណាកុំឲ្យទេសចរបំពានទៅលើវប្បធម៌ ដែលយើងតែងតែរំឭកដាស់តឿនថា បេតិកភណ្ឌពិភពលោកដូចជា៖ ប្រាសាទអង្គរ ប្រាសាទព្រះវិហារ និងសំបូរព្រៃគុក មិនត្រូវបានបំពានដោយប្រការណាមួយនោះទេ។ យើងត្រូវគោរពនូវលក្ខខណ្ឌទាំងឡាយដែលអង្គការយូណេស្កូកំណត់ឲ្យយើងធ្វើ។ យើងត្រូវធ្វើកិច្ចការទាំងឡាយ ដើម្បីអភិរក្សនូវកេរដំណែលប្រវត្តិសាស្ត្រនេះ បើមិនដូច្នោះអ្វីៗដែលយើងបានដាក់បញ្ចូលទៅក្នុងបេតិកភណ្ឌពិភពលោករួចហើយ អាចបាត់បង់នូវលក្ខណៈសម្បត្តិរបស់វា។ ដូច្នេះត្រូវចងចាំថា យើងទាំងអស់គ្នាចូលរួមការពារបេតិកភណ្ឌវប្បធម៌ទាំងអស់គ្នា នេះសមដូចពាក្យដែលយើងបានដាក់ថា បេតិកភណ្ឌវប្បធម៌ដូនតាដែលត្រូវគោរពការពារ។ -



លោកជំទាវ **ភឿង សកុណា**
រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
និងជាប្រធានអាជ្ញាធរជាតិអប្សរា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានមរតកវប្បធម៌ទាំងរូបី និងអរូបីដ៏សម្បូរបែប ដែលនេះជាតឹកតាងប្រវត្តិសាស្ត្របញ្ជាក់អំពី អតីតកាលដ៏រុងរឿងថ្កុំថ្កើងគួរជាទីស្ញប់ស្ញែងរបស់ខ្មែរ។ បុព្វបុរសខ្មែរបានបន្សល់ទុកនូវមរតកវប្បធម៌ដ៏មានតម្លៃវិសេសវិសាលអស្ចារ្យក្រៃលែង ហើយវប្បធម៌ទាំងនោះបានក្លាយជាព្រលឹង និងអត្តសញ្ញាណជាតិជាប់ក្នុងក្រនីបេះដូងជនជាតិខ្មែរគ្រប់រូបនាពេលបច្ចុប្បន្ន។ ជាពិសេសទៀតនោះ ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសតែមួយគត់ក្នុងពិភពលោក ដែលបានយករូបប្រាសាទបុរាណជាតំណាងដាក់លើទង់ជាតិរបស់ខ្លួន។

អនុលោមតាមគោលនយោបាយឈ្នះៗ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភាដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាសេនាធិការ បានកំណត់គោលនយោបាយអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិជាភារកិច្ចចម្បងដែលត្រូវគុះពារបំពេញឲ្យខាងតែបាន។ ក្នុងន័យនេះ ក្រសួងបានដាក់បញ្ចូលនូវគោលនយោបាយដែលជួយបង្កលក្ខខណ្ឌសមស្របតាមរយៈការលើកទឹកចិត្តដល់គំនិតច្នៃប្រឌិតថ្មីក្នុងវិស័យវប្បធម៌ និងជំរុញសក្តានុពលវប្បធម៌ឲ្យក្លាយជាចលករមួយយ៉ាងសំខាន់ក្នុងការបង្កើនកំណើនសេដ្ឋកិច្ចជាតិ។

អំពីកិច្ចការអភិរក្ស ជួសជុលប្រាង្គប្រាសាទ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ខ្ញុំពិតជាមានមោទនភាពឧត្តុង្គឧត្តមបំផុត ព្រោះអង្គរគឺជារមណីយដ្ឋានមានជីវិត ដែលតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋាននេះត្រូវបានផ្សំដោយសមាសធាតុ៣ សំខាន់ៗគឺ ប្រាង្គប្រាសាទ ធម្មជាតិ និងសហគមន៍មនុស្ស។ ចាប់ពីថ្ងៃដំបូងនៃការចុះបញ្ជីរមណីយដ្ឋានអង្គរជាបេតិកភណ្ឌពិភពលោកមកដល់បច្ចុប្បន្ន គឺមានរយៈពេល២៥ឆ្នាំ ហើយក្នុងរយៈពេលជាងពីទសវត្សនេះ ការងារដែលមានលក្ខណៈជាប្រវត្តិសាស្ត្រជាច្រើនត្រូវបានសម្រេចឡើងដោយកិច្ចសហប្រតិបត្តិការជិតស្និទ្ធ រវាងស្ថាប័នអាជ្ញាធរជាតិអប្សរានិងដៃគូអន្តរជាតិមកពីប្រទេសជាមិត្តដូចជា ប្រទេសបារាំង ប្រទេសជប៉ុន ប្រទេសចិន ប្រទេសឥណ្ឌា។ល។ ក្នុងនាមខ្ញុំជាប្រធានអាជ្ញាធរជាតិអប្សរា ខ្ញុំសូមយកឱកាសនេះថ្លែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អគ្គមគ្គុទ្ទេសក៍ជាតិដ៏ឆ្នៀវឆ្លាដែលបានដឹកនាំនាវាកម្ពុជារួចផុតពីភាពក្រីក្រតោកយ៉ាក និងគំនរផេះផង់នៃសង្គ្រាម។

ដោយមិនបំភ្លេចនឹកដល់គុណូបការៈនៃថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាជំនាន់មុន ខ្ញុំសូមឧទ្ទិសនូវរាល់សមិទ្ធផលទាំងអស់ ជូនដល់អតីតប្រធានអាជ្ញាធរជាតិអប្សរា ឯកឧត្តម **វណ្ណ មូលីវណ្ណ** សម្តេចវិបុលបញ្ញា **សុខ អាន** ជាឥស្សរជនដ៏ឆ្នើមបំផុតផ្នែកបេតិកភណ្ឌ និងអ្នកជំនាញជាតិ-អន្តរជាតិមួយចំនួនដែលបានបូជាកម្លាំងកាយ និងប្រាជ្ញាស្មារតីក្នុងបុព្វហេតុថែរក្សាអង្គរជាអត្តសញ្ញាណជាតិខ្មែរ និងជាសម្បត្តិបេតិកភណ្ឌមនុស្សជាតិ។ មួយវិញទៀត ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរវាយតម្លៃខ្ពស់ដល់គ្រប់មន្ត្រី អ្នកជំនាញជាតិ-អន្តរជាតិ ព្រមទាំងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរាដែលបានចូលរួមក្នុងបេសកកម្មដ៏អស្ចារ្យថែរក្សារមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក និងជាមរតកមនុស្សជាតិ។

សូមឲ្យស្មារតីស្រឡាញ់ ថែរក្សា ការពារ បេតិកភណ្ឌវប្បធម៌ជាតិដែលមានជាប់ក្នុងក្រនីបេះដូងនៃកូនខ្មែរគ្រប់ៗរូប ក្លាយជាការប្រមូលផ្តុំនូវមហាកម្លាំងសាមគ្គីជាតិដ៏ធំ ដើម្បីបង្ហាញអំពីមហិច្ឆតាជាតិ និងការខិតខំប្រឹងប្រែងរួមសំដៅពង្រីកកិត្យានុភាពវប្បធម៌ជាតិ និងលើកកម្ពស់កិត្តិយសកម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈឲ្យកាន់តែល្បីរន្ទឺថែមទៀតក្នុងឆាកអន្តរជាតិ។



**សារស្វាគមន៍របស់**

ឯកឧត្តម **ស៊ុំ ម៉ាប់** អគ្គនាយក
អាជ្ញាធរជាតិអប្សរា

រមណីយដ្ឋានអង្គរត្រូវបានបញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ នាសម័យប្រជុំពេញអង្គគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី១៦ នៅទីក្រុងសាន់តាហ្វេ សហរដ្ឋអាមេរិក ដែលមានផ្ទៃដីទំហំគ្របដណ្តប់ចំនួន ៤០ ១០០ហិកតា ជាមួយប្រាសាទសំខាន់ៗចំនួន៩១។ ដោយសារស្ថានភាពផុយស្រួយ ជាពិសេសកង្វះខាតនៃការថែទាំ ការលួចឈើទន្រ្ទានដោយព្រៃឈើ ការលួចគាស់កកាយយកវត្ថុបុរាណ និងគ្រាប់មីន រមណីយដ្ឋានអង្គរនាពេលនោះត្រូវបានបញ្ចូលជាបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់។ ម្យ៉ាងទៀត នៅពេលនោះសូម្បីតែស្ថាប័នជាតិទទួលបន្ទុកការការពារ និងរៀបចំរមណីយដ្ឋានអង្គរក៏ពុំទាន់បានបង្កើតនៅឡើយដែរ។

បញ្ហាប្រឈមជាច្រើនបានស្ថិតនៅចំពោះមុខនៃកិច្ចការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។ ប៉ុន្តែទោះជាយ៉ាងណា តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងក្របខណ្ឌគណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីកិច្ចការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) សមិទ្ធផលជាប្រវត្តិសាស្ត្រដ៏អស្ចារ្យយ៉ាងច្រើនត្រូវបានរំលេច។ រីឯការប្រឈមទាំងប៉ុន្មានត្រូវបានកាត់បន្ថយបន្តិចម្តងៗជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ អាយស៊ីស៊ី-អង្គរក៏បានផ្តល់ឱកាសដល់ស្ថាបត្យករ វិស្វករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗធ្វើការផ្លាស់ប្តូរយោបល់ព័ត៌មាន វិធីសាស្ត្រស្រាវជ្រាវទៅវិញទៅមក សំដៅជំរុញការងារជួសជុល អភិរក្ស ឬស្រាវជ្រាវ។ ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា រួមជាមួយដៃគូអន្តរជាតិនានា បានខិតខំជួយសង្គ្រោះរមណីយដ្ឋានអង្គរនិងទទួលបានជោគជ័យ ក្នុងការធ្វើឱ្យរមណីយដ្ឋាននេះចាកផុតពីការប្រឈមនឹងគ្រោះថ្នាក់នៅឆ្នាំ២០០៤។

ស្របតាមការរីកចម្រើននៃការងារ និងការវិវត្តជាក់ស្តែងក្នុងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានបោះជំហានទៅរកបរិបទការងារថ្មីមួយទៀត គឺការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងបរិបទថ្មីនេះ ក្រៅពីការផ្តោតជាចម្បងទៅលើកិច្ចការជួសជុល និងអភិរក្សប្រាង្គប្រាសាទ អាជ្ញាធរជាតិអប្សរាបានកំណត់ផែនការយុទ្ធសាស្ត្រអាទិភាពមួយចំនួនតាមរយៈកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីរក្សាគុណភាពរវាងការអភិរក្ស និងអភិវឌ្ឍន៍ដោយផ្តោតជាចម្បងទៅលើការអភិវឌ្ឍវិស័យទេសចរណ៍ ការស្រាវជ្រាវប្រព័ន្ធធារាសាស្ត្របុរាណ និងគ្រប់គ្រងទឹក ការលើកតម្លៃបរិស្ថានព្រៃឈើ និងទេសភាពវប្បធម៌ការស្រាវជ្រាវអំពីបេតិកភណ្ឌអរូបី ព្រមទាំងការលើកកម្ពស់ជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ។

ជាក់ស្តែង អាជ្ញាធរជាតិអប្សរាសម្រេចបានជោគជ័យដែលលេចធ្លោបំផុត គឺការរកឃើញប្រព័ន្ធធារាសាស្ត្រសម័យអង្គរ ដែលមិនត្រឹមតែអាចបញ្ចៀសរមណីយដ្ឋានអង្គរ និងក្រុងសៀមរាបពីទឹកជំនន់ទេ ថែមទាំងបានបង្កើនបរិមាណទឹកដើម្បីជាប្រយោជន៍ដល់ការងារអភិរក្ស និងការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់អ្នកក្រុងសៀមរាបទៀតផង។ អាជ្ញាធរជាតិអប្សរាក៏សម្រេចបាននូវឯកសារធម្មនុញ្ញអង្គរដែលជាគោលការណ៍ស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់ការអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរផងដែរ។

ឯកសារគ្រប់គ្រងបេតិកភណ្ឌអង្គរក៏ជាសមិទ្ធផលដ៏ចម្បងមួយទៀតដែរ ប្រៀបដូចជាផែនការមេយ៉ាងសំខាន់ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសំដៅក្នុងការជំរុញកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ដើម្បីបង្កលក្ខណៈឱ្យកាន់តែប្រសើរដល់ភ្ញៀវទេសចរដែលមកទស្សនារមណីយដ្ឋានអង្គរ ព្រមទាំងផ្តល់អត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋានឱ្យកាន់តែច្រើនថែមទៀត។

ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងទ្រទ្រង់វិស័យទេសចរណ៍ ត្រូវបានកសាងឡើងជាបន្តបន្ទាប់ដូចជា ផ្លូវ ស្ពាន សារមន្ទីរ ទីលានចំណតសួនច្បារ បញ្ជរសំបុត្រចូលទស្សនារមណីយដ្ឋាន។ បច្ចុប្បន្ន រមណីយដ្ឋានអង្គរបានក្លាយជាគោលដៅទេសចរណ៍មួយដ៏ចម្បងក្នុងពិភពលោក ហើយភ្ញៀវទេសចរចម្រុះជាតិសាសន៍ជាច្រើនលាននាក់បានមកទស្សនានៅទីនេះ។ លើសពីនេះទៀត រមណីយដ្ឋានអង្គរបានក្លាយជាគំរូនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ការគ្រប់គ្រងរមណីយដ្ឋានដែលបានផ្តល់ជាគំនិតឱ្យបង្កើតឡើងនូវគម្រោងជួសជុលធំៗជាច្រើនផ្សេងទៀតនៅក្នុងពិភពលោក។

# ឧទ្ទិសកថា



ឯកឧត្តម **វណ្ណ មូលីវណ្ណ**
ប្រធានអគ្គនាយកអាជ្ញាធរជាតិអប្សរា
១៩៩៥ - ២០០១



សម្តេចវិបុលបញ្ញា **សុខ អាន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានអាជ្ញាធរជាតិអប្សរា ២០០៤ - ២០១៣



ឯកឧត្តម **ចេង ហៃ**
អគ្គនាយករងអាជ្ញាធរជាតិអប្សរា
២០០១ - ២០០៧



ឯកឧត្តម **ឃួន ឃុនណាយ**
អគ្គនាយករងអាជ្ញាធរជាតិអប្សរា
២០០៤ - ២០១៣



លោកស្រី **ទេព ចន្ទ**
ប្រធាននាយកដ្ឋាន
១៩៩៥ - ២០១៦

សមិទ្ធផលដែលបង្ហាញក្នុងឯកសារនេះ សុទ្ធសឹងជាស្នាដៃដ៏មានតម្លៃបំផុតរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់ផ្នែកទាំងអស់ ដែលបានពុះពារជម្នះឧបសគ្គផ្សេងៗ ក្នុងបុព្វហេតុអភិរក្សទ្រព្យបេតិកភណ្ឌអង្គររហូតមកដល់បច្ចុប្បន្ន។ យើងខ្ញុំសូមឧទ្ទិសនូវស្នាដៃនៃការរៀបចំសៀវភៅនេះឡើងចំពោះថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាដែលលោកបានលះបង់ជីវិតក្នុងពេលកន្លងទៅ ដូចមានរាយនាមខាងលើ។

បទសម្ភាសជាមួយឯកឧត្តមសាស្ត្រាចារ្យ **អាហ្សេទីន បេសៅអ៊ិច**




ឯកឧត្តមសាស្ត្រាចារ្យ អាហ្សេទីន បេសាអ៊ិច គឺជាបុរាណវិទូ និងជាសមាជិកបណ្ឌិតសភាចារឹកនិងសិលាចារឹកនិងអក្សរផ្ចង់។ អតីតបម្រើការងារនៅអង្គការយូណេស្កូ លោកសាស្ត្រាចារ្យត្រូវបានបោះឆ្នោតតែងតាំងជាប្រធាន (ពីរលើក) និងជាអ្នករាយការណ៍ (បួនលើក) នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ បច្ចុប្បន្នលោកសាស្ត្រាចារ្យជាអ្នកតំណាងផ្ទាល់អគ្គនាយកអង្គការយូណេស្កូ និងជាលេខាធិការអចិន្ត្រៃយ៍វិទ្យាសាស្ត្ររបស់គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ ដើម្បីកិច្ចការអភិរក្ស និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) និងគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការអភិរក្សនិងលើកតម្លៃរមណីយដ្ឋានប្រាសាទព្រះវិហារ (អាយស៊ីស៊ី-ព្រះវិហារ) ។

សម្ភាសដោយលោក ឡុង កុសល ប្រធាននាយកដ្ឋានផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា

*លោក ឡុង កុសល ៖*
*តើឯកឧត្តមសាស្ត្រាចារ្យអាចជម្រាបយើងទាំងអស់គ្នាបានទេថា ហេតុអ្វីបានមានការចាំបាច់ក្នុងការដាក់បញ្ចូលតំបន់អង្គរទៅជាបេតិកភណ្ឌពិភពលោក?*

ឯកឧត្តមសាស្ត្រាចារ្យ អាហ្សេទីន បេសាអ៊ិច ៖
ជាដំបូងខ្ញុំសូមលើកឡើងអំពីអតីតកាលបន្តិច ដើម្បីអាចឲ្យយើងទាំងអស់គ្នា បានយល់ច្បាស់អំពីបរិបទនៃស្ថានភាពអង្គរនៅមុនពេលបញ្ចូលជាបេតិកភណ្ឌពិភពលោក។

ដោយព្រះបញ្ញាញាណរបស់អតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** ដែលពេលនោះព្រះអង្គគង់ជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ព្រះអង្គបានធ្វើសេចក្តីអំពាវនាវជាលក្ខណៈអន្តរជាតិ ឲ្យមានការស្រោចស្រង់អង្គរជាបន្ទាន់ពីការខូចខាត និងការបែកបាក់នៃប្រាង្គប្រាសាទក្នុងតំបន់អង្គរ ដែលជាកេរដំណែលមនុស្សជាតិ និងប្រជាជាតិខ្មែរចំពោះស្ថាបត្យកម្មដ៏អស្ចារ្យនេះ។ ការអំពាវនាវនេះទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីអន្តរជាតិ ជាពិសេសនោះគឺអង្គការយូណេស្កូ ព្រោះថាកម្ពុជានៅពេលនោះកំពុងតែស្ថិតក្នុងស្ថានភាពសង្គ្រាមស៊ីវិល និងការចរចាស្វែងរកសន្តិភាពនៅឡើយ។ អ្វីដែលអាក្រក់ជាងតែខ្លាំងនោះ គឺតំបន់អង្គរត្រូវបានត្រួតត្រាដោយខ្មែរក្រហម សម្បូរទៅដោយគ្រាប់មីន ការលួចគាស់បំផ្លាញកេរ្តិ៍បុរាណ ការដុះលូតលាស់នៃព្រៃឈើដែលមិនអាចគ្រប់គ្រងបាន និងកង្វះខាតនៃការថែរក្សាជួសជុលរាប់សិបឆ្នាំមកហើយ។
ដូច្នេះ ជាក់ស្តែងណាស់ អង្គរត្រូវបានអន្តរជាតិយល់ឃើញថាកំពុងតែស្ថិតក្នុងគ្រោះថ្នាក់យ៉ាងពិតប្រាកដមែន។
ទោះជាមានការយល់ឃើញជាអន្តរជាតិបែបនេះក្តី ក៏នៅមានសំណួរផ្សេងៗទាក់ទិននឹងការចុះបញ្ជីដូចជា បើតំបន់អង្គរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម និងពោរពេញទៅដោយគ្រាប់មីន តើយើងសម្រេចចិត្តចុះបញ្ជីតំបន់អង្គរ ជាបេតិកភណ្ឌពិភពលោកទៅដូចម្តេចកើត? ជាសំណាងល្អដែរ កាលគ្រានោះអតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** បានស្នើទៅកាន់អគ្គនាយកអង្គការយូណេស្កូ ដើម្បីមកធ្វើទស្សនកិច្ចនៅតំបន់អង្គរ ហើយពេលនោះខ្ញុំផ្ទាល់ក្នុងឋានៈជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោកត្រូវបានអគ្គនាយកអង្គការយូណេស្កូស្នើឲ្យមកធ្វើការពិនិត្យ ស្វែងយល់ និងវាយតម្លៃអំពីស្ថានភាពជាក់ស្តែង ដែលតំបន់អង្គរកំពុងតែប្រឈមនាពេលនោះ។ ខ្ញុំនៅចាំថានាពេលនោះក្រុមការងាររបស់ខ្ញុំមានអ្នកនាំផ្លូវយ៉ាងពិសេស ហើយអមដំណើរជាមួយទាហានទៀតផង យើងពុំអាចទៅណាមកណាដោយសេរីនោះទេ ព្រោះគ្រោះថ្នាក់ខ្លាំងណាស់។

កម្ពុជាចំពោះការការពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ។

មួយវិញទៀត ក្នុងន័យជាគោលនយោបាយ កាលខ្ញុំនៅជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ខ្ញុំមានកិត្តិយសបានជួបជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពេលនោះសម្តេចបានបញ្ជាក់ថា កម្ពុជាពិតជាចង់ចុះបញ្ជីតំបន់អង្គរមែនហើយ ប៉ុន្តែសូមជម្រាបទៅគណៈកម្មាធិការបេតិកភណ្ឌពិភពលោកផងថា កម្ពុជានឹងការពារតំបន់បេតិកភណ្ឌមួយនេះ។ ដូចនេះ ខ្ញុំសូមប្រព័ន្ធផ្សព្វផ្សាយជួយផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាបានដឹងពីតួនាទីរបស់ខ្លួន ក្នុងការជួយថែរក្សាបេតិកភណ្ឌរបស់ខ្លួន ព្រោះកម្ពុជាគឺជាអ្នកស្នើសុំចុះបញ្ជី និងសន្យាការពារដោយខ្លួនឯង។ ហេតុនេះហើយ បើទោះជាថ្ងៃក្រោយគ្មានអាយស៊ីស៊ី-អង្គរ ក៏នៅមានអាជ្ញាធរជាតិអប្សរា ហើយស្មារតីការពារ និងអភិរក្សរមណីយដ្ឋានអង្គរនៅតែមានជាឿងរហូតក្នុងដួងចិត្តរបស់ប្រជាជនកម្ពុជាគ្រប់រូប។

**លោក ឡុង កុសល ៖ តើឯកឧត្តមសាស្ត្រាចារ្យមានការពេញចិត្តដូចម្តេចខ្លះចំពោះដំណើរការកិច្ចការពារ និងអភិរក្សក្នុងតំបន់អង្គររយៈកាល២០ឆ្នាំមកនេះ?**

ឯកឧត្តមសាស្ត្រាចារ្យ អាហ្សេឌីន បេសឆាអ៊ូច ៖ ខ្ញុំមានការពេញចិត្តចំពោះប្រព័ន្ធការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពតំបន់អង្គរ ព្រោះជារៀងរាល់៦ខែម្តងយើងមានកិច្ចប្រជុំគ្នារវាងអ្នកបច្ចេកទេសផ្សេងៗ ដើម្បីវិភាគវែកញែករកប្រភពនៃបញ្ហា និងការផ្តល់ដំណោះស្រាយបច្ចេកទេសដើម្បីបន្តការងារទៅមុខទៀត។ កំឡុងពេល៦ខែនេះ មុនពេលកិច្ចប្រជុំម្តងៗ អ្នកបច្ចេកទេសរបស់យើងអាចចុះទៅមើលទីតាំងផ្សេងៗក្នុងតំបន់អង្គរដោយផ្ទាល់ ដើម្បីត្រួតពិនិត្យ ពិភាក្សា និងរាយការណ៍មកគណៈកម្មការអាយស៊ីស៊ី-អង្គរ ដើម្បីទទួលបានអនុសាសន៍យកទៅអនុវត្តបន្ត។ វាមិនមែនជារឿងងាយស្រួលទេ ក្នុងការស្វែងរកជំនួយពីបណ្តាប្រទេសផ្សេងៗ លុះត្រាតែយើងមានរបាយការណ៍ច្បាស់លាស់អំពីវឌ្ឍនភាពនៃការងារនីមួយៗ ហើយការអនុវត្តបែបនេះមានសារៈសំខាន់ណាស់ ព្រោះតាមរយៈនៃការពិភាក្សានិងការធ្វើបទបង្ហាញក្នុងកិច្ចប្រជុំបច្ចេកទេស ដែលមានប្រើភាសាពីរគឺ អង់គ្លេស ខ្មែរ បានធ្វើឲ្យគេយល់ឃើញថាកម្ពុជាចាប់ផ្តើមមានអ្នកបច្ចេកទេសជំនាន់ថ្មីហើយ។ យើងពេញចិត្ត ព្រោះថាវាជាមធ្យោបាយដ៏ល្អបំផុតសម្រាប់ការចូលរួមថែរក្សាការពារតំបន់បេតិកភណ្ឌពិភពលោក ដោយប្រើប្រព័ន្ធអភិរក្សនេះ ព្រោះគ្មានការបែងចែករវាងប្រទេសធំ និងប្រទេសតូច អ្នកមានបទពិសោធន៍ច្រើន និងអ្នកមានបទពិសោធន៍តិច ហើយយើងមកទីនេះដោយមានភាពស្មើគ្នា និងគោលបំណងរួមតែមួយក្នុងការថែរក្សានិរន្តរភាពនៃបេតិកភណ្ឌវប្បធម៌។



© APSARA



## អំពីបេតិកភណ្ឌ



© APSARA

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋសមាជិកនៃអង្គការយូណេស្កូនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៥១។ ការប្រើប្រាស់សញ្ញាណសម្គាល់នៃបេតិកភណ្ឌ នៅទីបំផុតត្រូវបានគេទទួលស្គាល់ជាសកល គឺគ្របដណ្តប់ប្រាសាទ បណ្តុំប្រាសាទរមណីយដ្ឋាននិងទីកន្លែងទាំងឡាយដែលមានតម្លៃពិសេសដាច់គេផ្នែកប្រវត្តិសាស្ត្រ បុរាណវិទ្យា ស្ថាបត្យកម្ម ឬផ្នែកធម្មជាតិ និងបរិស្ថាន។

បើតាមសញ្ញាណដែលគេទទួលស្គាល់ជាទូទៅនេះ បេតិកភណ្ឌ គឺជាបណ្តុំសម្បត្តិរួមរបស់សមូហភាពដែលទទួលបានជាកេរមរតកពីអតីតកាលដ៏យូរអង្វែងៗ បេតិកភណ្ឌ ក៏អាចជាលទ្ធផលរបស់ធម្មជាតិតាមរយៈពេលវេលា (បេតិកភណ្ឌធម្មជាតិ៖ គឺសត្វ រុក្ខ ទីកន្លែងនៃពិភពរុក្ខ) ហើយក៏អាចជាសមិទ្ធផលរបស់មនុស្សក្នុងរយៈពេលច្រើនសតវត្ស (បេតិកភណ្ឌវប្បធម៌៖ មានន័យថា អ្វីៗដែលមនុស្សបាននាំមកឲ្យប្រវត្តិសាស្ត្រនៃពិភពលោក វប្បធម៌ និងអរិយធម៌)។

សរុបមក បេតិកភណ្ឌ គឺជាមរតកដែលទទួលបានពីអតីតកាលនិងដែលត្រូវផ្ទេរបន្តទៅមនុស្សជំនាន់ក្រោយៗទៀត។

បេតិកភណ្ឌវប្បធម៌ ចែកចេញជាបេតិកភណ្ឌវប្បធម៌រូបីនិងបេតិកភណ្ឌវប្បធម៌អរូបី។

ក- បេតិកភណ្ឌវប្បធម៌រូបីរួមមាន៖ ប្រាសាទ សំណង់ស្ថាបត្យកម្ម រមណីយដ្ឋាន ធាតុទាំងឡាយពាក់ព័ន្ធនឹងបុរាណវិទ្យា ផ្ទាំងគំនូរ ចម្លាក់តាមប្រាសាទ សិលាចារឹកប្រឡាយទឹកប្រវត្តិសាស្ត្រ សំណង់ជាកសាស្ត្រសំខាន់ៗក្រុងបុរាណ ទេសភាពវប្បធម៌ ការរៀបចំដីធ្វើកសិកម្ម ឬព្រៃឈើក្នុងប្រវត្តិសាស្ត្រ ។ បើនិយាយដោយសង្ខេប គឺស្លាកស្នាមរយៈពេលវែងនៃវត្តមានរបស់មនុស្ស ដែលមានតម្លៃលេចធ្លោ។

ខ- បេតិកភណ្ឌវប្បធម៌អរូបី រួមមាន៖ ប្រពៃណីទំនៀមទម្លាប់ ការសម្តែងតាមទម្រង់សិល្បៈ ដូចជា ចម្រៀង តន្ត្រី ល្ខោន ជំនឿ កិច្ចពិធីនានា ព្រឹត្តិការណ៍បុណ្យទានមានលក្ខណៈប្រជាប្រិយ ចំណេះដឹងជាប្រពៃណី ចំណេះធ្វើ និងការប្រតិបត្តិផ្សេងៗទាក់ទងនឹងពិភពធម្មជាតិ ឬចក្រវាឡ។ ជារួមគឺគ្រប់សកម្មភាពដែលមានជីវិត និងមានអត្ថន័យ ទង្វើនិងកាយវិការ មធ្យោបាយទំនាក់ទំនងជំនឿ និងការប្រតិបត្តិទាំងឡាយដែលកើតឡើងជាមួយគ្នា និងជាប់ខ្សែក ដោយមិនពាក់ព័ន្ធនឹងពិភពទំនើបនិងពិភពបច្ចុប្បន្ននេះទេ។

បេតិកភណ្ឌធម្មជាតិ ជាមរតកធម្មជាតិ ដែលជាតឹកតាងប្រវត្តិសាស្ត្រនៃភពផែនដីក្នុងដំណើរវិវត្តនៅក្នុងចក្រវាឡ

បណ្ដុំផ្ទា ឬលម្អ ដែលមានសត្វនិងរុក្ខជាតិមានជីវិតមានតម្លៃគួរឲ្យកត់សម្គាល់ចំពោះវិទ្យាសាស្ត្រ និងចំពោះភាពសុខដុមរមនាយូរអង្វែងរវាងមនុស្ស បរិស្ថាន និងសង្គមនៅជុំវិញ។

## បេតិកភណ្ឌពិភពលោក

រមណីយដ្ឋានមួយបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក (ឬបេតិកភណ្ឌនៃមនុស្សជាតិ) គឺសំដៅទៅរមណីយដ្ឋាននៃបេតិកភណ្ឌវប្បធម៌រូបី ឬរមណីយដ្ឋានធម្មជាតិ ដែលផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យឥតល្អៀង ហើយដែលបានទទួលស្គាល់ជាឯកច្ឆន្ទ។ ក្រោយពីការវាយតម្លៃពីអ្នកជំនាញការឯករាជ្យមក ឃើញថារមណីយដ្ឋាននោះ ពិតជាមានតម្លៃលេចធ្លោជាសកលបើប្រៀបធៀបនឹងមនុស្ស និងប្រវត្តិសាស្ត្រនៃមនុស្ស ឬប្រៀបធៀបនឹងធម្មជាតិនិងការវិវត្តរបស់ធម្មជាតិ។

សម្បត្តិមួយបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយប្រកាសជាបេតិកភណ្ឌពិភពលោក (យូណេស្កូ) គឺដើម្បីទទួលការអភិរក្ស ដោយរក្សាបូរណភាព និងភាពដើមនៃសម្បត្តិនោះ ជាគុណប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគតនៅលើផ្នែកវិទ្យាសាស្ត្រនិងសិល្បៈក៏ដូចជាដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។

គួរកត់សម្គាល់ថា សម្បត្តិខ្លះជាបេតិកភណ្ឌផ្នែកវប្បធម៌ផង និងផ្នែកធម្មជាតិផង។ សម្បត្តិទាំងនោះត្រូវបានចុះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយផ្អែកលើមូលដ្ឋាននៃបណ្ដាលក្ខណៈវិនិច្ឆ័យ និងក្រោយពីមានការវាយតម្លៃផ្នែកវប្បធម៌ផងនិងផ្នែកធម្មជាតិផង។ សម្បត្តិទាំងនោះមានឈ្មោះថា បេតិកភណ្ឌចម្រុះ។

ការចុះបញ្ជី ធ្វើឡើងតាមរយៈសេចក្ដីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដោយអនុលោមតាមអនុសញ្ញាឆ្នាំ១៩៧២ ស្ដីពីការការពារបេតិកភណ្ឌផ្នែកវប្បធម៌និងធម្មជាតិពិភពលោក។ អ្នកជំនាញជាច្រើនបានកត់សម្គាល់ថា បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ កាន់តែប្រឈមនឹងគ្រោះមហន្តរាយមិនគ្រាន់តែខូចខាតដោយសារអាយុកាលប៉ុណ្ណោះទេ ប៉ុន្តែមានមូលហេតុផ្សេងទៀតគឺ ការវិវត្តនៃជីវភាពសង្គម និងសេដ្ឋកិច្ច ដែលធ្វើឲ្យការខូចខាតកាន់តែធ្ងន់ធ្ងរ និងបាតុភូតមួយចំនួនដែលធ្វើឲ្យប៉ះពាល់ ឬធ្វើឲ្យខូចខាតកាន់តែគួរឲ្យខ្លាចថែមទៀត។ ដោយហេតុនេះហើយបានជាអង្គការយូណេស្កូនៅក្នុងមហាសន្និបាតលើកទី១៧ នាខែវិច្ឆិកា ឆ្នាំ១៩៧២ នៅទីក្រុងប៉ារីស ប្រទេសបារាំង បានអនុម័តអនុសញ្ញាឆ្នាំ១៩៧២។ អនុសញ្ញានេះគឺជាកិច្ចព្រមព្រៀងអន្តរជាតិ ស្ដីពីកិច្ចការពារបេតិកភណ្ឌពិភពលោកផ្នែកវប្បធម៌ និងធម្មជាតិដោយគ្មានទំនាក់ទំនងអ្វីជាមួយបញ្ហានយោបាយឬផលប្រយោជន៍ហិរញ្ញវត្ថុនោះទេ។

អនុសញ្ញាចែងអំពីកាតព្វកិច្ចរបស់រដ្ឋភាគី ត្រូវធ្វើការកំណត់អត្តសញ្ញាណកម្មសម្បត្តិទាំងឡាយ ដែលខ្លួនត្រៀមសុំចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅក្នុងបញ្ជីត្រៀម ហើយចង្អុលបង្ហាញថា រដ្ឋភាគីត្រូវធ្វើដូចម្ដេចដើម្បីបំពេញតួនាទីរបស់ខ្លួនក្នុងការការពារ និងអភិរក្សសម្បត្តិទាំងនោះ។ នៅពេលផ្ដល់សច្ចាប័នលើអនុសញ្ញានេះ ប្រទេសនីមួយៗមានកាតព្វកិច្ចមិនគ្រាន់តែជានាការអភិរក្សសម្បត្តិដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកាតព្វកិច្ចត្រូវថែរក្សាការពារបេតិកភណ្ឌជាតិរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពនិងចីរភាពផងដែរ។ អនុសញ្ញានេះក៏បានចែងពីកាតព្វកិច្ចរបស់រដ្ឋភាគី ត្រូវផ្ដល់របាយការណ៍ទៀងទាត់ជូនគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ស្ដីពីស្ថានភាពនៃការអភិរក្សបេតិកភណ្ឌដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងត្រូវជួយសម្របសម្រួលបេសកកម្មរបស់អ្នកជំនាញការដែលទទួលបន្ទុកមកធ្វើការវាយតម្លៃអំពីស្ថានភាពនៃការអភិរក្សនេះ។

ការអនុវត្តអនុសញ្ញាឆ្នាំ១៩៧២ ដែលឃ្លាំមើលដោយគណៈកម្មាធិការមួយ មានសមាសភាពមកពីរដ្ឋភាគីជ្រើសរើសដោយការបោះឆ្នោត ត្រូវធ្វើឡើងដោយអនុលោមតាមអត្ថបទគោលឈ្មោះថា «សេចក្ដីណែនាំក្នុងការអនុវត្តអនុសញ្ញានៃបេតិកភណ្ឌពិភពលោក» ដែលរៀបចំដោយបណ្ដាប្រទេស និងអនុម័តដោយការព្រមព្រៀងតាមមតិភាគច្រើន ឬតាមរយៈការបោះឆ្នោតដោយយកតាមមតិភាគច្រើនដាច់ខាត (មានន័យថា ២/៣ នៃសមាជិករបស់គណៈកម្មាធិការដែលមានវត្តមាននិងដែលត្រូវបោះឆ្នោត)។

អស់រយៈពេលជាច្រើនឆ្នាំក្រោយមក អនុសញ្ញានេះបានធ្វើឲ្យបេតិកភណ្ឌផ្នែកវប្បធម៌ និងធម្មជាតិក្លាយជាកម្មវត្ថុនៃច្បាប់អន្តរជាតិ។ អនុសញ្ញាបានបង្កលក្ខណៈឲ្យសញ្ញាណនៃសហគមន៍អន្តរជាតិ បានឆ្លងមកដល់ទស្សនទាននៃមនុស្សជាតិ ហើយទន្ទឹមនឹងនោះ នាំមកនូវគោលការណ៍នៃលក្ខណៈសកល ដែលនាំឲ្យមានការសន្មតថាមនុស្សជាតិគឺតំណាងដោយបេតិកភណ្ឌរួមមួយ។

នៅខែមិថុនា ឆ្នាំ២០១៤ (សម័យប្រជុំលើកទី៣៨ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីក្រុងដូហា រដ្ឋកាតា) មានរដ្ឋ១៩១ ដែលបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីការការពារបេតិកភណ្ឌពិភពលោក ពោលគឺស្ទើរតែជាចំនួនរដ្ឋជាសមាជិកនៃអង្គការយូណេស្កូទាំងអស់។

អនុសញ្ញាឆ្នាំ១៩៧២ ស្ដីពីកិច្ចការពារបេតិកភណ្ឌផ្នែកវប្បធម៌និងធម្មជាតិ បានកំណត់អំពីមុខងាររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក របៀបជ្រើសរើសសមាជិក និងអាណត្តិរបស់គណៈកម្មាធិការ។ គណៈកម្មាធិការនេះ ធ្វើការប្រជុំទៀងទាត់មួយដងក្នុងមួយឆ្នាំ។ តំណាងរដ្ឋភាគីចំនួន២១ដែលជាសមាជិករបស់គណៈកម្មាធិការត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតនៅក្នុងមហាសន្និបាតរដ្ឋភាគី នៃអនុសញ្ញាសម្រាប់អាណត្តិជាអតិបរមា៦ឆ្នាំ (ក្នុងការជាក់ស្ដែងអាណត្តិនេះត្រូវបានបន្ថយមកត្រឹម៤ឆ្នាំ តាំងពីជាង១០ឆ្នាំមកហើយ)។ តំណាងផ្សេងៗទៀតរបស់រដ្ឋភាគីចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងឋានៈជាអ្នកសង្កេតការណ៍។

គណៈកម្មាធិការដែលមានសមាជិកចំនួន២១រូបមានតួនាទីសំខាន់ដូចខាងក្រោម៖

- លើមូលដ្ឋាននៃបញ្ជីសំណើសុំចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់រដ្ឋភាគី ធ្វើការកំណត់អត្តសញ្ញាណកម្មនៃសម្បត្តិផ្នែកវប្បធម៌ និងធម្មជាតិដែលមានតម្លៃលេចធ្លោជាសកល ដែលនឹងត្រូវការពារនៅក្នុងក្របខណ្ឌអនុសញ្ញានេះ ហើយធ្វើការចុះសម្បត្តិទាំងនោះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។
- ឃ្លាំមើលស្ថានភាពនៃការអភិរក្សសម្បត្តិដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោកដោយទំនាក់ទំនងជាមួយរដ្ឋភាគី ដូច្នេះហើយធ្វើការសម្រេចថាសម្បត្តិបេតិកភណ្ឌពិភពលោកណាខ្លះត្រូវចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ ឬត្រូវដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ ឬជួនកាលសម្រេចថា តើសម្បត្តិបេតិកភណ្ឌពិភពលោកណាមួយត្រូវដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោក។
- ពិនិត្យសំណើសុំជំនួយអន្តរជាតិ ដែលផ្ដល់ថវិកាដោយមូលនិធិនៃបេតិកភណ្ឌពិភពលោក។
- ត្រួតពិនិត្យនីតិវិធីក្នុងការសុំជំនួយអន្តរជាតិ និងពិគ្រោះយោបល់បច្ចេកទេសជាមួយអ្នកជំនាញការឯករាជ្យមុននឹងធ្វើការសម្រេចចិត្ត។
- គ្រប់គ្រងមូលនិធិបេតិកភណ្ឌពិភពលោក ហើយយកចិត្តទុកដាក់ធ្វើដូចម្ដេចឲ្យការប្រើប្រាស់មូលនិធិនេះធ្វើឡើងសម្រាប់តែកិច្ចការពារសម្បត្តិបេតិកភណ្ឌដែលមានតម្លៃលេចធ្លោជាសកលដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកតាមការស្នើសុំរបស់រដ្ឋភាគីតែប៉ុណ្ណោះ។
- រៀងរាល់ពីរឆ្នាំម្ដងធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនមហាសន្និបាត នៃរដ្ឋភាគីនិងជូនមហាសន្និបាតរបស់អង្គការយូណេស្កូ។
- ពិនិត្យកែសម្រួលឡើងវិញនិងអនុម័តនូវ «សេចក្ដីណែនាំនិងនីតិវិធីក្នុងការអនុវត្តអនុសញ្ញាឆ្នាំ១៩៧២»។

## ការចុះសម្បត្តិមួយក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

ដើម្បីដាក់ពាក្យសុំចុះសម្បត្តិមួយក្នុងបញ្ជីបេតិកភណ្ឌពិភពលោក (យូណេស្កូ) ប្រទេសទាំងអស់ត្រូវតែផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ១៩៧២ ហើយតាមរយៈការផ្តល់សច្ចាប័ននេះ រដ្ឋនោះក្លាយជារដ្ឋភាគីនៃអនុសញ្ញា។

គណៈកម្មាធិការចាត់ទុកថា សម្បត្តិមួយមានតម្លៃលេចធ្លោជាសកល ហើយសម្រេចចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ប្រសិនបើសម្បត្តិនោះឆ្លើយតបយ៉ាងហោចណាស់ទៅនឹងលក្ខណៈវិនិច្ឆ័យមួយនៃបណ្តាលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

(i) តំណាងឲ្យស្នាដៃកំពូលនៃទេពកោសល្យរបស់មនុស្សក្នុងការបង្កើតថ្មី។

(ii) បង្ហាញពីការផ្លាស់ប្តូរនៃការជះឥទ្ធិពលយ៉ាងសម្បើមក្នុងសម័យកាលណាមួយនោះ ឬក្នុងតំបន់វប្បធម៌កំណត់ច្បាស់លាស់មួយទៅលើការរីកចម្រើននៃស្ថាបត្យកម្ម ឬបច្ចេកវិទ្យា សិល្បៈសំណង់ប្រាង្គប្រាសាទ ផែនការកម្មទីក្រុង ឬការបង្កើតទេសភាព។

(iii) ជាសាក្សីកម្មតែមួយគត់ ឬយ៉ាងហោចណាស់លេចធ្លោជាងគេនៃប្រពៃណីវប្បធម៌ ឬអរិយធម៌មួយដែលនៅរស់រាន ឬដែលបានបាត់បង់ទៅហើយ។

(iv) ជាគំរូដ៏ឆ្នើមមួយនៃប្រភេទសំណង់ ឬសំណុំស្ថាបត្យកម្ម ឬបច្ចេកវិទ្យា ឬទេសភាព ដែលរំលេចនូវសម័យកាលណាមួយឬច្រើន ដែលមានអត្ថន័យជាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

(v) ជាគំរូដ៏ឆ្នើមមួយនៃការតាំងទីលំនៅតាមបែបប្រពៃណីរបស់មនុស្សជាតិ ការប្រើប្រាស់ដីធ្លី ឬសមុទ្រដែលតំណាងឲ្យវប្បធម៌មួយឬច្រើន ឬអន្តរកម្មរវាងការរស់នៅរបស់មនុស្សជាមួយបរិស្ថានជាពិសេសនៅពេលដែលវាងាយទទួលរងផលប៉ះពាល់ពីការផ្លាស់ប្តូរដែលមិនអាចត្រឡប់មកសភាពដើមវិញបាន។

(vi) មានទំនាក់ទំនងដោយផ្ទាល់ ឬដោយសម្ភារៈជាមួយនឹងព្រឹត្តិការណ៍ ឬប្រពៃណីទំនៀមទម្លាប់រស់រវើកជាមួយនឹងគំនិត ជំនឿ ឬស្នាដៃសិល្បៈ និងអក្សរសាស្ត្រដែលមានអត្ថន័យលេចធ្លោជាសកល (គណៈកម្មាធិការចាត់ទុកថាជាការល្អ លក្ខណៈវិនិច្ឆ័យនេះត្រូវប្រើរួមជាមួយលក្ខណៈវិនិច្ឆ័យដទៃទៀត)។

(vii) តំណាងឲ្យបាតុភូតធម្មជាតិដ៏គួរឲ្យកត់សម្គាល់ ឬជាតំបន់ប្រកបដោយទេសភាពធម្មជាតិដ៏វិសេសវិសាល និងប្រកបដោយសារៈសំខាន់ខាងសោភ័ណភាពដ៏លេចធ្លោ។

(viii) ជាគំរូដ៏ឆ្នើម តំណាងឲ្យដំណាក់កាលសំខាន់ៗនៃប្រវត្តិសាស្ត្រផែនដី រួមទាំងកំណត់ត្រានៃជីវិត ដំណើរការនៃភូគព្ភសាស្ត្រ ដែលកំពុងបន្តក្នុងការកកើតទម្រង់ផែនដី ឬទម្រង់សណ្ឋានដី ឬភូមិសាស្ត្រដែលមានអត្ថន័យដ៏សំខាន់។

(ix) ជាគំរូដ៏ឆ្នើម តំណាងឲ្យដំណើរការអេកូឡូស៊ី និងជីវសាស្ត្រ ដែលនៅតែបន្តមានក្នុងដំណើរការវិវត្ត និងការអភិវឌ្ឍរបស់ប្រព័ន្ធអេកូឡូស៊ីនៃផែនដី ក្លជាតិ និងសត្វរស់នៅលើគោក ក្នុងទឹក តំបន់ឆ្នេរ និងក្នុងសមុទ្រ។

(x) ជាជម្រកធម្មជាតិមានលក្ខណៈតំណាងនិងសំខាន់បំផុត សម្រាប់ការអភិរក្សជីវៈចម្រុះនៅនឹងកន្លែង ដែលក្នុងនោះមានរួមបញ្ចូលទាំងប្រភេទដែលស្ថិតនៅក្នុងស្ថានភាពប្រឈមនឹងការផុតពូជហើយដែលមានតម្លៃលេចធ្លោជាសកល តាមទស្សនៈវិទ្យាសាស្ត្រ ឬទស្សនៈនៃការអភិរក្ស។

ទោះជាសម្បត្តិណាមួយត្រូវបានចាត់ទុកថាមានតម្លៃលេចធ្លោជាសកលហើយក្តី ប៉ុន្តែសម្បត្តិនោះក៏ត្រូវតែបំពេញលក្ខខណ្ឌបូរណភាព និង (ឬ) ភាពដើម ហើយត្រូវតែទទួលបាននូវប្រព័ន្ធការពារនិងគ្រប់គ្រងមួយសមស្រប ដើម្បីធានាការគង់វង្សរបស់សម្បត្តិនោះ (ផែនការគ្រប់គ្រង)។

ORGANISATION DES NATIONS UNIES
POUR L'ÉDUCATION,
LA SCIENCE ET LA CULTURE

CONVENTION CONCERNANT
LA PROTECTION DU PATRIMOINE
MONDIAL
CULTUREL ET NATUREL

*Le Comité du patrimoine mondial*
*a inscrit*

# *Angkor*

***sur la Liste du patrimoine mondial***

***L'inscription sur cette Liste consacre la valeur universelle exceptionnelle d'un bien culturel ou naturel afin qu'il soit protégé au bénéfice de l'humanité***

DATE D'INSCRIPTION

14 décembre 1992

LE DIRE CTEUR GÉNÉRAL
DE L'UNESCO

## ការចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

សូមរំឭកថា ព្រះករុណាព្រះបាទសម្តេច**ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" បានឡាយព្រះហស្តលេខាលើសំណុំលិខិតស្នើសុំចុះរមណីយដ្ឋានអង្គរ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩១ ដោយព្រះអង្គទ្រង់បានអំពាវនាវសុំឲ្យអង្គការយូណេស្កូ ធ្វើការសម្របសម្រួលជាមួយសហគមន៍អន្តរជាតិ លើកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដើម្បីជួយសង្គ្រោះអង្គរ។ ផ្អែកលើរបាយការណ៍វាយតម្លៃមួយរបស់អ្នកជំនាញការ រមណីយដ្ឋានអង្គរត្រូវបានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក កំណត់លក្ខណៈវិនិច្ឆ័យចំនួន៤ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងឡាយដែលតម្រូវសម្រាប់ការចុះសម្បត្តិមួយក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយបានសម្រេចចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។ លក្ខណៈវិនិច្ឆ័យទាំងនោះរួមមាន៖

- (i) រមណីយដ្ឋានអង្គរបង្ហាញអំពីសិល្បៈខ្មែរទាំងមូល ចាប់តាំងពីសតវត្សទី៩ រហូតដល់សតវត្សទី១៤ ដោយរួមមានស្នាដៃឯកផ្នែកសិល្បៈជាច្រើនដូចជា ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន្ត ប្រាសាទបន្ទាយស្រីជាដើម។
- (ii) ឥទ្ធិពលសិល្បៈខ្មែរដូចដែលគេឃើញនៅអង្គរ ជះឥទ្ធិពលទៅលើសិល្បៈនានាមួយផ្នែកធំនៃតំបន់អាស៊ីអាគ្នេយ៍ និងដើរតួនាទីដ៏សំខាន់នៅក្នុងដំណើរវិវត្តដោយឡែករបស់តំបន់នេះ។
- (iii) ចក្រភពខ្មែរនៅចន្លោះសតវត្សទី៩ និងសតវត្សទី១៤ បានគ្របដណ្តប់មួយភាគធំនៃតំបន់អាស៊ីអាគ្នេយ៍ និងដើរតួនាទីចម្បងក្នុងការអភិវឌ្ឍវប្បធម៌ និងនយោបាយក្នុងតំបន់។ អ្វីៗនៅសល់ពីអារ្យធម៌ដ៏រុងរឿងនេះ គឺបេតិកភណ្ឌដ៏សម្បូរបែបនៃប្រាសាទដែលសង់អំពីឥដ្ឋនិងអំពីថ្មជាច្រើន។
- (iv) ស្ថាបត្យកម្មខ្មែរ បានវិវត្តចេញពីឧបទ្វីបឥណ្ឌា ប៉ុន្តែក្នុងរយៈពេលមួយដ៏ឆាប់បានឃ្លាតពីឥទ្ធិពលឥណ្ឌា ចាប់តាំងពីស្ថាបត្យកម្មនេះបានអភិវឌ្ឍន៍លក្ខណៈពិសេសដោយឡែករបស់ខ្លួន។ លក្ខណៈពិសេសនៃស្ថាបត្យកម្មនេះបានវិវត្តដោយឯករាជ្យ ហើយខ្លះទៀត បានដកស្រង់គំនិតយកមកពីប្រពៃណីវប្បធម៌ជិតខាងៗ ជាលទ្ធផលស្ថាបត្យកម្មខ្មែរបានលេចចេញនូវលក្ខណៈថ្មីមួយដោយឡែករបស់ខ្លួននៅក្នុងវិស័យសិល្បៈ និងស្ថាបត្យកម្មតំបន់អាស៊ី។

គួររំឭកថា នៅក្នុងសន្និសីទអន្តររដ្ឋាភិបាលស្តីពីអង្គរលើកទី១ នាទីក្រុងតូក្យូ ព្រះករុណាព្រះបាទសម្តេច**ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" បានទទួលការបោះឆ្នោតថ្វាយព្រះកេត្តនាមដ៏ខ្ពង់ខ្ពស់ ជាព្រះប្រធានកិត្តិយសរបស់អាយស៊ីស៊ី-អង្គរ ហើយព្រះអង្គទ្រង់បានធានាអំពីបូរណភាពរបស់រមណីយដ្ឋានអង្គរ និងការគ្រប់គ្រងរមណីយដ្ឋាននេះប្រកបដោយចីរភាព។ ដោយឡែកនាសម័យប្រជុំលើកទី៣៦នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលបានប្រព្រឹត្តទៅនៅទីក្រុង Saint-Pétersbourg ពីថ្ងៃទី២៤ ខែមិថុនា រហូតដល់ថ្ងៃ៦នៃកក្កដា ឆ្នាំ២០១២ សេចក្តីសម្រេចលេខ C 668 ពាក់ព័ន្ធនឹងតម្លៃលេចធ្លោជាសកលបានបញ្ជាក់ច្បាស់នូវបណ្តាលក្ខណៈវិនិច្ឆ័យ និងតម្លៃទាំងឡាយដែលអង្គរបានឆ្លើយតប។ នៅក្នុងការសំយោគសង្ខេបតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានអង្គរបានសង្កត់ធ្ងន់លើភាពពិត និងបូរណភាពនៃរមណីយដ្ឋានអង្គរ ដោយធ្វើការវិភាគលើគោលការណ៍ជាមូលដ្ឋានដែលតម្រូវចាំបាច់ក្នុងការការពារ និងគ្រប់គ្រង។





## សេចក្តីសម្រេចពាក់ព័ន្ធនឹងអង្គរ លេខ C 668 ស្តីពី តម្លៃលេចធ្លោជាសកល (សំយោគសង្ខេប)

"អង្គរ" ស្ថិតក្នុងខេត្តសៀមរាបភាគខាងជើងនៃប្រទេសកម្ពុជា គឺជារមណីយដ្ឋានបុរាណមួយយ៉ាងធំក្នុងបណ្តារមណីយដ្ឋានបុរាណនៅអាស៊ីអាគ្នេយ៍។ រមណីយដ្ឋាននេះ មានទំហំប្រហែល៤០១គីឡូម៉ែត្រក្រឡារួមមានប្រាសាទ រចនាសម្ពន្ធធារាសាស្ត្រ (បារាយណ៍ ទំនប់ ករសិទ្ធ ប្រឡាយទឹក) និងផ្លូវគមនាគមន៍ជាច្រើន។ ក្នុងរយៈពេលជាច្រើនសតវត្ស "អង្គរ" គឺជារាជធានីនៃអាណាចក្រខ្មែរ។ រមណីយដ្ឋានអង្គរដែលប្រកបដោយប្រាសាទដ៏គួរឲ្យស្ញប់ស្ញែង ទីតាំងអតីតរាជធានី និងបារាយណ៍ជាច្រើន គឺជាការប្រមូលផ្តុំតែមួយគត់នៃបណ្តាលក្ខណៈជាតឹកតាងនៃអរិយធម៌មួយដ៏រុងរឿង។ ប្រាង្គប្រាសាទដូចជា ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន្ត ប្រាសាទព្រះខ័ន និងប្រាសាទតាព្រហ្ម ដែលជាឧទាហរណ៍នៃស្ថាបត្យកម្មខ្មែរ សុទ្ធសឹងតែផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងបរិបទភូមិសាស្ត្រ ហើយក៏ផិតជាមទៅដោយអត្ថន័យជានិមិត្តរូបផងដែរ។ ស្ថាបត្យកម្ម និងប្លង់រាជធានី ជាតឹកតាងនៃសណ្តាប់ធ្នាប់ និងឋានានុក្រមសង្គមកម្រិតខ្ពស់នៅក្នុងចក្រភពខ្មែរ។ ដូច្នេះ "អង្គរ" ក្រៅពីបង្ហាញ ឲ្យឃើញនូវសារៈសំខាន់ខ្ពស់ផ្នែកស្ថាបត្យកម្ម បុរាណវិទ្យា និងសិល្បៈ ក៏ជារមណីយដ្ឋានចម្បងផ្ទុះបញ្ចាំងនូវតម្លៃវប្បធម៌ សាសនា និងនិមិត្តរូបផងដែរ។

ឧទ្យានអង្គរមានប្រជាជនរស់នៅ មានភូមិដ្ឋានជាច្រើននៅរាយប៉ាយក្នុងទូទាំងឧទ្យាន ក្នុងនោះភូមិដ្ឋានខ្លះមានតាំងពីសម័យអង្គរមកម្ល៉េះ។ ប្រជាពលរដ្ឋច្រើនប្រកបមុខរបរកសិកម្ម ជាពិសេសរបរធ្វើស្រែ។

•លក្ខណៈវិនិច្ឆ័យ(១) រមណីយដ្ឋានអង្គរទាំងមូលបង្ហាញអំពីសិល្បៈខ្មែរតាំងពីដើមដំបូងនាសតវត្សទី៩ រហូតដល់ចុងបញ្ចប់នាសតវត្សទី១៤ ហើយនៅក្នុងរមណីយដ្ឋាននេះ គេឃើញនូវកំពូលស្នាដៃឯកផ្នែកសិល្បៈជាច្រើន (ឧទាហរណ៍ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន្ត ប្រាសាទបន្ទាយស្រី)។

•លក្ខណៈវិនិច្ឆ័យ (២) គេអាចមានអារម្មណ៍ថា សិល្បៈខ្មែរដូចដែលឃើញសព្វថ្ងៃនៅរមណីយដ្ឋានអង្គរ បានសាយភាយឥទ្ធិពលទៅផ្នែកភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍។ គេឃើញថា សិល្បៈខ្មែរដើរតួនាទីដ៏សំខាន់ណាស់នៅក្នុងដំណើរវិវត្តដោយឡែករបស់តំបន់នេះ។

•លក្ខណៈវិនិច្ឆ័យ (៣) ចក្រភពខ្មែរនៅចន្លោះសតវត្សទី៩ និងសតវត្សទី១៤ បានលាតសន្ធឹងទៅលើផ្នែកភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍។ ចក្រភពនេះមានឥទ្ធិពលបណ្តុះបញ្ញាញាណទៅលើការវិវត្តផ្នែកនយោបាយ និងវប្បធម៌នៃតំបន់។ អ្វីដែលនៅសេសសល់ពីអរិយធម៌នេះ គឺបេតិកភណ្ឌដ៏សម្បូរបែបនៃសំណង់សាសនា កសាងអំពីឥដ្ឋនិងថ្ម។

•លក្ខណៈវិនិច្ឆ័យ (៤) ស្ថាបត្យកម្មខ្មែរបានវិវត្តចេញពីឧបទ្វីបឥណ្ឌា ប៉ុន្តែបានផ្តាច់ខ្លួនពីឥទ្ធិពលឥណ្ឌាយ៉ាងឆាប់រហ័ស នៅពេលដែលស្ថាបត្យកម្មនេះបានអភិវឌ្ឍន៍លក្ខណៈរបស់ខ្លួន។ លក្ខណៈខ្លះបានរីកធំធាត់ដោយឯករាជ្យ លក្ខណៈខ្លះទៀតដកស្រង់គំនិតពីប្រពៃណីវប្បធម៌ប្រទេសជិតខាងៗ ជាលទ្ធផលសិល្បៈខ្មែរមានលក្ខណៈដោយឡែករបស់ខ្លួន បើប្រៀបធៀបនឹងសិល្បៈ និងស្ថាបត្យកម្មនៃបណ្តាប្រទេសតំបន់បូព៌ា។

## បូរណភាព

តំបន់អង្គរគ្របដណ្តប់ដោយសំណង់ប្រាសាទសំខាន់ៗ បណ្តាញធារាសាស្ត្រសម័យចក្រភពខ្មែរ បណ្តាបារាយណ៍ និងប្រឡាយទាំងឡាយនៅតែបន្តមានអត្ថិភាព។ ទិដ្ឋភាពប្រាសាទនីមួយៗ ទិដ្ឋភាពប្រព័ន្ធធារាសាស្ត្រនីមួយៗ ឆ្លុះបញ្ចាំងឲ្យឃើញនូវលក្ខណៈនៅគង់វង្សរបស់រមណីយដ្ឋាន ឆ្លុះបញ្ចាំងឲ្យឃើញនូវភាពរុងរឿងនៃរាជធានីសម័យបុរាណ។ ប៉ុន្តែបូរណភាពរបស់រមណីយដ្ឋាននៅពេលបច្ចុប្បន្នកំពុងប្រឈមនឹងសម្ពាធពីរប្រភេទ៖

១. សម្ពាធកើតចេញពីក្នុងអង្គរ បង្កដោយប្រជាពលរដ្ឋ១០០,០០០នាក់ដែលរស់នៅក្នុងភូមិចំនួន១១២ រាយប៉ាយក្នុងរមណីយដ្ឋានដែលមាននិន្នាការជាប្រចាំចង់ពង្រីកដីធ្លី ផ្ទះសំបែងរបស់ខ្លួន។

២. សម្ពាធកើតចេញពីក្រៅ ដោយសារស្ថិតនៅជាប់នឹងទីក្រុងសៀមរាប ទីរួមខេត្ត និងជាកន្លែងទទួលទេសចរស្នាក់នៅ។

## ភាពពិត

ការងារអភិរក្ស និងជួសជុលអង្គរដែលបានធ្វើឡើង

នៅចន្លោះឆ្នាំ១៩០៧និង១៩៩២ ជាពិសេសធ្វើឡើងដោយសាលាបារាំងចុងបូព៌ាប្រទេស (EFEO) ក្រុមបុរាណវិទ្យាប្រទេសឥណ្ឌា (ASI) អង្គការអភិរក្សរបស់ប្រទេសប៉ូឡូញ (PKE) និងអង្គការមូលនិធិនៃវិមានពិភពលោក (WMF) ពុំបង្កផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើភាពដើមរួមរបស់បណ្តាប្រាសាទទាំងឡាយនៅតំបន់អង្គរទេ ហើយក៏មិនបង្កផលប៉ះពាល់ដល់ចំណាប់អារម្មណ៍រួមអំពីប្រាសាទនីមួយៗដែរ ។

## ពាលការណ៍ទាំងឡាយដែលគ្រប់គ្រងទាំងជាប់ក្នុងការងារការពារនិងគ្រប់គ្រង

សម្បត្តិបេតិកភណ្ឌអង្គរត្រូវបានការពារលើផ្នែកច្បាប់ដោយព្រះរាជក្រឹត្យលេខ០០១.នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ។ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកត/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦។ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា។ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៧០.សសរ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលកំណត់ថា ដីធ្លីទាំងអស់ដែលស្ថិតក្នុងតំបន់១ និងតំបន់២ក្នុងរមណីយដ្ឋានសៀមរាបអង្គរ គឺជាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងអនុក្រឹត្យលេខ៥០.អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា ចុះថ្ងៃ ទី០៩ ខែឧសភា ឆ្នាំ២០០៨ ដែលបានចែងច្បាស់អំពីការបង្កើតនាយកដ្ឋានមួយទទួលបន្ទុកចុះបញ្ជីដីធ្លី រៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ។ ដើម្បីពង្រឹងការងារគ្រប់គ្រងដីធ្លី និងសំណង់ក្នុងតំបន់ការពារទី១និងទី២ បង្គោលកំណត់ព្រំប្រទល់តំបន់ការពារទី១និងទី២ ត្រូវបានដាំតាំងពីឆ្នាំ២០០២មក រួចបន្តនៅឆ្នាំ២០០៩ និងបញ្ចប់នៅឆ្នាំ២០១២។

## តំបន់នៅក្នុងបរិវេណរមណីយដ្ឋានអង្គរ និងខេត្តសៀមរាប

តាមព្រះរាជក្រឹត្យលេខ ០០១នស ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ តំបន់សៀមរាបអង្គរទាំងមូលត្រូវបានបែងចែកជា៥តំបន់ ដែលមានកម្រិតការពារខុសៗគ្នា៖

- តំបន់១ គឺជារមណីយដ្ឋានមានប្រាសាទ (ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ និងស្ថានីយបុរាណវត្ថុកម្រិតជាតិ)។
- តំបន់២ គឺជាឧទ្យានបុរាណវត្ថុត្រូវការពារ (តំបន់ទ្រនាប់ដែលស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ)។
- តំបន់៣ គឺជាតំបន់ទេសភាពវប្បធម៌ត្រូវការពារ (បរិស្ថានដែលបង្កើតឡើងដោយអន្តរកម្មរបស់មនុស្សឆ្លងកាត់ពេលវេលា)។
- តំបន់៤ គឺជាតំបន់ដែលមានសារប្រយោជន៍ខាងបុរាណវត្ថុវិទ្យា ឬប្រវត្តិសាស្ត្រ (រមណីយដ្ឋានដែលគេស្គាល់ទីតាំង ឬត្រូវរកទីតាំង ហើយដែលសារៈសំខាន់របស់តំបន់នេះ គឺអាចស្គាល់តែតាមរយៈការសិក្សាស្រាវជ្រាវនៅនឹងកន្លែងប៉ុណ្ណោះ)។
- តំបន់៥ គឺជាបរិវេណសម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចនិងវប្បធម៌នៃតំបន់សៀមរាបអង្គរ។

រមណីយដ្ឋានអង្គរ ដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មានផ្ទៃដីទំហំ៤០១គីឡូម៉ែត្រក្រឡា (ពោលគឺប្រហែល៤០១,០០០ហិកតា) ហើយនៅកន្លែងខ្លះមានប្រជាជនរស់នៅ។ ទឹកដីអង្គរមាន៣ផ្នែក ផ្នែកទី១មានផ្ទៃដី ៣៥១គីឡូម៉ែត្រក្រឡា (២៦គ.ម. x ១៣គ.ម.) គឺជារមណីយដ្ឋានអង្គរក្នុងន័យចង្អៀត។ ផ្នែកនេះរួមមានតំបន់១ រមណីយដ្ឋានមានប្រាសាទ និងតំបន់២ ឧទ្យានបុរាណវត្ថុត្រូវការពារស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ ស្របតាមបទដ្ឋានរបស់អនុសញ្ញានៃបេតិកភណ្ឌពិភពលោក។ បណ្តាំតំបន់១និងតំបន់២នេះ បង្កើតបានជាចតុកោណកែងដ៏ធំមួយ គ្របដណ្តប់បារាយណ៍ខាងលិច បារាយណ៍ខាងជើង និងបារាយណ៍ខាងកើត។ ចតុកោណកែងនេះ ភ្ជាប់ទៅតំបន់ការពាររមណីយដ្ឋានបន្ទាយស្រី (២០គីឡូម៉ែត្រក្រឡា) នៅខាងជើង និងភ្ជាប់ទៅរមណីយដ្ឋានរលួស (៣០គីឡូម៉ែត្រក្រឡា) នៅទិសអាគ្នេយ៍។ នៅក្នុងរមណីយដ្ឋានទាំងពីរខាងក្រោយនេះ តំបន់១និងតំបន់២បានត្រួតស៊ីគ្នា។ ព្រះរាជក្រឹត្យលេខ ០០១នស កំណត់តំបន់៣ ជាតំបន់ការពារទេសភាពវប្បធម៌មានលក្ខណៈបរមបុរាណដែលភ្ជាប់រវាងរមណីយដ្ឋានទាំងឡាយ ហើយការពារបរិវេណពិសេសដូចជាផងស្ទឹងរលួស ផងស្ទឹងសៀមរាប ដែលគ្របដណ្តប់តំបន់ក្រុងស្ទើរតែទាំងមូល។

តំបន់៤ បម្រុងទុកសម្រាប់តំបន់នៅដាច់ឆ្ងាយពីគ្នា ឬតំបន់ដែលត្រូវធ្វើចំណាត់ថ្នាក់នៅពេលខាងមុខ ដោយយោងតាមលទ្ធផលនៃការរកឃើញថ្មីៗ។ តំបន់នេះតម្រូវឲ្យមានការការពារកម្រិតប្រហាក់ប្រហែលនឹងតំបន់២ដែរ។

តំបន់១ និងតំបន់២ ជាតំបន់ការពារកម្រិតខ្ពស់ពុំអនុញ្ញាតឲ្យសាងសង់អគារលំនៅដ្ឋានថ្មីឡើយ រីឯដីធ្លីជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ តំបន់១ ត្រូវបានបម្រុងទុកសម្រាប់កិច្ចការពារ និងការលើកតម្លៃរមណីយដ្ឋានមានប្រាសាទ។ ការសាងសង់ដែលអនុញ្ញាតបាន គឺមានតែការសាងសង់ទាំងឡាយផ្សារភ្ជាប់ជាមួយនឹងការរៀបចំការទស្សនារបស់ភ្ញៀវទេសចរប៉ុណ្ណោះ ការសាងសង់លំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋពុំអនុញ្ញាតទេ។ ក្នុងតំបន់២ គម្រោងអភិវឌ្ឍន៍ទាំងឡាយត្រូវបានកម្រិតត្រឹមកិច្ចការការពារ ការលើកតម្លៃរមណីយដ្ឋានបុរាណវិទ្យា និង «ការអភិរក្សរបៀបរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន» តែប៉ុណ្ណោះ។ ក្នុងតំបន់២ អាចមានការអនុញ្ញាតឲ្យសាងសង់មជ្ឈមណ្ឌលសិប្បកម្មខ្នាតតូចៗ ភូមិចាស់ទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវថែរក្សា ប៉ុន្តែពុំអនុញ្ញាតឲ្យពង្រីកថែមទៀតឡើយ។



# BORNES DE DÉLIMITATION DES ZONES DE PROTECTION DU PARC D' ANGKOR







## អំពីអាជ្ញាធរជាតិអប្សរា

អប្សរាជាឈ្មោះអាជ្ញាធរ គឺជាពាក្យដែលដកស្រង់ពីភាសាបារាំងថា APSARA «Autorité pour la Protection du Site et l'Aménagement de la Région d'Angkor» ដែលមានន័យថា អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ។ អាជ្ញាធរជាតិអប្សរាត្រូវបានបង្កើតឡើងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ ដែលគណៈកម្មាធិការបេតិកភណ្ឌពិភពលោកសំណូមពរឲ្យប្រទេសកម្ពុជាបំពេញ ពេលដែលអង្គរបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។

នៅក្នុងដំណាក់កាលដំបូងៗនៃការចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួន អាជ្ញាធរជាតិអប្សរាបានកំណត់នូវផែនការយុទ្ធសាស្ត្រជាអាទិភាពជាក់លាក់ ដើម្បីជំរុញផែនការឲ្យក្លាយជាលទ្ធផលសម្រេចជាក់ស្តែង។ ការងារអាទិភាពនៅពេលនោះ គឺប្រើប្រាស់នូវរាល់លទ្ធភាពឬធនធាន រួមទាំងយន្តការជាតិនិងអន្តរជាតិ ដើម្បីធ្វើការជួសជុលសង្គ្រោះបន្ទាន់ដល់ប្រាង្គប្រាសាទនានា ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់យ៉ាងខ្លាំងពីការទន្ទ្រានដោយព្រៃឈើ កង្វះខាតនៃការថែរក្សាដោយមូលហេតុសង្គ្រាមស៊ីវិល គ្រាប់មីន និងការលួចគាស់កកាយរកវត្ថុបុរាណជាដើម។ ស្តែងចេញពីឧទ្ទៈដ៏មោះមុតក្នុងការថែរក្សាប្រាង្គប្រាសាទ ព្រមទាំងដោយទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការយូណេស្កូ គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ អាជ្ញាធរជាតិអប្សរាបានក្លាយខ្លួនជាផ្នែកមួយយ៉ាងសំខាន់ ដែលមិនអាចអត់បានក្នុងយុទ្ធនាការជួសជុលសង្គ្រោះបន្ទាន់ដល់ប្រាង្គប្រាសាទនានា។ ជាក់ស្តែងតាមរយៈគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ មានស្ថាប័នអន្តរជាតិជាច្រើន ដែលជាតំណាងឲ្យរដ្ឋាភិបាលនៃប្រទេសទាំងនោះ បានបើកការដ្ឋានជួសជុលជាបន្តបន្ទាប់ដើម្បីធានាថា ប្រាង្គប្រាសាទទាំងនោះនឹងលែងប្រឈមនឹងគ្រោះថ្នាក់ ហើយរក្សាបានគង់វង្សតទៅ។ ក្នុងបរិបទការងារដូចពោលខាងលើនេះហើយ ទើបរយៈពេល ១០ឆ្នាំក្រោយ គឺនៅឆ្នាំ២០០៤ គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ប្រកាសជាឱឡារិកថា រមណីយដ្ឋានអង្គរលែងជាបេតិកភណ្ឌពិភពលោកដែលប្រឈមនឹងគ្រោះថ្នាក់ទៀតហើយ។

ដោយសម្គាល់ឃើញការវិវត្តដ៏ឆាប់រហ័សនៃសកម្មភាពជួសជុលសង្គ្រោះបន្ទាន់ នៃប្រាង្គប្រាសាទក្នុងរមណីយ-ដ្ឋានអង្គរ សន្និសីទអន្តររដ្ឋាភិបាលដើម្បីអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ រៀបចំជាលើកទី២ នៅថ្ងៃទី១៥ នៃវិច្ឆិកា ឆ្នាំ២០០៤ បានផ្តល់អនុសាសន៍សំខាន់ៗ ដោយផ្តោតជាពិសេសលើការរៀបចំផែនការគ្រប់គ្រង

- ការងារអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌។
- ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ដីធ្លី និងសហគមន៍ ជាពិសេសសបង្កើតសួនច្បារ ថ្នាលបណ្តុះកូនឈើ ដាំដើមឈើឡើងវិញដើម្បីការពារបរិស្ថាននិងទេសភាពវប្បធម៌។
- បង្កើនការរៀបចំសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗដែលចាំបាច់ដូចជា ផ្លូវ ថ្នល់ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ។
- ការងារបណ្តុះបណ្តាល ស្រាវជ្រាវ ផ្សព្វផ្សាយ និងសហប្រតិបត្តិការជាតិ-អន្តរជាតិ។
- លើកកម្ពស់ជីវភាពតាមរយៈការបណ្តុះបណ្តាល។
- ការពារការលួចសំណង់បុរាណក្នុងតំបន់សៀមរាបអង្គររួមមាន វត្ថុដែលមានលក្ខណៈប្រវត្តិសាស្ត្រ លំនៅដ្ឋានបុរាណ និងការលក់សំណង់ស្ថាបត្យកម្មបុរាណដែលមានតម្លៃបេតិកភណ្ឌ។

## ការអភិវឌ្ឍធនធានមនុស្ស

ដើម្បីធានាឲ្យបាននូវនិរន្តរភាពនិងជោគជ័យក្នុងកិច្ចការពារ អភិរក្ស និងលើកតម្លៃបេតិកភណ្ឌពិភពលោកអង្គរ អាជ្ញាធរជាតិអប្សរាបានកំណត់នូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាច្រើន ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងទៅអនាគតដូចជា៖

- ស្វែងរកធនធាន និងបច្ចេកទេសពីដៃគូអន្តរជាតិក្នុងការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក និងសហគមន៍។ ការបណ្តុះបណ្តាលចំណេះដឹង គឺបានអនុវត្តជាក់ស្តែងតាមការដ្ឋាននៃគម្រោងរបស់ដៃគូអន្តរជាតិជាច្រើនដែលកំពុងអនុវត្ត។
- ធ្វើការអភិវឌ្ឍចំណេះដឹងបុគ្គលិកឲ្យស្របទៅតាមស្ថានភាពវិវឌ្ឍន៍ ដែលតម្រូវឲ្យមានជំនាញបច្ចេកទេស បច្ចេកវិទ្យា និងចំណេះដឹងពិតប្រាកដសម្រាប់ធ្វើការងារដោយខ្លួនឯងបាននៅពេលអនាគត។
- ធ្វើការជ្រើសរើសបុគ្គលិកដែលមានគុណភាព ជាពិសេសផ្តល់ឱកាសជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់បេតិកភណ្ឌអង្គរជាអាទិភាព ដើម្បីជំរុញពួកគាត់ឲ្យចូលរួមក្នុងកិច្ចការពារបេតិកភណ្ឌពិភពលោក ជាកត្តាជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នៃតំបន់អង្គរ។
- រៀបចំកម្មវិធីបណ្តុះបណ្តាល ដោយធ្វើការផ្ទាល់នៅការដ្ឋាន និងបណ្តុះបណ្តាលពីវិធីសាស្ត្រថ្មីៗ ដើម្បីអភិវឌ្ឍន៍ជំនាញឲ្យឆ្លើយតបទៅនឹងការរីកចម្រើននៅតំបន់អង្គរ។
- បង្កើតឲ្យមានកម្មវិធីផ្លាស់ប្តូរការសិក្សាដល់មន្ត្រីបុគ្គលិកថ្នាក់ខ្ពស់សម្រាប់ធ្វើការបណ្តុះបណ្តាលបន្ថែមលើជំនាញដូចជា៖ ផ្នែកបុរាណវិទ្យា ស្ថាបត្យកម្ម វិស្វកម្មសំណង់ស៊ីវិល និងការសិក្សាពីសង្គមជាដើម...។ល។



© APSARA


ប្រាសាទអង្គរវត្ត
© APSARA



© PHANG-MAKARA

## កិច្ចការអភិរក្ស និងជួសជុលនៅប្រាសាទអង្គរវត្ត

អង្គរវត្តជាប្រាសាទដ៏ល្អត្រកាល និងធំជាងគេនៅក្នុងចំណោមប្រាសាទរបស់ខ្មែរទាំងអស់ បានសាងឡើងនៅចំកណ្ដាលរាជធានីអង្គរ នៅរវាងពាក់កណ្ដាលទី១នៃសតវត្សរ៍ទី១២ ក្នុងរជ្ជព្រះបាទសូរ្យវរ្ម័នទី២។ ទម្រង់នៃប្រាសាទទាំងមូល រួមនឹងកសិន្ធុមានទំហំទទឹង១៩០ម៉ែត្រព័ទ្ធជុំវិញផងនោះ បង្កើតបានជាកន្លែងចតុកោណដ៏ធំមួយមានទំហំ១៥០០ម៉ែត្រ គុណនឹង១៣០០ម៉ែត្រ គ្របដណ្ដប់លើផ្ទៃដីប្រមាណជា៩ហិកតា។ លក្ខណៈសំខាន់របស់ប្រាសាទអង្គរវត្ត គឺសំណង់ជាកងសាជីជ្រុងមួយ តួប៉មប្រាំខ្ទង់ផ្កាដែលស្ថិតនៅចំកណ្ដាលរោងទងព័ទ្ធជុំវិញជាច្រើនជាន់។ ការងារជួសជុលនិងពង្រឹងឡើងវិញត្រូវបានដំណើរការឡើងនៅក្នុងគម្រោងអន្តរជាតិដ៏ធំមួយដែលទាក់ទងនឹងក្រុមការងារមកពីប្រទេសសហរដ្ឋអាមេរិក បារាំង អាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន។

ចាប់តាំងពីឆ្នាំ១៩៩៥មក គម្រោងអភិរក្សរូបចម្លាក់ទេពអប្សររបស់ប្រទេសអាល្លឺម៉ង់ (GACP) បាននិងកំពុងអនុវត្តដើម្បីអភិរក្សរូបចម្លាក់ទេពអប្សរ ទេវតា និងគ្រឿងលម្អនៅតាមផ្នែកផ្សេងៗទៀតរបស់ប្រាសាទ។ រូបចម្លាក់ទេវតាប្រមាណជា២០% ស្ថិតក្នុងស្ថានភាពខូចខាតខ្លាំង បណ្ដាលមកពីសំណឹកមីក្រូសារពាង្គកាយ និងការជួសជុលមិនបានប្រសើរនាពេលអតីតកាល ដែលប្រការទាំងអស់នេះបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅលើរូបចម្លាក់ទាំងនោះ។ ក្នុងការអនុវត្តការងារដ៏ប៉ិនប្រសប់និងលំបាកនេះ អង្គការគម្រោងអភិរក្សរូបចម្លាក់ទេពអប្សររបស់ប្រទេសអាល្លឺម៉ង់ បានធ្វើការវិភាគដ៏ជាក់លាក់ឥតខ្ចោះ ដោយប្រើវិធីសាស្ត្រសម្របសម្រួល និងព្យាបាល ដែលអាចជួយឲ្យចម្លាក់ទាំងនោះអាចរួចផុតពីការប្រឈមបានទាន់ពេលវេលា។



ការជួសជុលរោងទងគូរសមុទ្រទឹកដោះបានបញ្ចប់ក្នុងឆ្នាំ ២០១៦ © WMF

ឆ្នាំ២០០៨ គម្រោងមូលនិធិប្រាសាទពិភពលោក(WMF) របស់សហរដ្ឋអាមេរិកសហការជាមួយអាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលដំបូលរោងទងគូរសមុទ្រទឹកដោះ ក្នុងបំណងធំ គឺការពារជម្រាបទឹកដែលហូរស្រក់ពីផ្នែកដំបូលរោងទងមកលើជញ្ជាំងដែលនាំឲ្យមានការខូចខាត និងពុកផុយដល់ចម្លាក់ផ្ទៃរឿងនៅលើជញ្ជាំង។ គម្រោងនេះមានរយៈពេល៤ឆ្នាំសម្រាប់ការជួសជុលផង និងបណ្ដុះបណ្ដាលដល់អ្នកបច្ចេកទេសខ្មែរជំនាញវិស្វករ ពិសេសដល់ពលករ ដើម្បីទទួលនូវបទពិសោធន៍គ្រប់គ្រាន់លើផ្នែកអភិរក្ស និងជួសជុលបេតិកភណ្ឌផង។



ការជួសជុលរោងទងគូរសមុទ្រទឹកដោះ © WMF

ស្ថាប័ន ហៅកាត់ថា J.S.A របស់រដ្ឋាភិបាលជប៉ុនដែលជាជំនួយសម្រាប់កិច្ចការអភិរក្ស និងជួសជុលប្រាសាទមានវត្តមាននៅអង្គរនាឆ្នាំ១៩៩៤ ហើយគម្រោងនេះស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរវាងអង្គការយូណេស្កូ ជប៉ុន-អាជ្ញាធរជាតិអប្សរា។



បណ្ណាល័យខាងជើង ផ្នែកខាងក្នុងប្រាសាទអង្គរវត្តឆ្នាំ ២០០០

© HUM-RITHY






## គម្រោងជួសជុលស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត

ស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត បានទទួលការជួសជុលមួយផ្នែកត្រង់តែមខាងត្បូងដោយសាលាបារាំង (EFEO) នៅឆ្នាំ១៩៥៤។ ចំណែកស្ថាប័នសូហ្វីយ៉ា នៃប្រទេសជប៉ុនសហការជាមួយអាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលរួចរាល់ស្ពានហាលប្រវែង១០០ម៉ែត្រផ្នែកខាងកើត ចន្លោះឆ្នាំ១៩៩៦ដល់២០០៧។ បច្ចុប្បន្នអាជ្ញាធរជាតិអប្សរា កំពុងរៀបចំគម្រោងជួសជុលស្ពានហាលសម្រាប់ឆ្នាំ២០១៦ ដល់២០២០ ដោយសហការផ្នែកបច្ចេកទេសជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា។ យោងតាមអនុសាសន៍របស់ក្រុមអ្នកជំនាញអាដហុក អាយស៊ីស៊ីអង្គរ លើកទី២៤នាខែធ្នូ ឆ្នាំ២០១៧។ យោងតាមការធ្វើសាកល្បងជួសជុលជញ្ជាំងស្ពានហាលប្រវែង៤ទៅ៥ម៉ែត្រដំបូង និងមិនតម្រូវឲ្យរុះរើថ្មជញ្ជាំងណាមួយឡើយ។



កិច្ចការជួសជុលចម្រឹងបង្អួចនៅពេងទី២ (ខាងក្នុង ប៉ែកខាងត្បូង-លិច)

## ចម្រឹងបង្អួចនៅប្រាសាទអង្គរវត្ត

ស្ថានភាពចម្រឹងបង្អួចទាំងអស់នៅប្រាសាទអង្គរវត្ត ពុំមានភាពរឹងមាំទេ ដោយចម្រឹងខ្លះពុកផុយ ខ្លះសឹករិចរិលរបេះធ្លាក់ដោយអន្ទ្រា ឯខ្លះទៀតបានបាក់ និងបាត់បង់ទាំងស្រុង។ សម្រាប់ចម្រឹងបង្អួចនៅពេងទី២ (ផ្នែកខាងក្នុង) គឺមានស៊ុមបង្អួចសរុបចំនួន១៤៩ស៊ុម មានចម្រឹង១០៣៩ ក្នុងនោះចម្រឹងបាត់បង់មានចំនួន២៥០ចម្រឹង។ ក្រុមអ្នកជំនាញខ្មែរនៃអាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់ជួសជុលរួចនូវចម្រឹងបង្អួចស្ថិតនៅពេងទី២ខាងក្នុងប៉ែកខាងត្បូងកាលពីខែមីនា ឆ្នាំ២០១៥ កន្លងទៅ។







## ជួសជុលច្រាំងកសិន្ធុ នៃប្រាសាទអង្គរវត្ត (២០០៤-២០១៧)

ថ្មច្រាំងកសិន្ធុប្រាសាទអង្គរវត្តរងការខូចខាតស្ទើរទាំងស្រុង ក្នុងនោះដុំថ្មទាំងអស់បានរលុះចូលទៅក្នុងកសិន្ធុទឹក ដោយសារការបាក់ស្រុតរចនាសម្ព័ន្ធសំណង់ និងការឡើងចុះមិនទៀងទាត់នៃទឹកក្នុងកសិន្ធុតាមរបបទឹកភ្លៀងប្រចាំឆ្នាំ។ កន្លងមកច្រាំងកសិន្ធុបានជួសជុលពីស្ថាប័នជាតិ និងអន្តរជាតិច្រើនដំណាក់កាល ដូចជាអង្គការ I.Ge.S នៃប្រទេសអ៊ីតាលី បានជួសជុលច្រាំងកសិន្ធុចំនួន២កន្លែងផ្សេងគ្នា គឺចន្លោះឆ្នាំ២០០១ដល់ឆ្នាំ២០១៤ ដែលមានប្រវែងសរុប១៤០ម៉ែត្រ។ ចំណែកអាជ្ញាធរជាតិអប្សរាបានជួសជុលច្រាំងប្រវែង៤០ម៉ែត្រក្នុងឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៧ ក្នុងនោះ ថ្មរាយប៉ាយ និងបាក់បែកមួយចំនួនបានម្រម៉ែម្រមូលដើម្បីប្រើប្រាស់ក្នុងការជួសជុលឡើងវិញ ។


ប្រាសាទបាយ័ន្ត
© PHANG MAKARA



© JASA

## ការជួសជុលប្រាសាទបាយ័ន្ត

ប្រាសាទបាយ័ន្តស្ថិតនៅចំកណ្តាលបេះដូងនៃរាជធានីអង្គរធំ បានសាងឡើងជាច្រើនដំណាក់កាល (ចាប់ផ្តើមក្នុងរវៀងឆ្នាំ១២០០ ដោយព្រះបាទជ័យវរ្ម័នទី៧) ហើយជាមួយនឹងការកែប្រែ និងពង្រីកបន្ថែមផ្សេងៗទៀត បានធ្វើឲ្យប្រាសាទនេះមានលក្ខណៈពិសេសតំណាងដោយរចនាបថស្ថាបត្យកម្មតែមួយគត់។ ជាប្រាសាទភ្នំសាងពីថ្មភក់ មានរូបរាងខុសប្លែកពីគេ ដោយសារតួប៉មចំនួន៣៧ ដែលភាគច្រើនឆ្លាក់ជារូបមុខបួន បែរទៅកាន់ទិសសំខាន់ៗទាំងបួន។ យ៉ាងណាក៏ដោយ ប្រាសាទបាយ័ន្តគឺជាប្រាសាទមួយទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ និងពិបាកជួសជុលជាទីបំផុត។ កិច្ចការជួសជុលបានចាប់ផ្តើមអន្តរាគមន៍ជាបន្ទាន់នៅហោត្រៃពីរនៅជាប់នឹងខ្លោងទ្វារចូលប្រាសាទ ដោយបានរក្សាសម្ភារៈដើមរបស់សំណង់បានជាច្រើន និងប្រើវិធីសាស្ត្រសាងសង់ តាមរបៀបបុរាណ ដោយមានការយល់ព្រមពីគម្រោងគាំពារអង្គរ ជប៉ុន-អប្សរា (the Japan Apsara Safeguarding Angkor (JASA)) ដែលជាគម្រោងសហការរវាងក្រុមកម្ពុជា តំណាងដោយអាជ្ញាធរជាតិអប្សរា និងក្រុមជប៉ុនមកពីសាកលវិទ្យាល័យ វ៉ាសេដា។

ប្រាសាទបាយ័ន្តក៏បានបង្ហាញឲ្យឃើញផងដែរ អំពីបញ្ហានៃប្រព័ន្ធបង្ហូរទឹក ហើយកិច្ចការជួសជុលនេះក៏បានអនុវត្តក្នុងគោលបំណងការពារកុំឲ្យមានទឹកជ្រាបចូលក្នុងគ្រឹះរបស់ខឿនប្រាសាទទៀត ដើម្បីកាត់បន្ថយបរិមាណសំណើមនៅក្នុងជញ្ជាំងកំពែងចម្លាក់រឿង។

ការសិក្សាពីកូតត្ថសាស្ត្រ ក៏បានបង្ហាញអំពីគម្រោងការពង្រីងអណ្តូងស្ថិតនៅក្នុងតួប៉មកណ្តាលនៃប្រាសាទបាយ័ន្តមុនពេលយកបដិមាព្រះពុទ្ធ ដែលជានិមិត្តរូបដ៏សំខាន់របស់ប្រាសាទមកដាក់នៅទីតាំងដើមឡើងវិញ។



© JASA



ការជួសជុលបណ្ណាល័យខាងជើង

© JASA



© ROEURM-SOPHALLA

ចន្លោះឆ្នាំ១៩៩៤-២០០៥ កិច្ចការអភិរក្សនិងជួសជុលប្រាសាទបាយ័ន្តស្ថិតនៅក្រោមគម្រោងរបស់អង្គការ JSA នៃប្រទេសជប៉ុន" Japanese Government Team for Safeguarding Angkor"។ គម្រោងក្នុងដំណាក់កាលទី១ ១៩៩៤ ដល់ ១៩៩៩ បានជួសជុលបណ្ណាល័យផ្នែកខាងជើង និងដំណាក់កាលទី២ ១៩៩៤ ដល់ ២០០៥ ជួសជុលបណ្ណាល័យខាងជើងផ្នែកខាងក្រៅនៃប្រាសាទអង្គរវត្ត ជួសជុលប្រាសាទសួព្រ័ត្រ (N1) ខ្លោងទ្វារចូល (N2) និងរោងទងខាងក្រៅផ្នែកខាងកើតប្រាសាទបាយ័ន្ត។ បន្ទាប់មកគម្រោង JSA បានផ្លាស់ប្តូរទៅជា JASA (២០០៦-២០១៦) "JAPAN-APSARA-Safeguarding- Angkor" ក្នុងទម្រង់សហប្រតិបត្តិការរវាងអង្គការ JSA យូណេស្កូ និងអាជ្ញាធរជាតិអប្សរា។ ដំណាក់កាលទី៣នៃគម្រោង ( ២០០៥ -២០១១) បានធ្វើការជួសជុលឡើងវិញនូវបណ្ណាល័យផ្នែកខាងត្បូងប្រាសាទបាយ័ន្តនិងសិក្សាស្ថានភាពលំនឹងនៃប៉មធំកណ្តាលបាយ័ន្ត។ ចំណែកដំណាក់កាលទី៤ (២០១១-២០១៦) បន្តរៀបចំបរិវេណ និងជួសជុលចេតិយតូបនៅច្រកចូលខាងកើតនៃប្រាសាទបាយ័ន្ត ដោយរួមបញ្ចូលទាំងសិក្សានូវបច្ចេកទេសថែទាំការពារចម្លាក់ស្ថិតតាមជញ្ជាំងខាងក្នុងនៃរោងទងខាងក្នុងផង។



© JASA



កំពែងទីក្រុងអង្គរធំ ជាសំណង់បេតិកភណ្ឌដែលធ្វើពីថ្មបាយក្រៀម មានរាងបួនជ្រុងមានប្រវែងសរុប១៦គីឡូម៉ែត្រ ដែលមួយជ្រុងៗមានប្រវែង៣គីឡូម៉ែត្រ កំពែងនេះមានកម្ពស់ប្រហែល៨ម៉ែត្រទៅ៩ម៉ែត្រ ដោយសារពីតាំងពីយូរឆ្នាំ ការបាក់បែកថ្មបាយក្រៀមបាន១៩០០ប្រមាណ ចាប់ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៨ កំពែងទីក្រុងអង្គរធំ ត្រូវបានជួសជុលដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរាប្រវែង៩៣ម៉ែត្រ បើគិតជាទីតាំងមាន៦ទីតាំង ក្នុងចំណោម២០ទីតាំង

© APSARA

## ការជួសជុលប្រាសាទភ្នំបាខែង

ដំណាក់កាលទី១ (២០០៤-២០០៨) សម្រាប់ការសិក្សារៀបចំផែនការគោល និងគម្រោងសាកល្បង ដើម្បីជួសជុលថ្មជ្រុង និងគែមនៃប៉មពីរ៉ាមីតៗ ដំណាក់កាលទី២ (២០០៩-២០១៦) បានធ្វើការជួសជុលប្រាសាទឥដ្ឋលេខ១០ ដែលមានមន្ត្រីជំនាញខាងជួសជុលឥដ្ឋមកពីអាជ្ញាធរជាតិអប្សរា ដើម្បីអនុវត្តសម្រេចកិច្ចការនេះនៅចុងឆ្នាំ២០១៦។

គម្រោងផែនការអភិរក្ស និងជួសជុលប្រាសាទភ្នំបាខែង កំពុងបន្តជួសជុលកន្លែងខូចខាតស្ថិតនៅតាមរូតទីមួយៗ ផ្នែកខាងកើត ត្រង់ថ្មគម្រាលកូនប្រាសាទថ្ម ជួសជុលរចនាសម្ព័ន្ធថ្មដែលលេះបាក់ស្ថិតនៅតាមជ្រុងកែង និងពង្រឹងថ្មជញ្ជាំងប្រាសាទទៅនឹងថ្មភ្នំជាដើម។



ជ្រុងឦសាន-ភ្នំបាខែង





## ប្រាសាទបាពួន

ប្រាសាទបាពួន ជាប្រាសាទដ៏ធំសម្បើមមួយសាងឡើងនៅពាក់កណ្តាលសតវត្សរ៍ទី១១ ដែលមានសាជីធំមួយជាភ្នំថ្នាក់ៗប្រាំជាន់កម្ពស់២៥ម៉ែត្រ និងទំហំបាត១៣០ម៉ែត្រ គុណនឹង១០៤ម៉ែត្រ។ ក្រោមការដឹកនាំដោយលោក B. P. Groslier ជាបុរាណវិទូនៃសាលាបារាំងចុងបូព៌ាប្រទេស (EFEO) និងលោក Jacques Dumarcay ជាស្ថាបត្យករ បានធ្វើការជួសជុលប្រាសាទបាពួន ដោយប្រើប្រាស់វិធីសាស្ត្រអាណាស្ទីឡូ ជាលើកដំបូងដើម្បីពង្រឹងគ្រឹះប្រាសាទដ៏ធំនេះ ហើយបន្ទាប់មកក៏បានជួសជុលថ្មកក់យកមកដាក់ឲ្យដូចនឹងស្ថានភាពដើមរបស់គ្រឹះវិញ។ ផ្នែកខ្លះនៃការជួសជុលនេះ បានបញ្ចប់ជាស្ថាពរ ហើយពេលក្រោយៗមកទៀត គំរូនៃការជួសជុលនេះ គឺជាវិធីសាស្ត្រមានលក្ខណៈសមរម្យសម្រាប់ការនាំជួសជុលថ្មយកទៅដាក់តាមទីតាំងដើមនីមួយៗរបស់សំណង់វិញ។ កិច្ចការនេះបានបន្តអនុវត្តអស់រយៈ១៦ឆ្នាំដោយលោក Pascal Royère ជាស្ថាបត្យករមកពីសាលាបារាំងចុងបូព៌ាប្រទេស ដែលបានធ្វើឲ្យប្រាសាទទាំងមូលមានលំនឹងឡើងវិញ ព្រមទាំងបានអភិរក្សទុកនូវដំណាក់កាលសំខាន់ៗទាំងពីររបស់ប្រវត្តិប្រាសាទ គឺសម័យកាលទាក់ទងនឹងព្រហ្មញ្ញសាសនា ជាពិសេសគឺរូបចម្លាក់នៅតាមជញ្ជាំងរៀបរាប់ពីរឿងរាមកេរ្តិ៍ និងសម័យកាលពុទ្ធសាសនា មានរូបព្រះពុទ្ធចូលព្រះនិព្វាន។







ប្រាសាទបាពួន




## ការងារអភិរក្សនិងជួសជុលប្រាសាទតាព្រហ្ម

តាមពិត ប្រាសាទតាព្រហ្ម គឺជាពុទ្ធវិហារព្រះពុទ្ធសាសនា និងជាប្រាសាទមួយក្នុងចំណោមប្រាសាទសំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧ សាងឡើងនៅចុងសតវត្សរ៍ទី១២ដល់ដើមសតវត្សរ៍ទី១៣។ ការងារអភិរក្សនៅប្រាសាទតាព្រហ្មបានប្រឈមនឹងបញ្ហាធ្ងន់ធ្ងរជាច្រើនដែលបង្កឡើងដោយសារលក្ខខណ្ឌបរិស្ថាននៅជុំវិញប្រាសាទនេះ។ វិធីសាស្ត្រច្រើនប្រភេទត្រូវបានអនុវត្តសម្របសម្រួលបញ្ចូលគ្នាដើម្បីការពារ និងជួសជុលប្រាសាទទាំងមូល។ អង្គការស្រាវជ្រាវបុរាណវិទ្យានៃប្រទេសឥណ្ឌា (Archaeological Survey of India) បានចងក្រងឯកសារលម្អិតអំពីថ្ម និងសមាសធាតុធម្មជាតិផ្សេងៗរបស់ប្រាសាទទាំងមូល ជាពិសេសដើមឈើ។ ការព្យាបាលដ៏ពិសេសមួយត្រូវបានអនុវត្តទៅលើស្រទាប់ដីផ្នែកខាងក្រោមនិងនៅក្នុងគ្រឹះ ហើយបានរៀបថ្មផ្នែកខាងក្រោមឡើងវិញនិងដកម្រាលថ្មឡើងវិញ។ ទីតាំងអនុវត្តកិច្ចការជួសជុលចំនួន៤ ក្នុងចំណោមទីតាំង៥ បានបញ្ចប់ជាស្ថាពរ។ ឫសឈើព័ទ្ធជុំវិញថ្មប្រាសាទបានរួមចំណែកបង្កើតឲ្យមានសម្រស់ពិសេសមួយនៅក្នុងប្រាសាទនេះ ដែលជាហេតុផលមិនអនុញ្ញាតឲ្យមានការពង្រឹង និងជួសជុលគ្រប់ទីតាំងខូចខាតទាំងអស់នៅក្នុងប្រាសាទនេះបានឡើយ គឺត្រូវរក្សាស្ថានភាពធម្មជាតិរបស់វាជាបន្តទៀត មានន័យថា ទិដ្ឋភាពទាំងនេះគឺជាលទ្ធផលនៃការបាក់បែកខូចខាតជាច្រើនសតវត្ស។


មុនពេលជួសជុល © ASI


ក្រោយពេលជួសជុល © ASI


មុនពេលជួសជុល © ASI


ក្រោយពេលជួសជុល © ASI


មុនពេលជួសជុល © ASI


ក្រោយពេលជួសជុល © ASI


មុនពេលជួសជុល
© EFEO


ក្រោយពេលជួសជុល
© ROEURM-SOPHALLA

## ការជួសជុលអភិរក្ស ប្រាសាទចៅសាយទេវតា

នៅដើមសតវត្សទី២០ សាលាបារាំងចុងបូព៌ាប្រទេស ធ្លាប់បានធ្វើការបោសសម្អាត ចាត់វិធានការសង្គ្រោះ និងជួសជុលប្រាសាទចៅសាយទេវតាឲ្យផុតពីគ្រោះថ្នាក់ ហើយបានធ្វើការជួសជុលគោបុរៈខាងលិចនៃប្រាសាទ។ មុនពេលក្រុមការងាររដ្ឋាភិបាលចិនសម្រាប់អភិរក្សរមណីយដ្ឋានអង្គរ ចូលរួមក្នុងគម្រោងនេះក្នុងចំណោមសំណង់ប្រាសាទទាំង៩នៃប្រាសាទចៅសាយទេវតា ក្រៅពីគោបុរៈខាងលិចដែលមានលក្ខណៈល្អពេញលេញ ផ្នែកផ្សេងទៀតមានស្ថានភាពខូចខាតកម្រិតធ្ងន់ធ្ងរ។ ក្រុមការងារបានធ្វើការជួសជុលប្រាសាទចៅសាយទេវតាដោយបែងចែកជាពីរដំណាក់កាល រួមមានការអង្កេតសម្រាប់ដំណាក់កាលដំបូង និងការជួសជុលដំណាក់កាលក្រោយៗ។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ ក្រុម CSA បានចាប់ផ្តើមការងារត្រួតពិនិត្យ និងគូសវាស់វែងលើស្ថានភាពជាក់ស្តែងនៃសំណង់ប្រាសាទចៅសាយទេវតា ហើយបានអនុវត្តការស្រាវជ្រាវជាច្រើនលើផ្នែកប្រវត្តិសាស្ត្របុរាណវិទ្យា ការអង្កេតភូគព្ភសាស្ត្រ ការអភិរក្សថ្មស្ថាបត្យកម្ម និងរចនាបថ។ល។

មូលហេតុដែលធ្វើឲ្យប្រាសាទចៅសាយទេវតាបែកបាក់ទ្រង់ទ្រាយធំ ក្រៅពីការបំផ្លាញដោយសកម្មភាពមនុស្សនិងមិនបានជួសជុលច្រើនឆ្នាំហើយក៏ពាក់ព័ន្ធផងដែរនិងគ្រឹះសំណង់ប្រាសាទ វិធីសាងសង់ប្រាសាទ ការប៉ះពាល់ដោយសារទឹក និងការបំផ្លាញដោយជីវសាស្ត្រ។ យោងតាមស្ថានភាពខូចខាតរបស់ប្រាសាទចៅសាយទេវតា ដកស្រង់តាមបទពិសោធន៍អនុវត្តវិធីសាងសង់វត្ថុដើមឡើងវិញរបស់អ្នកជំនាញបារាំង ព្រមទាំងអនុលោមតាមគតិការអន្តរជាតិស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌និងប្រាសាទបុរាណ និងគោលការណ៍អភិរក្សបេតិកភណ្ឌវប្បធម៌ចិន ក្រុមការងារ CSA បានដាក់ចេញនូវផែនការជួសជុលដែលរួមមាន ៖ការជួយសង្គ្រោះពង្រឹងភាពរឹងមាំនៃប្រាសាទ ការអភិរក្សបេតិកភណ្ឌ និងការជួសជុលចំណុចសំខាន់ៗ។

ជុំវិញសំណង់ប្រាសាទចៅសាយទេវតាមានផ្ទាំងថ្ម និងដុំថ្ម ប្រមាណ៤០០០ដុំ ដែលបានរលំធ្លាក់ចុះពីសំណង់ប្រាសាទនីមួយៗ។ ក្នុងអំឡុងពេលជួសជុល ក្រុមការងារ CSA បានរៀបចំនិងដាក់លេខរៀងសម្រាប់ដុំថ្មទាំងនេះសារឡើងវិញ ហើយបានជួសជុល និងរៀបថ្មទាំងនេះតាមកន្លែងដើមវិញ ព្រមទាំងបានដាក់បំពេញនូវថ្មលើប្រាសាទចៅសាយទេវតាប្រមាណ៣០ ទៅ៤០% ដែលបានបាក់បែកឬបាត់បង់។

ឆ្លងកាត់ការខិតខំប្រឹងប្រែងអស់រយៈពេលជិត១០ឆ្នាំ ស្ថានភាពគ្រោះថ្នាក់នៃប្រាសាទចៅសាយទេវតាត្រូវបានបំបាត់ ផ្ទាំងថ្មដែលបានធ្លាក់លើភាគច្រើនត្រូវបានរៀបដាក់កន្លែងដើមដោយសុវត្ថិភាព ផ្នែកដែលបាក់បែកបានជួសជុល និងធ្វើឲ្យមានលក្ខណៈកាន់តែរឹងមាំ បរិស្ថានជុំវិញប្រាសាទក៏ត្រូវបានដោះស្រាយ និងគ្រប់គ្រងបានល្អ។

ប្រាសាទចៅសាយទេវតា ក្រោយពេលបញ្ចប់ការជួសជុលជាមូលដ្ឋាន បានក្លាយទៅដូចស្ថានភាពដើមវិញ មិនត្រឹមតែរចនាបថសាងសង់ ស្ថាបត្យកម្ម រចនាសម្ពន្ធសំណង់ប្រាសាទ សម្ភារៈសំណង់ និងសិល្បៈសាងសង់ សុទ្ធតែបានរក្សានូវស្ថានភាពដូចដើម។

# គម្រោងជួសជុល ប្រាសាទ ព្រះពិធូ (២០១៤-២០១៨)

គម្រោងអភិរក្ស និងស្តារឡើងវិញសម្រាប់អភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូ គឺបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០១៥។ គម្រោងនេះជាផ្នែកមួយនៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ (ODA) នៃរដ្ឋាភិបាលកូរ៉េ គ្រប់គ្រងដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA និងបានអនុវត្តរួមគ្នារវាងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHF) នៃសាធារណរដ្ឋកូរ៉េ និងអាជ្ញាធរជាតិអប្សរា។

ដំណាក់កាលទី១សម្រាប់គម្រោង គឺកំពុងអនុវត្តជួសជុលលានច្រកចូលខាងលិចរបស់ប្រាសាទដែលមានការចូលរួមសហការពីអ្នកបច្ចេកទេសខ្មែរ និងពលករជំនាញពីអាជ្ញាធរជាតិអប្សរា។

ក្នុងរយៈពេល៨០០ឆ្នាំកន្លងទៅ ក្រុមប្រាសាទព្រះពិធូបានទទួលរងនូវការខូចខាតតាមស្ថានភាពខុសគ្នាជាច្រើន។ មូលហេតុចម្បងៗនៃការខូចខាតរបស់ប្រាសាទខ្មែរទាំងនេះ គឺការបែកបាក់ដែលបណ្តាលមកពីការប្រែប្រួលនៃសណ្ឋានដីនិងអស្ថិរភាពនៃរចនាសម្ព័ន្ធសំណង់។ កត្តាសំខាន់ៗផ្សេងទៀតរួមមានកត្តាអាកាសធាតុរុក្ខជាតិដុះជុំវិញ សត្វល្អិត ការលួចវត្ថុបុរាណខុសច្បាប់ និងសកម្មភាពរបស់មនុស្ស។

ការអភិរក្សសំណង់ប្រាសាទបែកបាក់នៅអង្គរ គឺជាផ្នែកមួយនៃការវិនិយោគប្រើប្រាស់ ដើម្បីការពារបេតិកភណ្ឌរួមរបស់មនុស្សជាតិទាំងមូលតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយបានផ្តើមនៅដើមទសវត្សរ៍១៩៩០ ដោយសហគមន៍អន្តរជាតិដើម្បីថែរក្សា និងអភិរក្សប្រាសាទនៅអង្គរដែលប្រឈមនឹងគ្រោះថ្នាក់។ អ្នកជំនាញបរទេសមកពីជុំវិញពិភពលោក បានធ្វើកិច្ចពិភាក្សារកដំណោះស្រាយដើម្បីអភិរក្សតំបន់នេះ។ ជាលទ្ធផល គឺបង្កើតឲ្យមានការចាប់ផ្តើមកិច្ចការអភិរក្សប្រាសាទ នៅអង្គរហូតក្លាយជាគំរូនៃការអភិរក្សបេតិកភណ្ឌវប្បធម៌តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការចូលរួមរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់គម្រោងជួសជុលប្រាសាទព្រះពិធូបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការចូលរួមចំណែកសហប្រតិបត្តិការជាអន្តរជាតិ ក្នុងទិសដៅកិច្ចការអភិរក្សបេតិកភណ្ឌ។ ប្រទេសនេះក៏បានប្តេជ្ញាចិត្តផងដែរ ក្នុងការវិនិយោគប្រើប្រាស់លើការអភិរក្សសម្បត្តិវប្បធម៌សំខាន់ៗនៅក្នុងសកលលោក។





# ការជួសជុលបង្កាន់ដៃនាគជ្រុងនិរតី ប្រាសាទបន្ទាយស្រី(២០១៤-២០១៧)

ស្ថានភាពបច្ចុប្បន្ននៃបង្កាន់ដៃនាគ ប្រាសាទបន្ទាយស្រី បង្ហាញនូវភាពទ្រុឌទ្រោមខ្លាំងជាច្រើនកន្លែងពោល គឺបង្កាន់ដៃនាគខ្លះរលុះបាក់ជាកំណាត់ៗ ខ្លះសឹករេចរឹល ប្រេះ និងរបេះជាស្រទាប់ៗ។ រាល់ចំណុចខូចខាតទាំងអស់ គឺក្រុមអ្នកបច្ចេកទេសអភិរក្សថ្មរបស់អាជ្ញាធរជាតិអប្សរា បានធ្វើការជួសជុលពង្រឹងឡើងវិញរួចរាល់មួយចំនួនដូចជាជួសជុលបង្កាន់ដៃនាគជ្រុងនិរតី(២០១៦)បង្កាន់ដៃនាគជ្រុងពាយ័ព្យ ក្នុងខែសីហា ឆ្នាំ ២០១៧ និងជួសជុលចម្លាក់ផ្តែរស្ថិតនៅខាងជើង និងខាងត្បូងនៃប៉មកណ្តាលក្នុងឆ្នាំ ២០១៦។











រចនាសម្ពន្ធនៃខ្លោងទ្វារខាងកើតរួមមាន ថ្ពែរ សសរពេជ្រ និងសសរផ្ដោបរបស់ប៉មឥដ្ឋលេខ៨ប្រាសាទបាគង បានលំរបាក់នៅក្នុងខែតុលា ឆ្នាំ២០០៩កន្លងទៅ ក្នុងស្ថានភាពពេលមានភ្លៀងខ្លាំង ដោយរៀបចំជួសជុល និងតភ្ជាប់បំណែកថ្ពែរដែលបានបាក់ជាកំណាត់ៗ ដែលមានទម្ងន់សរុបចំនួន៤តោន។ បន្ទាប់ពីជុសជុលរួចរាល់ ផ្នែកនេះត្រូវបានយកទៅដាក់នៅកន្លែងដើមវិញ។ ឯរចនាសម្ពន្ធថ្មផណ្ដើរ សសរផ្ដោបទាំងពីរ កម្រាលខឿនឥដ្ឋ បានតម្រូវឲ្យមានការជួសជុលពង្រឹងឡើងវិញទាំងស្រុង។



ប៉មឥដ្ឋលេខ៦ គឺស្ថិតនៅបរិវេណខាងលិចផ្នែកខាងជើងនៃប៉មធំកណ្ដាលប្រាសាទបាគង។ ប៉មនេះមានស្ថានភាពឥដ្ឋពុកផុយ និងលេះឥដ្ឋខ្លាំង។ ដើមឈើ និងឫសឈើបានចាក់ស្រេះចូលក្នុងស្រទាប់ឥដ្ឋបង្កឲ្យមានការលេះជុំឥដ្ឋដោយអន្ទើ។ ប៉មទាំងមូលបានធ្វើការពង្រឹង និងជួសជុលឡើងវិញក្នុងឆ្នាំ២០១៥ ហើយបញ្ចប់នៅចុងឆ្នាំ២០១៧។ ការជួសជុលធ្វើឡើងដោយផ្នែកៗនៅត្រង់ទីតាំងដែលការខូចខាតប៉ុណ្ណោះ ព្រមទាំងបិទក្ដិតប្រហោងរន្ធតូចៗនៅលើជញ្ជាំង។



[illegible]



© PHANG-MAKARA



© GACP



© GACP

## គម្រោងជួសជុលប្រាសាទព្រះគោ

គម្រោងឈ្មោះ RAF(The Royal Angkor Foundation បានផ្តើមកិច្ចការអភិរក្ស និងជួសជុលប៉មប្រាសាទព្រះ-គោនៅក្នុងខែមករា ឆ្នាំ១៩៩៤ រហូតដល់ឆ្នាំ១៩៩៦។ ក្នុងកំឡុងឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ អង្គការអន្តរជាតិរបស់ប្រទេសអាល្លឺម៉ង់ GACP បន្តកិច្ចការជួសជុលនេះ ដែលលទ្ធផលនៃដំណាក់កាលជួសជុលនីមួយៗ រួមមានៈ ជួសជុលថ្មកម្រាលខឿន ពង្រឹងសសរផ្តោបលើប៉មទាំងប្រាំមួយ សង់សសរផ្តោបថ្មីនៅប៉មធំកណ្តាលខាងកើត និងខាងលិច។

ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបច្ចេកទេស (អាយ-ស៊ីស៊ី-អង្គរ) ឆ្នាំ១៩៩៩បានផ្តល់អនុសាសន៍ឲ្យមានការបន្តជួសជុលបន្ថែម លើរចនាសម្ព័ន្ធឥដ្ឋប្រាសាទព្រះគោ។ គម្រោងនេះ ចាប់ផ្តើមជួសជុលប៉មធំកណ្តាលខាងកើត នៅដើម ខែសីហា ឆ្នាំ២០០១ ហើយបានបញ្ចប់នៅ ក្នុងខែធ្នូ ឆ្នាំ២០០៧។ លទ្ធផលនៃការជួសជុលរចនាសម្ព័ន្ធឥដ្ឋនៅប្រាសាទព្រះគោ ដូចជា ជួសជុលប៉មធំកណ្តាលខាងកើត សង់សសរពេជ្រថ្មី១ដើមដំឡើងនៅខ្លោងទ្វារខាងកើតនៃប៉មជ្រុងពាយ័ព្យពង្រឹងសសរពេជ្រចំនួន២ដើម នៅខ្លោងទ្វារខាងកើតនៃប៉មកណ្តាលខាងលិចសង់សសរពេជ្រថ្មី១ដើម ដំឡើងនៅខ្លោងទ្វារបញ្ឆោតខាងត្បូងនៃប៉មជ្រុងអាគ្នេយ៍ជួសជុលឥដ្ឋជ្រុងនិរតីនៃប៉មអាគ្នេយ៍ ពង្រឹងសសរពេជ្រអំពីឥដ្ឋនៅប៉មកណ្តាលខាងលិច និងប៉មជ្រុងពាយ័ព្យ។

បណ្ណាល័យជ្រុងអាគ្នេយ៍នៃប្រាសាទព្រះគោត្រូវបានជួសជុលពង្រឹងឡើងវិញក្នុងគម្រោងឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ ជញ្ជាំងឥដ្ឋផ្នែកខាងកើត ខាងលិច ខាងត្បូង ខាងជើង និងរូតកំពូលនៃបណ្ណាល័យនេះ បានជួសជុលរួចរាល់ជាស្ថាពរ។ រាល់ដំណើរការអនុវត្តគម្រោង គឺជាការចំណាយ និងទទួលបន្ទុកទាំងស្រុងពីអាជ្ញាធរជាតិ-អប្សរា រួមទាំងអ្នកបច្ចេកទេស និងពលករជំនាញខ្មែរ។



© APSARA



## ការជួសជុលព្រះវិហារវត្តបូណ៌

*រមណីយដ្ឋានអង្គរ ក្រៅពីប្រាង្គប្រាសាទ បុរាណដ្ឋាន ទួលបុរាណ នៅមានវត្តអារាមមួយចំនួននៅសេសសល់មកដល់បច្ចុប្បន្ន។ វត្តអារាមទាំងនោះមានវ័យចំណាស់ស្ថិតនៅតាមដងស្ទឹងសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ដូចជាវត្តរាជបូណ៌ វត្តអារញ្ញសាគរជាដើម។ វត្តអារាមជាសំណង់បែបព្រះពុទ្ធសាសនា បន្ទាប់ពីប្រជាជនខ្មែរផ្លាស់ប្តូរពីព្រហ្មញ្ញសាសនាមកព្រះពុទ្ធសាសនា នាសម័យកណ្តាល និងបន្តរហូតមកដល់សព្វថ្ងៃ។*

វត្តបូណ៌ ឬវត្តរាជបូណ៌ បានសាងសង់ឡើងក្នុងរវាងឆ្នាំ១៦៥០មានអាយុកាលជាង៥០០ឆ្នាំមកហើយ ជាវត្តមួយក្នុងចំណោមវត្តដែលមានវ័យចំណាស់បំផុត ជាបូជនីយដ្ឋាន និងបុរាណដ្ឋានដ៏ល្បីនៅក្នុងខេត្តសៀមរាប។ រចនាបថនៃព្រះវិហារ គំនូរ ព្រះពុទ្ធបដិមា រចនាសម្ព័ន្ធសំណង់ល-និង-ល រាប់ពីដំបូល តួព្រះវិហារ គ្រឹះហោជាង សន្លឹកទ្វារ សន្លឹកបង្អួច បល្ល័ង្ក សសរ ពណ៌ គឺសុទ្ធតែជាទីចាប់អារម្មណ៍បំផុតសម្រាប់ទេសចរអ្នកស្រាវជ្រាវជាតិ-អន្តរជាតិ។

វត្តបុរាណមួយនេះ បានរក្សានូវភាពដើមនៃស្ថាបត្យ-កម្ម គំនូររឿងរាមកេរ្តិ៍នៅលើជញ្ជាំង រួមទាំងមានចម្លាក់ក្បាច់ធ្វើពីស៊ីម៉ងត៍ និងឈើនៅតាមបង្អួច ទ្វារ និងដំបូលព្រះវិហារគួរឲ្យស្ញប់ស្ញែង។ ចំណែកគំនូរសំខាន់ៗនៅលើជញ្ជាំងផ្នែកខាងក្នុងព្រះវិហារ ប្រហែលជាគូរនៅដើមសតវត្សទី២០ ដោយជាងគំនូរតាប៉ិល និងក្មួយរបស់គាត់ឈ្មោះ គង់ និត។ វិចិត្រករទាំងពីររូបនេះ ជាអ្នករចនាល្ខោនស្បែកធំ ដែលធ្វើឲ្យរូបគំនូរទាំងនេះមានភាពដូចគ្នានឹងកាយវិការរបស់ល្ខោនស្បែកធំដែរ។ ភាពអស្ចារ្យនៃក្បូរ-ក្បាច់រចនាដ៏ល្អពិចិត្រនៃសំណង់ ចម្លាក់ គំនូរទាំងនោះ ត្រូវបានខូចខាត និងបាត់បង់សោភ័ណភាពដើមដោយអធ្វើនៅកន្លែងខ្លះដោយសារអាកាសធាតុ អាយុកាល ការធ្វើថ្មីការប្រះស្រាំ ធ្លុះ និងផ្សែងធូបទៀនជាដើម ពិសេសផ្នែកដំបូលព្រះវិហារដែលមានសភាពចាស់ទ្រុឌទ្រោមៗ ដូច្នេះហើយទើបអាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុលព្រះវិហារនេះក្នុងបំណងអភិរក្ស និងលើកតម្លៃវប្បធម៌នៃសិល្បៈរបស់ខ្មែរនាបុរាណកាលឲ្យរស់រវើកនាពេលបច្ចុប្បន្នឡើងវិញ ដើម្បីរក្សាបាននូវភាពយូរអង្វែងនៃស្ថាបត្យកម្មដ៏វិចិត្រមួយនេះ។

កិច្ចការអភិរក្សនិងជួសជុលព្រះវិហារវត្តបូណ៌ គឺចាប់-ផ្តើមនៅឆ្នាំ២០១៤ មានបុគ្គលិក១៩នាក់ មកពីនាយកដ្ឋានផ្សេងៗគ្នានៃអាជ្ញាធរជាតិអប្សរា។ ការជួសជុលនិងសម្អាតនេះផ្តោតសំខាន់លើសន្លឹកបង្អួច សន្លឹកទ្វារ ពុទ្ធបដិមាធំក្នុងព្រះវិហារ និងពុទ្ធបដិមាតូចៗមួយចំនួន។ បល្ល័ង្ក គំនូររចនាសម្ព័ន្ធសសរដែលរងនូវការខូចខាត ប្រេះស្រាំ របេះបាត់បង់ភាពដើម ដោយសារផ្សែងភ្លើងធូប ធូលីដីបរិយាកាស អាយុកាល ការលាបពណ៌ថ្មី និងការជួសជុលផ្សេងៗពីមួយជំនាន់ទៅមួយជំនាន់ៗ ដើម្បីរក្សាគុណតម្លៃនៃបុរាណវត្ថុនេះឲ្យបានល្អ អ្នកជំនាញអាជ្ញាធរ-ជាតិអប្សរាប្រើវិធីសម្អាតស្ងួត សម្អាតសើម ដើម្បីយកពណ៌ថ្នាំថ្មី ធូលី ឬលាងកំណកផ្សែងដែលរុំព័ទ្ធលើរូបបដិមា រូបគំនូរ និងចង់ដឹងដែរថា តើពណ៌ដើមនៃសំណង់មានពណ៌អ្វី ធ្វើពីអ្វី។ ម្យ៉ាងទៀត ដើម្បីអភិរក្សនិងលើកតម្លៃសោភ័ណភាពដើមនៃសិល្បៈសំណង់នេះផងដែរ ការសម្អាតមួយស្រទាប់ម្តងៗ ដើម្បីបកថ្នាំទាំងនោះរហូតដល់ស្រទាប់ដើម ដែលភាគច្រើនជាពណ៌បែបស្រគត់ស្រគំ តែកន្លែងខ្លះ រូបខ្លះយើងក៏មិនអាចសម្អាតឲ្យដល់ស្រទាប់ដើមដែរ ព្រោះវានាំឲ្យប៉ះពាល់វត្ថុនោះ។ នៅតាមជញ្ជាំង សសរ រូបចម្លាក់លើស៊ុមបង្អួច មានស្រទាប់ថ្នាំខុសៗគ្នា ចន្លោះពី៨ទៅ៣ស្រទាប់ ហើយរាល់ការសម្អាតជួសជុល ទាមទារឡើងណាស់នូវការអត់ធ្មត់និងប្រិតប្រៀងបំផុត ពិសេសត្រូវមានជំនាញលាយគ្រឿងផ្សំឲ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីកុំឲ្យមានប្រតិកម្មជាមួយថ្នាំចាស់ៗ។

មកដល់បច្ចុប្បន្ន អាជ្ញាធរជាតិអប្សរាសម្រេចបានការសម្អាតជើងសសរ ពុទ្ធបដិមាធំ បល្ល័ង្ករូបចម្លាក់មួយចំនួនសន្លឹកបង្អួច៩ផ្ទាំង រូបគំនូរ៣ផ្ទាំងក្នុងចំណោម១៥៧ផ្ទាំងនូវគ្រឿងលើរូបដែលបាត់មុខ ហើយបិទម្នាងសិលាលើកន្លែងចន្លោះប្រហោងធំៗជាដើម។ ប៉ុន្តែការជួសជុលនេះពុំមែនជាការងាយស្រួលនោះឡើយ ព្រោះបើធ្វេសប្រហែសតែបន្តិចអាចធ្វើឲ្យរូប និងវត្ថុបុរាណទាំងនោះខូចទ្រង់-ទ្រាយដើមទាំងស្រុង។


ការជួសជុលរូបគំនូរនៅក្នុងព្រះវិហារវត្តរាជបូណ៌
ការជួសជុលក្បាច់នៅលើទ្វារនិងបង្អួចនៅព្រះវិហារវត្តរាជបូណ៌



ព្រះវិហារអារញ្ញសាគរ

## ការជួសជុលព្រះវិហារអារញ្ញសាគរ

វត្តអារញ្ញសាគរ គឺជាវត្តអារាមដែលមានវ័យចំណាស់។ គេមិនអាចកំណត់ពីអាយុកាលច្បាស់លាស់នៃសំណង់វិហារនេះបានទេ តែបើតាមដំណឹងពីព្រឹទ្ធាចារ្យក្នុងភូមិ ព្រះវិហារនេះមានអាយុកាលជាងរយឆ្នាំមកហើយ។ មានទីតាំងក្នុងភូមិសាស្ត្រភូមិអារញ្ញ សង្កាត់សៀមរាប ក្រុងសៀមរាប ព្រះវិហារវត្តអារញ្ញសាគរជាសំណង់ព្រះវិហារបុរាណមួយ ក្នុងចំណោមព្រះវិហារជាច្រើនទៀត ដែលស្ថិតនៅតាមបណ្តោយស្ទឹងសៀមរាប ផ្ទុះឆ្ពោះទៅភ្នំក្រោមនៃទន្លេសាប។ ស្ថាបត្យកម្មវិសេសវិសាលនៃព្រះវិហារនេះ គឺការលម្អផ្សេងៗតាមរចនាបថខ្មែរសុទ្ធសាធ សង់នៅលើខឿនខ្ពស់មួយជាន់ ជញ្ជាំងសង់ពីឥដ្ឋតាន់ និងសសរជុំវិញមានទម្រង់មូលដែលជាស្នាដៃរចនាដ៏ពិសេសរបស់បុព្វបុរសខ្មែរជំនាន់មុន។ អ្វីដែលអស្ចារ្យជាងនេះទៀតនោះ គឺភាពមូលនីមួយៗក៏មានសភាពខុសៗគ្នាថែមទៀត។

សសរខាងក្នុង និងគ្រឿងបង្គុំដំបូលនៃវត្តអារញ្ញ គឺធ្វើពីឈើ ប៉ុន្តែដោយសារកត្តាពេលវេលានិងធម្មជាតិ បណ្តាលឲ្យស្ថានភាពសំណង់ទាំងមូលមានសភាពចាស់ទ្រុឌទ្រោម ទាមទារឲ្យមានការជួសជុលជាបន្ទាន់។ ក្នុងបុព្វហេតុអភិរក្សសំណង់វិហារបុរាណ អាជ្ញាធរជាតិអប្សរាបានជួយលើផ្នែកបច្ចេកទេស សិក្សាចម្លងប្លង់ចាស់ទុកធ្វើជាឯកសារ ដើម្បីឲ្យប្រាកដថា ការជួសជុលបានគោរពតាមមាត្រដ្ឋាន និងទម្រង់ដើមនៃវិហារនេះ។ ការជ្រើសរើសវិធីសាស្ត្រជួសជុលបែបនេះ គឺសំដៅធ្វើយ៉ាងណារក្សាទម្រង់ដើម និងធ្វើការជួសជុលតិចបំផុតតាមតែអាចធ្វើទៅបាន។ ជាក់ស្តែងការជួសជុលសសរនៃវិហារនេះ គឺគ្រាន់តែបកសំបកបាយក្រៀមដែលពុកផុយចេញ ហើយបូកស៊ីម៉ងត៍ថ្មីតែប៉ុណ្ណោះ។ ចំណែកដំបូលវិញ គឺត្រូវរៀបតាមលំនាំរចនាបថដើម ហើយក្បឿងត្រូវដូរថ្មី ដោយទុកក្បឿងចាស់ ដែលនៅប្រើបានសម្រាប់ប្រក់នៅកន្លែងណាមួយនៃដំបូលវិហារ។



ផ្ទាំងគំនូរ នៅក្នុងព្រះវិហារបាគង © CHAOSUN KERYA



ព្រះវិហារបាគង

## ការជួសជុលព្រះវិហារបាគង

តាមរូបភាពប្រវត្តិសាស្ត្រ ថតដោយសាលាបារាំងចុងបូព៌ានៅឆ្នាំ១៩៣៤ គេឃើញព្រះវិហារបាគងសាងសង់អំពីឈើប្រក់ក្បឿង ស្ថិតនៅលើចំណុចកណ្តាល នៃប្រាង្គប្រាសាទបាគង។ ក៏ប៉ុន្តែ ដោយតម្រូវការជួសជុលប្រាង្គប្រាសាទបាគង ទើបព្រះវិហារនេះត្រូវបានរំកិលចុះមកខាងក្រោមនៅឆ្នាំ១៩៣៨ ហើយសាងសង់ជាឥដ្ឋប្រក់ក្បឿងវិញ។ ព្រះវិហារបាគង មានទីតាំងនៅខាងជើងប្រាសាទបាគងជាប់នឹងមាត់គសិន្ធុប្រាសាទបាគងហើយ ព្រះវិហារនេះ ត្រូវបានកសាងឡើងក្នុងរចនាបថ សំណង់បុរាណខ្មែរ និងមានការតុបតែងលម្អយ៉ាងល្អ ឥតខ្ចោះរួមជាមួយនឹងគំនូរពុទ្ធប្រវត្តិយ៉ាងប្រណីត ក្នុងលក្ខណៈសំណង់ព្រះពុទ្ធសាសនា។

ដោយកត្តាអាយុកាល ព្រះវិហារបាគងរងការ ខូចខាត ខូចទ្រង់ទ្រាយ និងផ្ទាំងគំនូរជាច្រើនបានរលុប ស្ទើរមើលមិនយល់។

ក្នុងស្ថានភាពនេះហើយ ទើបនៅក្នុងកំឡុងឆ្នាំ២០០៧ រហូតដល់ពាក់កណ្តាលឆ្នាំ២០១១ អាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុន HOLCIM Group នៃប្រទេសស្វីស បានធ្វើការជួសជុលព្រះវិហារបាគងនោះឡើងវិញ។ ការជួសជុលត្រូវបែងចែកជា០៣ដំណាក់កាលផ្សេងគ្នាដោយចាំបាច់ ជាពិសេសការសិក្សាឡើងវិញអំពីភាពរឹងមាំនៃសំណង់ព្រះវិហារ។

ការជ្រើសរើសវិធីសាស្ត្រនិងបច្ចេកទេសជួសជុលបែបនេះ ក៏ព្រោះតែសំណង់ព្រះវិហារមានវ័យចំណាស់ ដែលចាំបាច់ត្រូវថែរក្សាឲ្យបានគង់វង្សនិងស្របតាមគោលការណ៍អភិរក្សរបស់អាជ្ញាធរជាតិអប្សរា គឺអ្វីដែលមានស្រាប់ត្រូវពង្រឹងឡើងវិញ ឬជំនួសត្រង់ចំណុចណាដែលទ្រុឌទ្រោមខ្លាំង ដើម្បីរក្សាឲ្យបាននូវទ្រង់ទ្រាយដើមនៃសំណង់ព្រះវិហារ។ ចំណុចសំខាន់ៗនៃការជួសជុលសំណង់ព្រះវិហារបាគងមានដូចជា ការពង្រឹងគ្រឹះនៃសសរទាំងអស់ ការពង្រឹង និងជួសជុល ដំបូល ពិដាន រូបគ្រុឌជាប់ព្រះវិហារ និងការជួសជុលរូបគំនូរស្ពឹត ពុទ្ធប្រវត្តិ។




## កំណាយនៅភ្នំគូលែន ក្រោមការសហការជាមួយអង្គការADF

ក្នុងឆ្នាំ២០១៨ ក្រុមបុរាណវិទូនៃអាជ្ញាធរជាតិអប្សរា និងបុរាណវិទូនៃអង្គការមូលនិធិបុរាណវិទ្យា និងអភិវឌ្ឍន៍ភ្នំគូលែនហៅកាត់ថា (ADF) បានសហការគ្នាធ្វើកំណាយលើទីតាំងមួយឈ្មោះ បន្ទាយ ឬហៅថា «ផ្ទះគូបាឫ» បានរកឃើញរចនាសម្ព័ន្ធសំណង់បុរាណមួយធ្វើពីឥដ្ឋ និងថ្មបាយក្រៀម។ ទីតាំងនេះស្ថិតនៅសហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ធំ ភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប នៃឧទ្យានជាតិព្រះជ័យវរ្ម័នទេគូមភ្នំគូលែន។




ទាក់ទងនឹងការអះអាងថា ទីនេះអាចជាអតីតរាជវាំង ឬរាជដំណាក់របស់ព្រះបាទជ័យវរ្ម័នទី២ នោះអ្នកជំនាញបុរាណវិទ្យាបានឲ្យដឹងថា៖ យោងទៅលើឯកសារស្រាវជ្រាវរបស់បារាំង និងខ្មែរពីមុនៗ ដែលសន្និដ្ឋានថានេះជារាជវាំងរបស់ព្រះអង្គ ដែលទ្រង់បានមកតាំងរាជធានីនៅលើខ្នងភ្នំគូលែន។ ដូច្នេះអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិបានសន្និដ្ឋានថា ទីនេះប្រហែលជាអតីត «រាជដំណាក់ ឬរាជវាំង» របស់ព្រះបាទជ័យវរ្ម័នទី២ បានកសាងនៅដើមសតវត្សរ៍ទី៩ មានទំហំផ្ទៃដី ៦០០ម៉ែត្រ x ៦០០ម៉ែត្រ។ យោងតាមលទ្ធផលដែលសន្និដ្ឋានបឋមមាន៖

-យើងបានរកឃើញកាំជណ្ដើរសង់ពីឥដ្ឋដែលជាច្រកចូលពីទិសខាងកើត។

- ចំពោះសំណង់កណ្ដាលនៃអគារអាចបែងចែកជា៦ដំណាក់កាល។

ដំណាក់កាលទី១ ប្រហែលជាស្ថិតក្នុងរាជព្រះបាទជ័យវរ្ម័នទី២ ក្នុងសតវត្សទី៩ បច្ចេកទេសសំណង់ មានការបង្ហាប់គ្រឹះ ដោយប្រើដីលាយជាមួយកម្ទេចថ្មបាយក្រៀមគ្រួស បន្ទាប់មករៀបក្រាំត់ពីឥដ្ឋមុននឹងធ្វើសំណង់ខាងលើ។

ដំណាក់កាលទី២ គឺចាក់ដីកម្រាស់៣០សង់ទីម៉ែត្រនៅលើកម្រាលឥដ្ឋដំណាក់កាលទី១ បន្ទាប់មកក៏រៀបកម្រាលឥដ្ឋនៅពីលើ។ ក្នុងដំណាក់កាលនេះ យើងមិនទាន់អាចធ្វើការសន្និដ្ឋានថាធ្វើពេលណានៅឡើយនោះទេ ដោយសារយើងមិនទាន់មានភស្តុតាងគ្រប់គ្រាន់។



ដំណាក់កាលទី៣ នៅផ្នែកខាងជើងនៃសំណង់អគារកណ្ដាលមានការរៀបចំសំណង់បន្ថែមដោយយើងឃើញឥដ្ឋនៅទីតាំងនេះរៀបពីលើឥដ្ឋដូចដំណាក់កាលទី២។

ដំណាក់កាលទី៤ នៅផ្នែកខាងលិចឆៀងខាងជើងជាប់នឹងសំណង់ក្នុងដំណាក់កាលទី៣ មានសំណង់ឥដ្ឋរៀបលើសំណង់ទី៣។

ដំណាក់ទី៥ យើងបានរកឃើញស្លាមសសរជាច្រើន។ ក្នុងដំណាក់កាលនេះបរិវេណអាគារគឺធ្វើពីលើរហូតដល់ដំណាក់កាល់ទី២។

ដំណាក់កាលទី៦ ស្ថិតក្នុងអំឡុងសតវត្សទី២០ រហូតដល់ពេលមានសង្គ្រាមផ្ទៃក្នុង គឺមានគ្រួសារព្រឹទ្ធាចារ្យម្នាក់បានសាងសង់ផ្ទះនៅលើសំណង់ចាស់។

ក្រៅពីកិច្ចការកំណាយស្រាវជ្រាវនេះ អាជ្ញាធរជាតិអប្សរានិងអង្គការ ADF បាននិងកំពុងចងក្រងសៀវភៅស្ដីអំពីបញ្ជីសារពើភណ្ឌបុរាណវត្ថុ និងបុរាណដ្ឋាននៅលើខ្នងភ្នំគូលែន ដែលជាលទ្ធផលដ៏ធំធេងបានមកពីការងារស្រាវជ្រាវ និងចុះផ្ទៀងផ្ទាត់ដល់ទីតាំងផ្ទាល់ដោយប្រៀបធៀបជាមួយទិន្នន័យដែលបានពីបច្ចេកវិទ្យាLiDAR ឆ្នាំ២០១២និង២០១៥។ លទ្ធផលទាំងនេះនឹងក្លាយជាចំណែកបំពេញលក្ខខណ្ឌក្នុងការដាក់បញ្ចូលភ្នំគូលែនទៅជាសម្បត្តិបេតិកភណ្ឌពិភពលោកនាអនាគត។













ស្ថានីយឡបុរាណទាំង៩ បានធ្វើកំណាយសិក្សាស្រាវជ្រាវកន្លងមក
Zemn-&-Jica

## ឧស្សាហកម្មកុលាលភាជន៍តំបន់អង្គរ

ឡបុរាណជាទីតាំងឧស្សាហកម្មកុលាលភាជន៍សំខាន់មួយក្នុងសម្បត្តិវប្បធម៌របស់អាណាចក្រអង្គរ។ ជិតបីទសវត្សកន្លងមក ការសិក្សាស្វែងយល់ពីឡបុរាណ ប្រព្រឹត្តឡើងក្រោយកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរាជាមួយនឹងស្ថាប័នអន្តរជាតិនានា។ ទន្ទឹមនឹងនោះ ការិយាល័យសិក្សាកុលាលភាជន៍របស់អាជ្ញាធរជាតិអប្សរាក៏ចូលរួមមួយចំណែកក្នុងការសិក្សាស្វែងយល់លើកតម្លៃសម្បត្តិវប្បធម៌របស់នេះ។ បុគ្គលិកខ្មែរនៃអាជ្ញាធរជាតិអប្សរាកំពុងបន្តការសិក្សាស្រាវជ្រាវស្ថានីយឡថ្នល់ម្រេច ឡបង្កោង និងឡខ្នារពោធិ៍ តាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន។ ការសិក្សានេះផ្តោតទៅលើរូបរាងខាងក្រៅរបស់កុលាលភាជន៍ សមាសធាតុដី បច្ចេកទេសផលិត ទម្រង់រូបរាងរបស់ភាជន៍ និងក្បាច់លម្អ។ ក្រោមកិច្ចសហការជាមួយស្ថាប័នអន្តរជាតិក្នុងតំបន់អង្គរ បានបង្ហាញនូវកាលបរិច្ឆេទសំណង់ឡបុរាណ និងកុលាលភាជន៍ ចាប់ពីដើមសតវត្សទី០៩ ដល់ទី១៥ នៃគ្រិស្តសករាជ។

នាពេលបច្ចុប្បន្នស្ថានីយឡបុរាណមានចំនួន៩ ដែលបានធ្វើកំណាយសិក្សាស្រាវជ្រាវ ហើយស្ថានីយឡទាំងនោះ មានអាយុកាលចាប់ពីចុងសតវត្សទី៨រហូតដល់សតវត្សទី១៥នៃគ.ស។ លទ្ធផលនៃការស្រាវជ្រាវ បានបែងចែកស្ថានីយឡទាំងនោះជាបីក្រុម តាមរយៈរចនាសម្ព័ន្ធឡ រូបរាងកុលាលភាជន៍ និងទីតាំងភូមិសាស្ត្រ។ ក្រុមស្ថានីយឡតំបន់អង្គរ មានដូចជា ឡបង្កោង ឡថ្នល់ម្រេច ឡតានី ឡសសើ និងឡខ្នារពោធិ៍។ ក្រុមស្ថានីយឡនៅទិសអាគ្នេយ៍តំបន់អង្គរ ជាក្រុមទី២ស្ថិតនៅជិតរាជធានីភ្នំពេញ មានឈ្មោះស្ថានីយឡជើងឯក។ យោងតាមក្រុមស្រាវជ្រាវរបស់រាជបណ្ឌិតសភាភ្នំពេញឡជើងឯកមានចំនួន៦១ឡបុរាណ ដែលមានវិសាលភាពធំជាងគេក្នុងអាណាចក្រអង្គរ។ ក្រុមស្ថានីយឡនៅខាងកើតតំបន់អង្គរ ជាស្ថានីយផលិតកុលាលភាជន៍ចុងសម័យអង្គរ សតវត្សទី១៣ ដល់ទី១៥ នៃគ្រិស្តសករាជ) ដែលស្ថិតនៅតាមបណ្តោយផ្លូវខាងកើតអង្គរទៅព្រះខ័នកំពង់ស្វាយ រួមមានស្ថានីយឡទ័ពជ័យចំនួន១២ឡ។ ឡចុងសំរោងចំនួន ២ឡ និងឡរលស្វាយចំនួន ៣ឡ ។ ស្ទួនទាំងបីក្រុមមានបច្ចេកទេសស្ងួនកុលាលភាជន៍ដូចគ្នា ដោយគ្រាន់តែនិយមស្រទាប់លោហធាតុខុសគ្នាទៅតាមសម័យកាល។

រចនាសម្ព័ន្ធឡរួមមានបន្ទប់ដុតភ្លើង បន្ទប់ដុតភាជន៍ និងបំពង់ផ្សែង។ បន្ទប់ដុតភ្លើងស្ថិតនៅទាបជាងបន្ទប់ដុតភាជន៍ និងមានសសរមួយជួរ ចំកណ្តាលបន្ទប់ដុតភាជន៍សម្រាប់ទ្រដំបូលឡ។

ឧស្សាហកម្មកុលាលភាជន៍ក្នុងតំបន់អង្គរ មានឡ ចំនួន៥ (ឡបង្កោង ឡថ្នល់ម្រេច ឡតានី ឡសសើ និងឡខ្នារពោធិ៍) ដែលលាតសន្ធឹងលើផ្ទៃរាបតំបន់អង្គរ ដល់ខ្ពង់រាបភ្នំគូលែន ដែលមានដំណើរការផលិតកុលាលភាជន៍ ចាប់ពីដើមសតវត្សទី៩ ដល់ទី១៣នៃគ.ស។ ស្ថានីយឡបង្កោងមានឡចំនួន៣៧ឡ ស្ថានីយឡថ្នល់ម្រេចមានឡចំនួន១០ឡ ស្ថានីយឡតានីមានឡចំនួន២៥ឡ ស្ថានីយឡសសើមានឡចំនួន២៨ឡ និងស្ថានីយឡខ្នារពោធិ៍មានឡចំនួន១៨ឡ។ រចនាសម្ព័ន្ធឡមានការវិវត្តពីតូចទៅធំ និងជាទូទៅស្ទួនស្ថាបនារចនាសម្ព័ន្ធឡថ្មីជាន់ពីលើឡចាស់ដែលខូចខាត។ ស្ទួនកសាងឡនៅលើទំនប់ថ្នល់ ឬទំនប់ទឹកបុរាណ ដោយប្រើជម្រាលនៃទំនប់នោះដើម្បីស្ថាបនាឡពីទីទាបទៅខ្ពស់។ ការសង់ឡនៅស្ថានីយឡបង្កោង ស្ទួនស្ថាបនាឡតាមបណ្តោយមាត់ស្ទឹង លើដីទួលដាច់ដោយឡែកពីទួល មួយទៅទួលមួយទៀត។



គុលាលភាជន៍ឡតំបន់អង្គរ

ស្ទួនប្រើដីឥដ្ឋស ដើម្បីស្ងួនកុលាលភាជន៍ទំហំតូច និងប្រើដីឥដ្ឋធម្មតា (ប្រភពដីនៅជិតស្ថានីយឡ) ស្ងួនកុលាលភាជន៍ទំហំធំ។ តាមរយៈប្រភេទដីឥដ្ឋស និងដីឥដ្ឋធម្មតា រួមផ្សំជាមួយនឹងកម្តៅខុសគ្នាក្នុងបន្ទប់ដុតភាជន៍ ជាបុព្វហេតុឲ្យផលិតផលកុលាលភាជន៍មានច្រើនពណ៌ (ពណ៌ប្រផេះទៅពណ៌ត្នោតខ្ចីចំពោះភាជន៍ទំហំធំ និងមានពណ៌បៃតងខ្ចីចំពោះភាជន៍ទំហំតូច) និងគុណភាពសាច់ដីកុលាលភាជន៍ផុយ ដល់រឹង។ តាមរយៈការសិក្សាស្រាវជ្រាវកុលាលភាជន៍ខ្មែរបានមកអំពីកំណាយស្រាវជ្រាវនៅស្ថានីយឡតំបន់អង្គរ ត្រូវបានចំណាត់ថ្នាក់៣ប្រភេទធំៗទៅតាមរូបរាង និងការប្រើប្រាស់។ ក្នុងនោះរួមមានគ្រឿងស្រទាប់ចេក កុលាលភាជន៍ទំហំតូចមាន (ជន្លាប់ កោដ្ឋ ខ្ចក អកកំបោរ និងចាន) និងកុលាលភាជន៍ទំហំធំមាន (ឆ្នាំង ក្រឡ ផើង ពាង ក្អម និងថូ)។ បច្ចេកទេសស្ងួននិងលម្អកុលាលភាជន៍ៈ ស្នាកស្នាមបន្សល់លើផ្ទៃខាងក្រៅរបស់ភាជន៍ បង្ហាញឲ្យដឹងពីបច្ចេកទេសស្ងួនកុលាលភាជន៍ដូចជា ការប្រើឈ្នាន់បង្វិល ដែលឃើញមានប្រើសម្រាប់ស្ងួនភាជន៍ទំហំតូចៗ។ ជាមួយគ្នានេះដែរ ស្ទួនប្រើចង្វាយមូលដីឥដ្ឋសម្រាប់ស្ងួនភាជន៍ធំៗ។ ក្នុងការលម្អកុលាលភាជន៍ស្ទួនប្រើបច្ចេកទេសឆ្លូត និងប្រដាប់ដែលធ្វើឡើងនៅលើឈ្នាន់បង្វិល ខណៈពេលឈ្នាន់កំពុងវិល ស្ទួនយកឧបករណ៍មកឆ្លូតលើផ្ទៃខាងក្រៅ បង្កើតជាក្បាច់ឆ្នូតផ្តេកមួយជុំៗ ដែលអាចឃើញមាននៅតាមជើងទម្រ ក្លៀក និងមាត់របស់ភាជន៍។ លើសពីនេះមានលម្អក្បាច់ឆ្លូតផ្សេងៗនៅលើគម្របរបស់ជន្លាប់ និងកោដ្ឋផងដែរ។



## ការប្រទះឃើញទូកបុរាណដ៏កម្រដំបូងបំផុត ដែលមានអាយុកាលចាស់ជាងគេក្នុងតំបន់អង្គរ

ទូកបុរាណប្រវែង១២,៨៣ម៉ែត្រ ដែលកប់នៅក្នុងដីជម្រៅជាង៧ម៉ែត្រ ត្រូវបានប្រទះឃើញនៅការដ្ឋានបូមខ្សាច់ក្នុងភូមិបំពេញរាជ្យ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។ ទូកប្រភេទនេះ ជាទូកកម្រដែលអ្នកស្រាវជ្រាវមិនដែលបានប្រទះឃើញ និងពុំឃើញមានប្រើប្រាស់ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។

យោងលទ្ធផលនៃការវិភាគនៅមន្ទីរពិសោធន៍ប្រទេសញូវហ្សេឡែនដោយប្រព័ន្ធវិទ្យាសាស្ត្រកាបូន១៤ ដែលមានភាពសុក្រិត និងច្បាស់បំផុត ហើយមានការទទួលស្គាល់ជាលក្ខណៈសកល ទូកបុរាណនេះមានអាយុ៨១១ឆ្នាំដោយមានកាលបរិច្ឆេទនៅឆ្នាំ១២០៧ ក្នុងរជ្យព្រះបាទជ័យវរ្ម័នទី៧។

បើតាមទម្រង់រូបរាងជាក់ស្តែងបានបញ្ជាក់ថា ទូកបុរាណ ដែលបានកប់ក្នុងដីជម្រៅ៧ម៉ែត្រនេះ ជាប្រភេទទូកឈ្លង ធ្វើពីដើមគគីរមួយដើមទាំងមូលមានប្រវែង១២,៨៣ម៉ែត្រ។ ចំពោះទីតាំងដែលរកឃើញវិញ គឺជាអតីតស្ទឹងពួកចាស់ ជាប់នឹងស្ទឹងសៀមរាបហូរទៅកាន់ស្រុកពួក។













ការប្រទះឃើញព្រះបដិមា កៃលជ្យគុរុ ព្រះពុទ្ធស្ដេចថ្នាំ

ព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថាជាព្រះពោធិសត្វ ដែលមានព្រះនាមហៅថា «កៃលជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្ដេចថ្នាំនៅសម័យបុរាណ ត្រូវបានប្រទះឃើញក្នុងគម្រោងស្រាវជ្រាវស្ដីពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដោយក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា និងវិទ្យាស្ថានស្រាវ-ជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី។ ក្នុងរណ្ដៅកំណាយនៅផ្នែកខាងកើតប្រាសាទ អ្នកស្រាវជ្រាវបន្តប្រទះឃើញបដិមាជាព្រះពុទ្ធប្រក់នាគ និងបដិមាដ៏ធំមួយអង្គដែលសន្និដ្ឋានជាបឋមថាជាទ្វារបាល មានកម្ពស់ហួសពីទៅ ១,៩០ម៉ែត្រ និងស្មាទទឹងហួសពីទៅ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្ដៅកំណាយ។ ក្នុងរណ្ដៅនេះដដែលក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើងនៃរូបបដិមាដ៏ធំនោះស្ថិតក្នុងរចនាបថបាយ័ន្ត បដិមានេះ កំបុតដៃទាំងពីរត្រឹមស្មា កំបុតជើងស្ដាំត្រឹមកជើង និងជើងឆ្វេងត្រឹមគល់ភ្លៅ។ ចំណែកដងខ្លួន និងព្រះកេសនៅមានក្បាច់ចម្លាក់សម្លៀកបំពាក់ និងក្បាំងសក់នៅស្អាតទាំងអស់។ បដិមានេះកប់ជ្រៅក្នុងដីប្រមាណត្រឹម៤តឹក ប៉ុណ្ណោះក្នុងពេលអ្នកស្រាវជ្រាវធ្វើកំណាយរកឃើញ ដោយដេកផ្ងារពោះបែរព្រះកេសទៅទិសខាងលិចទៅព្រះវិហារនៃមន្ទីរពេទ្យ។



បដិមាដ៏ធំមួយអង្គដែលសន្និដ្ឋានជាបឋមថាជាទ្វារបាល មានកម្ពស់ហួសពីទៅ ១,៩០ម៉ែត្រ និងស្មាទទឹងហួសពីទៅ ០,៥៨ម៉ែត្រ



## គម្រោងស្រាវជ្រាវ "ព្រះរាជរោងសិតសរិទ្ធក្នុងព្រះបរមរាជវាំងអង្គរធំ"







គម្រោងស្រាវជ្រាវ "ព្រះរាជរោងសិតសំរិទ្ធក្នុងព្រះបរមរាជវាំងអង្គរធំ" អនុវត្តដោយអាជ្ញាធរជាតិអប្សរានិងសាលាបារាំងចុងបូព៌ា(EFEO)បានបង្ហាញថាជនជាតិខ្មែរមានរោងសូលោហកម្មធំនិងប្រណីតជាងគេនៅអាស៊ី - អាគ្នេយ៍។ លទ្ធផលបឋមនៃកំណាយស្រាវជ្រាវនៅក្នុងព្រះបរមរាជវាំងអង្គរធំសម័យអង្គរនេះ ថែមទាំងបង្ហាញថា ទំនៀមនៃការផលិតលោហកម្មរបស់បុព្វបុរសខ្មែរនៅតែបន្តអាយុជីវិតនៅឡើយសព្វថ្ងៃ។

តាមការអះអាងរបស់អ្នកជំនាញកំណាយស្រាវជ្រាវនេះ បានរកឃើញចង្ក្រានសូលោហៈចំនួនពីរពុម្ពសម្រាប់ចាក់ជារូបផ្សេងៗ រួមនិងកម្ទេចកម្ទីលោហៈតូចៗដូចជាទង់ដែង ដែក និងសំណជាដើម។ សំណាកនៃលោហៈទាំងនេះបញ្ជាក់ថា ខ្មែរចេះវិធីផលិតលោហធាតុ មានសំរិទ្ធជាដើម ទៅជាគ្រឿងអលង្ការ សម្ភារៈប្រើប្រាស់ផ្សេងៗបានយ៉ាងល្អ ខណៈពេលដែលប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍មិនទាន់មាន។

## ប្រជាពលរដ្ឋក្នុងការប្រគល់វត្ថុបុរាណជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក



ក្រឡបុរាណធ្វើអំពីដីដុតសម្រាប់ដាក់វត្ថុច្រើនប្រភេទដូចជា អំបិល ស្ករ ប្រហុក និងវត្ថុរាវផ្សេងៗទាក់ទងជីវិតប្រចាំថ្ងៃផលិតនៅស្រុកខ្មែរចន្លោះសតវត្សទី១១ ទៅ១៥ នៃគ.ស ត្រូវបានអ្នកភូមិនគរក្រៅសង្កាត់គោកចក ក្រុង-សៀមរាប ប្រគល់ជូនអាជ្ញាធរជាតិអប្សរារក្សាទុកនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧។ តាមរយៈក្រឡនេះគេអាចសន្និដ្ឋានថា ក្រឡជាវត្ថុប្រើប្រាស់ដ៏សំខាន់ក្នុងការរស់នៅប្រចាំថ្ងៃមួយសម្រាប់មនុស្សសម័យបុរាណនិងបច្ចុប្បន្ន។



ព្រះពុទ្ធរូបប្រក់នាគក្បាលប្រាំពីរមួយព្រះអង្គ ធ្វើពីថ្មភក់ មានទម្រង់ព្រះភ្នែនលើផ្ចិលខាងបំពង់ ស្ថិតក្នុងចុងស.វទី១២ ដើម១៣ សម័យបាយ័ន្ត មានកម្ពស់៥៩ស.មបណ្ដោយ៣០ស.ម ទទឹង១៨ស.ម ត្រូវបានអ្នកភូមិគន្ធូត ឃុំកន្ធូត ស្រុកស្វាយលើ ខេត្តសៀមរាបប្រគល់ជូនអាជ្ញាធរជាតិអប្សរារក្សាទុកកាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។




## ការថែរក្សាជំនឿសាសនាតាមទំនៀមអ្នកអង្គរ

ចំពោះមនុស្សខ្លះយល់ឃើញថា អង្គរគ្រាន់តែជាសំណង់ប្រាសាទដ៏ធំមហិមា ជាកន្លែងប្រមូលផ្តុំទៅដោយរឿងរ៉ាវអាថ៌កំបាំង ជាទីកន្លែងស្រាវជ្រាវដ៏ចម្បង ជាថ្មដែលគ្មានជីវិត និងគ្រាន់តែជាកន្លែងកម្សាន្តអារម្មណ៍ជួបជុំគ្រួសារមិត្តភក្តិលំហែកាយប៉ុណ្ណោះ។

ផ្ទុយទៅវិញ សម្រាប់ប្រជាជនខ្មែរដែលមានជំនឿមុតមាំ ពិសេសអ្នកខេត្តសៀមរាប និងអ្នកនៅក្នុងតំបន់អង្គរផ្ទាល់ អង្គរជាអ្វីដែលមានភាពអស្ចារ្យជាងភ្នែកមើលឃើញ អង្គរជាដួងព្រលឹង ជាវិញ្ញាណនៃវត្ថុស័ក្តិសិទ្ធិ ជាបូជនីយដ្ឋានដែលនៅតែមានជីវិតតាំងពីកប់ពាន់ឆ្នាំ បើទោះបីបច្ចុប្បន្នសង្គមទំនើបទាន់សម័យក៏ដោយ ក៏អង្គរនៅតែជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ពួកគាត់។

ប្រាសាទបុរាណក្នុងតំបន់អង្គរ ត្រូវបានអ្នកស្រុកអង្គរ និងអ្នកដែលមានជំនឿគ្រប់ជាន់ថ្នាក់ ទុកជាកន្លែងដ៏ពិសិដ្ឋរបស់ទេព កន្លែងដែលមានវត្ថុស័ក្តិសិទ្ធិនិងបារមីខ្លាំងពូកែថែរក្សា។ ដូច្នេះ គេច្រើនយកកន្លែងនេះធ្វើជាកន្លែងប្រារព្ធពិធីសាសនាធំៗ ពិធីបួងសួងសុំសេចក្តីសុខចម្រើន សុំសុខសន្តិភាពទាំងផ្ទាល់ខ្លួន និងប្រទេសជាតិ ហើយក៏ជាកន្លែងបន់ស្រន់ ប្រាថ្នា និងធ្វើជាកសិណសាក្សីក្នុងរឿងផ្សេងៗផងដែរ។

អ្នកស្រុកអង្គរបានថែរក្សាទាំងសំណង់ប្រាសាទដោយការពារការលួច ការបំផ្លាញ ស្វែងយល់ពីវិធីអភិរក្សជាមួយអ្នកជំនាញ និងសម្អាតបរិស្ថានជុំវិញប្រាសាទ ព្រោះប្រាសាទជាកន្លែងទេព កន្លែងសម្រាប់ប្រារព្ធពិធីផ្សេងៗ។ ពួកគាត់ក៏ថែរក្សាទាំងជំនឿដែលពួកគាត់ជឿថា ជាដួងព្រលឹងបុព្វបុរសខ្មែរឲ្យរស់រកមានជីវិតរហូតដល់សព្វថ្ងៃយ៉ាងខ្ជាប់ខ្ជួន តាមរយៈការប្រតិបត្តិក្នុងការរស់នៅប្រចាំថ្ងៃ និងទំនៀមតាមផ្លូវកោល។ ជាក់ស្តែង ការរក្សានូវសម្លៀកបំពាក់ សាមគ្គីភាពក្នុងការធ្វើពិធីអ្វីមួយ ការប្រកបរបរប្រពៃណី ការប្រើប្រាស់សម្ភារៈប្រពៃណី ការគោរពនូវទំនៀមដូនតា ការសែនព្រេន បន់ស្រន់ហៅព្រលឹង ការគោរពបុគ្គល (អ្នកតា) ឬទីកន្លែងស័ក្តិសិទ្ធិក្នុងស្រុកភូមិជាដើម។

លើសពីនោះទៀត មានជំនឿខ្លះត្រូវអ្នកភូមិនិយមធ្វើទៅតាមផ្លូវកោលដូចជា លៀងមេមត់ ឡើងអ្នកតា ទូងចេត្រ ឬង់ក្រឡាន សុំទឹកភ្លៀង បិណ្ឌាតូច ចូលម្លប់ បំបួសនាគ។ល។ ដោយយកប្រាសាទ ផ្ទះខ្លួន និងទីដ៏ពិសិដ្ឋណាមួយធ្វើជាកន្លែងប្រារព្ធពិធី។ ពិធីទាំងនេះ មានពិធីខ្លះជាទំនៀមរបស់អ្នកស្រុកអង្គរផ្ទាល់តែម្តង ដែលគ្មានឡើយនៅតំបន់ផ្សេង ហើយប្រជាជនកម្រនឹងទុកខានក្នុងការប្រារព្ធពិធីទាំងនេះណាស់ បើទោះជាគ្មានអ្វីធ្វើធំដុំ ក៏នឹងបន្តធ្វើទៅតាមលទ្ធភាពដែលមាន ព្រោះពួកគាត់ជឿថា វានឹងនាំមកនូវសេចក្តីសុខសប្បាយ ហើយវាជាអ្វីដែលមានតាំងពីដូនតាទើបមិនចង់ឲ្យបាត់បង់។










អាជ្ញាធរជាតិអប្សរា ក្នុងនាមជាអ្នកគ្រប់គ្រងតំបន់អង្គរឲ្យមានការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព បានរួមចំណែកយកចិត្តទុកដាក់ ថែរក្សាអភិរក្សនូវមរតករូបី និងអរូបីជាមួយអ្នកស្រុកអង្គរឲ្យតំបន់នេះពេញដោយភាពស្រស់បំព្រង សុវត្ថិភាព មានហេដ្ឋារចនាសម្ព័ន្ធល្អ។ ពិសេស គឺចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីទំនៀមរបស់អ្នកស្រុក។

អាជ្ញាធរជាតិអប្សរាក៏បានចងក្រងក្រុមការងារកត់ត្រាអំពីទំនៀមរបស់អ្នកស្រុក ផ្សព្វផ្សាយឲ្យប្រជាជនយល់ដឹងពីសម្បត្តិវប្បធម៌ជាតិតាមរយៈការអប់រំពីកុមារតូចៗ រហូតដល់មនុស្សចាស់។ ការចូលជាវិភាគទានដើម្បីទ្រទ្រង់កម្មវិធីរបស់អ្នកស្រុក ការចូលរួមជួសជុលសំណង់អគារសម្រាប់អ្នកស្រុក ប្រារព្ធពិធីបុណ្យទាន។ ពិសេសជាងនេះទៅទៀត គឺការអភិរក្សជួសជុលនូវសំណង់បុរាណ ចម្លាក់ គំនូរដែលនៅតាមវិហារ ដែលជាទីគោរពសក្ការៈរបស់ប្រជាជនខ្មែរយ៉ាងសកម្មផងដែរ។

## ពិធីបួងក្រឡាន

ពិធីដែលគេយកក្រឡាន រួមនឹងផ្លែឈើ ភោគផលជាច្រើនប្រភេទ ទៅបួងពោលដើម្បីឲ្យព្រះសង្ឃនិមន្តទៅទស់យកហៅថា ពិធីបួងក្រឡាន។ អ្នកអង្គរនិយមធ្វើពិធីនេះនៅក្រោយរដូវច្រូតកាត់ហើយ។ គេតែងធ្វើនៅពេលរសៀល និងបន្តរហូតដល់យប់ជ្រៅ។ គោលបំណងនៃពិធី គឺអបអរការប្រមូលផលកសិកម្ម និងធ្វើបុណ្យឧទ្ទិសដល់ញាតិកាដែលបានស្លាប់ទៅហើយ។

កម្មវិធីសំខាន់ៗដែលគេធ្វើក្នុងពិធីនេះមានដូចជា គេរៀបចំគ្រឿងរណ្តាប់មាន ក្រឡាន អន្សម ផ្លែឈើ ត្រី សាច់ អំបិល ស្ករ ធូប ទៀន យកមកបួងពោលនៅកន្លែងណាមួយនៃពិធី ហើយគ្របស្លឹកឈើពីលើ រួចអុជធូបទៀន។ បន្ទាប់មកក៏និមន្តព្រះសង្ឃសមាទានសីល ហើយនិមន្តព្រះសង្ឃមួយអង្គ ធ្វើធុតង្គបីជុំយ៉ាងស្ងប់ស្ងាត់ដើម្បីទាករបស់ទាំងនោះ។ អ្នកចូលរួមអង្គុយសំពះដោយក្តីគោរព និងស្ងៀមស្ងាត់បំផុត។




## ពិធីបួងសួងសុំទឹកភ្លៀងអ្នកស្រុកអង្គរនៅប្រាសាទនាគព័ន្ធ



នាគព័ន្ធជាប្រាសាទដែលអ្នកស្រុកអង្គរយល់ថា មានភាពសក្តិសិទ្ធិអាចផ្តល់ទឹកភ្លៀងតាមសេចក្តីត្រូវការ នៅពេលជួបគ្រោះរាំងស្ងួត។ អ្នកអង្គរតែងប្រារព្ធពិធីសុំទឹកភ្លៀងជាប្រចាំ នៅពេលដល់រដូវធ្វើស្រែហើយនៅមិនទាន់មានភ្លៀងធ្លាក់គ្រប់គ្រាន់។

កម្មវិធីដែលគេធ្វើក្នុងពិធីនេះ គឺការរៀបចំពិធីប្រុងពលីប្រកាសបួងសួង និងសែនគ្រឿងសំណែនផ្សេងៗ។ ព្រះសង្ឃស្វាធ្យាយព្រះបរិត្ត និងធម៌មហាមេឃ ការបញ្ចាលរូប។ ពេលព្រឹកឡើង គេនិមន្តព្រះសង្ឃឆាន់យាគូ និងរាប់បាត្រព្រះសង្ឃតាមទំនៀមព្រះពុទ្ធសាសនា។



មុននឹងបញ្ចប់កម្មវិធី អាចារ្យនាំអ្នកស្រុកដើរប្រទក្សិណប្រាសាទនាគព័ន្ធ៣ជុំ ដោយចាក់ទឹកលើក្បាលទ (អ្នក-ស្រុកហៅថា ទ្វេកហ្វ) ដែលមានចម្លាក់រូបសំណាកនៅតាមទិសទាំងបួន។ មិនតែប៉ុណ្ណោះ អ្នកស្រុកក្មេងចាស់លេងជះទឹកដាក់គ្នាទៅវិញទៅមក ខ្លះច្រៀង ខ្លះរាំ សប្បាយក្អាកក្អាយ ហាក់ដូចជាកំពុងភ្លៀងធ្លាក់មកមែនទែន។




នៅដើមឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាបានសហការជាមួយក្រុមការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានរៀបចំបង្កើត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគេហទំព័រ www.angkor.com.kh ដើម្បីឆ្លើយតបតម្រូវការរបស់ភ្ញៀវទេសចរដែលចង់ស្វែងយល់អំពីសក្តានុពល ព្រឹត្តិការណ៍ សកម្មភាពទេសចរណ៍នានានៅក្នុងរមណីយដ្ឋានអង្គរបច្ចុប្បន្ន។ លើសពីនេះ គេហទំព័រទេសចរណ៍មួយនេះផ្តល់ឱកាសឱ្យភ្ញៀវទេសចរសាកសួរព័ត៌មានបន្ថែម និងផ្តល់យោបល់ដើម្បីចូលរួមការងារអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។






ដើម្បីឱ្យភ្ញៀវទេសចរកម្សាន្តលេងក្នុងរមណីយដ្ឋានអង្គរ និងទទួលបានបទពិសោធន៍ថ្មីៗ អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យមានអ្នកវិនិយោគផ្នែកសកម្មភាពកម្សាន្ត ដែលមានដូចជា៖ ការជិះដំរី ការជិះទូកនៅកសិន្ធុអង្គរធំ ជិះខ្សែយោងនៅក្នុងព្រៃឈើ និងការជិះបាឡុងនៅខាងលិចប្រាសាទអង្គរវត្ត

# ការអភិវឌ្ឍវិស័យទេសចរណ៍ ក្នុងតំបន់រមណីយដ្ឋានអង្គរ

កម្ពុជាជាប្រទេសមួយដែលគេទទួលស្គាល់ថាសម្បូរទៅដោយសម្បត្តិបេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ បើតាមការចាត់ថ្នាក់របស់ក្រសួងទេសចរណ៍កម្ពុជា តំបន់សៀមរាប-អង្គរ ត្រូវបានគេចាត់ទុកជាប៉ូលទេសចរណ៍វប្បធម៌យ៉ាងសំខាន់បំផុត ដែលសម្បូរទៅដោយប្រាង្គប្រាសាទបុរាណ ទីបុរាណដ្ឋាន និងបណ្តុំប្រពៃណីទំនៀម-ទម្លាប់ដែលបានរក្សានៅល្អផូរផង់។ ចំនួនភ្ញៀវទេសចរដែលធ្វើដំណើរមកកាន់ប្រទេសកម្ពុជាមានការកើនឡើងគួរឲ្យកត់សម្គាល់។ នៅឆ្នាំ២០១៧ មានភ្ញៀវទេសចរមកប្រទេសកម្ពុជាចំនួន៥,០៥៩,០១០នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៣ មានតែ១១៨,១៨៣នាក់ប៉ុណ្ណោះ។ កំណើនភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជាបានបង្ហាញអំពីសក្តានុពលទេសចរណ៍នៅក្នុងប្រទេស គួបផ្សំជាមួយនឹងសន្តិសុខ និងសុវត្ថិភាពក្នុងប្រទេសផងដែរ។ ទាំងនេះគឺជាសមិទ្ធផលដែលបានកើតចេញពីការដឹកនាំដ៏ឈ្លាសវៃ និងត្រឹមត្រូវរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ការអភិវឌ្ឍវិស័យទេសចរណ៍មកដល់ពេលនេះ គឺចាប់ផ្តើមឡើងពីការដាក់ចេញនូវគោលនយោបាយ "បើកចំហដែនមេឃ" នៅឆ្នាំ១៩៩៧ និង គោលនយោបាយ "ឈ្នះ ឈ្នះ" នៅឆ្នាំ១៩៩៨។

ដោយឡែកនៅក្នុងរមណីយដ្ឋានអង្គរ ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បាននិងកំពុងខិតខំប្រឹងប្រែង រកមធ្យោបាយនានាដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សេវាកម្ម និងបទពិសោធន៍ល្អៗសម្រាប់ភ្ញៀវទេសចរ។ ដើម្បីចូលរួមក្នុងការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរឲ្យមាននិរន្តរភាព អាជ្ញាធរជាតិអប្សរា កំពុងអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដោយស្មារតីទទួលខុសត្រូវខ្ពស់។ ផែនការគ្រប់គ្រងទេសចរណ៍នេះបានរៀបចំឡើងសមស្របនឹងគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១៦-២០២០ របស់ក្រសួងទេសចរណ៍ ដើម្បីចូលរួមទាក់ទាញភ្ញៀវទេសចរឲ្យបាន៧លាននាក់ក្នុងឆ្នាំ២០២០។ ដោយសារមានទស្សនវិស័យច្បាស់លាស់ក្នុងការដឹកនាំ និងអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ អង្គរបានទទួលជ័យលាភីផ្សេងៗ គួរជាទីមោទនៈដូចជា៖

- ArchaeoMadness៖ នៅឆ្នាំ២០១៤ ប្រាសាទអង្គរវត្ត ត្រូវបានវិទ្យាស្ថានបុរាណវិទ្យារបស់សហរដ្ឋអាមេរិក (Archaeological Institute of America) ផ្តល់ចំណាត់ថ្នាក់លេខ១ លើឯក ArchaeoMadness ដែលបានរៀបចំឡើងនៅក្នុងឱកាសប្រារព្ធទិវាបុរាណវិទ្យាអន្តរជាតិ។
- Ultimate Travelist (Lonely Planet)៖ នៅឆ្នាំ២០១៥ ប្រព័ន្ធផ្សព្វផ្សាយ Lonely Planet ក៏បានសម្រេចដាក់អង្គរវត្តក្នុងបញ្ជី Ultimate Travel List ជាគោលដៅសម្រាប់ភ្ញៀវទេសចរទស្សនាក្នុងចំណាត់ថ្នាក់លេខ១ ក្នុងចំណោមគោលដៅទស្សនាទាំង១០លើពិភពលោក។
- Tripadvisor៖ នៅឆ្នាំ២០១៥ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ អង្គរវត្តត្រូវបានបណ្តាញផ្សព្វផ្សាយ TripAdvisor ផ្តល់ចំណាត់ ថ្នាក់លេខ១ ក្នុងចំណោមគោលដៅទស្សនាល្បីៗទាំងឡាយលើពិភពលោក។






## ទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ

អង្គរគឺជាគោលដៅទេសចរណ៍ដ៏សំខាន់មួយសម្រាប់ភ្ញៀវទេសចរដែលមានបំណងស្វែងយល់ ស្រាវជ្រាវ និងទទួលបានបទពិសោធន៍អំពីវប្បធម៌ និងអរិយធម៌ខ្មែរ ដែលសព្វថ្ងៃនេះ មានភ្ញៀវទេសចររាប់លាននាក់មកពីប្រទេសផ្សេងៗលើសកលលោកមកទស្សនា។ ប្រមាណជា៣០% នៃភ្ញៀវទេសចរដែលមកទស្សនាអង្គរ គឺជាប្រភេទភ្ញៀវក្រុម ហើយស្នាក់នៅខេត្តសៀមរាបប្រហែល ៣ថ្ងៃជាមធ្យម។ នៅឆ្នាំ២០១៧ មានភ្ញៀវទេសចរបរទេសសរុបចំនួន២,៤៩៧,០២៣នាក់ ចំណាយទឹកប្រាក់ ១០៧,៩៧៦,២៣៩លានដុល្លា លើសំបុត្រទស្សនាអង្គរ ដែលកើនឡើង ៧៦,៥៤% បើប្រៀបធៀបនឹងឆ្នាំ២០១៦។ កំណើននេះជួយជំរុញបន្ថែមលើការអភិវឌ្ឍទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ ក៏ដូចជាចូលរួមចំណែកក្នុងការអភិរក្សប្រាសាទបុរាណ និងកំពុងផ្តល់នូវឱកាសក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ប្រជាជន ដែលរស់នៅក្នុងរមណីយដ្ឋានអង្គរផងដែរ។

យ៉ាងណាមិញ អាជ្ញាធរជាតិអប្សរានៅតែបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ក្នុងពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត។ ដំណោះស្រាយទាំងនោះរួមមាន ការអនុវត្តផែនការសកម្មភាព អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់បម្រើភ្ញៀវទេសចរ និងពង្រឹងគុណភាពសេវាកម្មឲ្យកាន់តែប្រសើរក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ចំពោះរមណីយដ្ឋានអង្គរឲ្យនៅកម្រិតទាបបំផុត ការផ្តល់បទពិសោធន៍ទស្សនាប្រកបដោយគុណភាពជូនភ្ញៀវទេសចរ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរ។

## ផែនការគ្រប់គ្រងទេសចរណ៍ និងគោលនយោបាយ

យោងតាមការស្នើឡើងរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលដើម្បីការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ហៅកាត់ថា អាយស៊ីស៊ី ICC នៅចុងឆ្នាំ២០១០ គណៈកម្មាធិការនេះបានតម្រូវឲ្យអាជ្ញាធរជាតិអប្សរារៀបចំជាផែនការគ្រប់គ្រងទេសចរណ៍ (Tourism Management Plan, TMP) ដែលជាផ្នែកមួយរួមបញ្ចូលក្នុងក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ (Angkor Heritage Management Framework, AHMF)។ ផែនការគ្រប់គ្រងទេសចរណ៍បានសិក្សា និងរៀបចំឡើងក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរាជាមួយក្រសួងទេសចរណ៍ដែលគាំទ្រ ដោយរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលី និងអង្គការយូណេស្កូ។ នៅឆ្នាំ២០១៣ ផែនការគ្រប់គ្រងទេសចរណ៍នេះ ត្រូវបានចុះហត្ថលេខា និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយសម្តេចវិបុលបញ្ញា **សុខ អាន** ពេលនោះជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា ហើយនៅចុងឆ្នាំ២០១៣ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាបានចេញសេចក្តីសម្រេចលេខ៣៦សសរ បង្កើតក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដើម្បីអនុវត្តផែនការគ្រប់គ្រងទេសចរណ៍នៅរមណីយដ្ឋានអង្គរឲ្យមានប្រសិទ្ធភាពខ្ពស់។

## សមិទ្ធផលទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ

### ការគ្រប់គ្រងភ្ញៀវក្នុងរមណីយដ្ឋានអង្គរ




ដើម្បីសម្រួលដល់ការធ្វើចរាចរ និងកាត់បន្ថយការកកស្ទះយានយន្ត ភាពរញ៉េរញ៉ៃ ក៏ដូចជាកាត់បន្ថយផ្សែងពុលចេញពីយានយន្តដែលប៉ះពាល់ដល់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសិក្សាអំពីចំនួនយានយន្ត និងប្រភេទមធ្យោបាយធ្វើដំណើរក្នុងរមណីយដ្ឋាន រួចបានដាក់ផែនការ និងបានអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- ហាមឃាត់រថយន្តលើសពី២៥កៅអីមិនឲ្យចរាចរតាមវង់តូចនិងវង់ធំក្នុងរមណីយដ្ឋានអង្គរ។
- កាត់បន្ថយការកកស្ទះនៅត្រង់ខ្លោងទ្វារទន្លេអុំនៅពេលព្រឹក តាមរយៈការអនុញ្ញាតតែចរាចរឯកទិសពីត្បូងទៅជើង ចាប់ពីម៉ោង៧កន្លះព្រឹក ដល់ ១១កន្លះព្រឹក។
- លើកទឹកចិត្តអ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយកង់ តាមរយៈការរៀបចំឲ្យមានផ្លូវជិះកង់។
- បានរៀបចំកន្លែងដាក់ភ្ញៀវ Drop off នៅមុខខាងលិចប្រាសាទអង្គរវត្ត។
- បានបិទផ្លូវមុខខាងលិចប្រាសាទអង្គរវត្ត (ផ្លូវអក្សរ T) ដើម្បីសម្រួលដល់ភ្ញៀវទេសចរថ្មើរជើងពីចំណតរថយន្តដើរឆ្ពោះទៅមុខខាងប្រាសាទអង្គរវត្ត។


















ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត







ប្រារព្ធខួប២៥ឆ្នាំរបស់រមណីយដ្ឋានអង្គរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក © UYFC APSARA Authority 201

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររំឭកខួប២៥ឆ្នាំ នៃការចុះរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។ នៅក្នុងព្រឹត្តិការណ៍នោះ មានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់បំផុតពីលោកជំទាវ កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងលោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា។




© UYFC APSARA

## ទិវាយោគៈអន្តរជាតិ

ជារៀងរាល់ឆ្នាំនៅខែមិថុនា អាជ្ញាធរជាតិអប្សរាតែងតែសហការជាមួយក្រសួងទេសចរណ៍កម្ពុជា និងស្ថានទូតឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជារៀបចំព្រឹត្តិការណ៍ទិវាយោគៈអន្តរជាតិនៅមុខខាងលិចប្រាសាទអង្គរវត្ត។


© SOK-SANGVAR


© SOK-SANGVAR

## កីឡារត់ម៉ារ៉ាតុងអន្តរជាតិ

រាល់ចុងឆ្នាំ អាជ្ញាធរជាតិអប្សរាសហការជាមួយក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រៀបចំកីឡារត់ម៉ារ៉ាតុងអន្តរជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែមមកខេត្តសៀមរាប។


© SOK-SANGVAR



© SOK-SANGVAR

## ទីលាន Parvis ប្រាសាទបន្ទាយស្រី

ទីលាន Parvis ប្រាសាទបន្ទាយស្រី ជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការទ្វេភាគីរយៈពេល០២ឆ្នាំ គឺពីឆ្នាំ២០០៨ ដល់២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលស្វីស ដោយមានអាជ្ញាធរជាតិអប្សរា និងគម្រោងអភិរក្សប្រាសាទបន្ទាយស្រី (BSCP : Banteay Srei Conservation Project) ជាសេនាធិការអនុវត្តការងារផ្ទាល់លើការដ្ឋាន។

គោលបំណងនៃការរៀបចំទីលាន Parvis ប្រាសាទបន្ទាយស្រីនេះឡើង គឺសំដៅចម្បងលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបដិសណ្ឋារកិច្ចសម្រាប់ទេសចរ ការគ្រប់គ្រងលំហូរភ្ញៀវទេសចរ ដើម្បីកាត់បន្ថយការកកស្ទះក្នុងប្រាសាទ ក្នុងន័យលើកកម្ពស់គុណភាពនៃការទស្សនា។ មិនត្រឹមតែប៉ុណ្ណោះ ការរៀបចំទីលាន Parvis នេះ រួមចំណែកយ៉ាងធំធេងក្នុងការអភិរក្ស និងថែរក្សាសម្បត្តិបេតិកភណ្ឌ និងលើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិជុំវិញប្រាសាទ ព្រមទាំងបង្កើនការចូលរួមពីសហគមន៍ម្ចាស់ស្រុកក្នុងវិស័យទេសចរណ៍ សំដៅរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ក្នុងកិច្ចសហប្រត្តិបត្តិការលើការងាររៀបចំទីលានប្រាសាទបន្ទាយស្រីនេះ រដ្ឋាភិបាលប្រទេសស្វីស ទទួលបន្ទុកសាងសង់អគារបដិសណ្ឋារកិច្ច និងអគារពិព័រណ៍ ដោយមានបំពាក់ផ្ទាំងព័ត៌មានក្នុងអគារ។ រាល់កិច្ចការផ្សេងៗទៀត ដូចជាការដោះស្រាយដីធ្លី ការសាងសង់ផ្លូវដើរ ការរៀបចំចំណតយានយន្ត ការរៀបចំកន្លែងលក់ដូរ បង្គន់អនាម័យ ការរៀបចំទេសភាព ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ការរៀបចំសហគម៍ ស្លាកសញ្ញាផ្សេងៗ និងការងារគ្រប់គ្រងដំណើរការនៃទីលាន Parvis ទាំងមូល ព្រមទាំងប្រាសាទផ្ទាល់ ជាភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា។

បន្ទាប់ពីសាងសង់ និងរៀបចំរួចរាល់នូវហេដ្ឋារចនាសម្ព័ន្ធ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ទីលាន Parvis ប្រាសាទបន្ទាយស្រីនេះត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលបញ្ញា **សុខ អាន** ឯកអគ្គរដ្ឋទូតប្រទេសស្វីសប្រចាំប្រទេសកម្ពុជា និងលោកជំទាវ លោកនាយកប្រត្តិបត្តិនៃអង្គការយូណេស្កូ ព្រមទាំងលេខាធិការវិទ្យាសាស្ត្រនៃ ICC ផងដែរ។

បច្ចុប្បន្ននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌទទួលបន្ទុកគ្រប់គ្រងដំណើរការនៃទីលាន Parvis ប្រាសាទបន្ទាយស្រីនេះ ដោយបានរៀបចំឲ្យមានបុគ្គលិកប្រចាំការនៅកន្លែងផ្តល់ព័ត៌មាន កន្លែងផ្ញើអីវ៉ាន់ កន្លែងសង្គ្រោះបឋម និងអគារពិព័រណ៍ ព្រមទាំងក្រុមកម្មករ ដើម្បីសម្អាត និងថែទាំសួនជាប្រចាំ។ ជារៀងរាល់ថ្ងៃ ជាមធ្យមមានភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិចំនួន១៦០០នាក់ បានឈប់សម្រាក និងប្រើប្រាស់ សេវាកម្មទាំងឡាយក្នុងមជ្ឈមណ្ឌលបដិសណ្ឋារកិច្ច មុននឹងចូលទៅទស្សនាប្រាសាទបន្ទាយស្រី។










## សារមន្ទីរក្នុងកិច្ចអភិរក្ស

ចាប់ពីការបង្កើតអាជ្ញាធរជាតិអប្សរាក្នុងឆ្នាំ១៩៩៥មក ស្ថាប័នជាតិនេះមានតួនាទីស្នូលក្នុងការស្រាវជ្រាវ និង អភិរក្សបេតិកភណ្ឌរូបី និងអរូបីនៅក្នុងតំបន់សៀមរាប-អង្គរទាំងមូល។

តើបេតិកភណ្ឌដូចជា រូបចម្លាក់ បដិមា វត្ថុសិល្បៈ ប្រពៃណី ជំនឿ ដែលបានរកឃើញមកពីការធ្វើកំណាយ និងការស្រាវជ្រាវទាំងអស់នោះ ត្រូវយកទៅផ្ទុកសុល ថែរក្សា និងធ្វើឲ្យមានវិញ្ញាណឡើងវិញនៅទីណា និង កន្លែងណា?

សារមន្ទីរ គឺជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ ដែលប្រមូល អភិរក្ស ស្រាវជ្រាវ ផ្សព្វផ្សាយ និងតាំង បង្ហាញបេតិកភណ្ឌរូបី និងអរូបីរបស់មនុស្សជាតិ ក្នុង គោលបំណងផ្តល់នូវការសិក្សា អប់រំ និងកម្សាន្តដល់ សាធារណៈជនគ្រប់រូប។

ចាប់តាំងពីឆ្នាំ១៩៩៧ កម្ពុជាបានក្លាយជាសមាជិក នៃក្រុមប្រឹក្សាអន្តរជាតិសារមន្ទីរ (International Council of Museums = ICOM)។ ស្ថាប័ន ICOM នេះមាន សមាជិកចំនួនជាង៦០០០០ មកពី១៦១ប្រទេស និង ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស ប្រទេសបារាំងក្នុង ឆ្នាំ១៩៤៦ ក្នុងបំណងស្រាវជ្រាវ អភិរក្ស និងផ្សព្វផ្សាយ បេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌រូបី និងអរូបី។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវចក្ខុវិស័យក្នុង ការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុង រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានខិតខំស្វែង រកកិច្ចសហការពីបណ្តាប្រទេសជាមិត្តឬក្រុមហ៊ុនឯកជន នានាដោយបង្កើតបានសារមន្ទីរមួយចំនួនរួមមាន៖





## សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ត្រូវបានកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ដោយមូលនិធិនៃក្រុម១% របស់ក្រុមហ៊ុនអ៊ីអុង (AEON) នៃប្រទេសជប៉ុន ដើម្បីដាក់តាំងនិងតម្កល់វត្ថុបុរាណដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវនៅប្រាសាទបន្ទាយក្តី។



ព្រះករុណាព្រះបាទ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាយាងដឹកនាំសម្ពោធសារមន្ទីរ

© APSARA

ចាប់តាំងពីបើកដំណើរការទទួលភ្ញៀវទស្សនាក្នុងឆ្នាំ-២០០៨ មកសារមន្ទីរបានពង្រីកការតាំងពិព័រណ៍សមុច្ច័យរបស់ខ្លួនជាបន្តបន្ទាប់ និងបានក្លាយជាឃ្លាំងស្តុក និងអភិរក្សវត្ថុសិល្បៈដែលបានរកឃើញជាបន្តបន្ទាប់នៅក្នុងតំបន់សៀមរាប-អង្គរទាំងមូល។ សព្វថ្ងៃនេះសារមន្ទីរមានពិព័រណ៍អចិន្ត្រៃយ៍ចំនួនបី ដែលសុទ្ធសឹងជាលទ្ធផលនៃកំណាយស្រាវជ្រាវក្នុងតំបន់អង្គរ។

នៅឆ្នាំ២០០៥ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបានធ្វើកំណាយនៅប្រាសាទតោកប៉ាទ្រី និង បានរកឃើញភាជន៍ជាង ៦០ ព្រមទាំងវត្ថុសិល្បៈផ្សេងៗទៀត។ កុលាលភាជន៍ដែលកំណាយបានជាប្រភេទវត្ថុដែលអ្នកស្រុកប្រើបញ្ចុះអដ្ឋិធាតុ។ ភាជន៍ខ្លះនាំចូលមកពីប្រទេសចិន ជប៉ុន និងថៃ ហើយខ្លះទៀតជាភាជន៍ក្នុងស្រុក។

តាមការវិភាគកាលបរិច្ឆេទវិទ្យុសកម្មកាបូន ភាជន៍ទាំងនេះមានអាយុកាលចាប់ពី ស.វទី ១៥ - ១៧ នៃគ.ស ប៉ុន្តែការប្រើប្រាស់ភាជន៍ទាំងអស់ មានអាយុកាលចាប់ពីចុងស.វទី ១៥ - ១៩ នៃគ.ស។



ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ យាងទស្សនាសារមន្ទីរ

© APSARA



### ពិព័រណ៍ព្រះពុទ្ធបដិមា (ប្រាសាទបន្ទាយក្តី)







នៅឆ្នាំ២០០០ និង ២០០១ សាកលវិទ្យាល័យសូហ្វីយ៉ា និងបុរាណវិទូខ្មែរ បានធ្វើកំណាយសិក្សាស្រាវជ្រាវនៅប្រាសាទបន្ទាយក្តី ហើយបានប្រទះឃើញរូបចម្លាក់ចំនួន ២៧៨បំណែក ដែលកប់ក្នុងរណ្តៅតែមួយ។ រូបចម្លាក់ទាំងនេះ ជាភស្តុតាងបញ្ជាក់ពីព្រឹត្តិការណ៍ដ៏គួរឲ្យកត់សម្គាល់មួយទាក់ទងនឹងព្រះពុទ្ធសាសនាសម័យអង្គរ។ ពុទ្ធបដិមាទាំងនេះមានសម័យកាលខុសៗគ្នា ហើយឆ្លុះបញ្ចាំងពីការវិវត្តនៃសិល្បៈព្រះពុទ្ធសាសនាខ្មែរ។

### ពិព័រណ៍ទីតាំងកប់សព (កោះតាមាស និងព្រៃក្មេង)

កោះតាមាសជាទីទួលធំមួយដែលមានផ្ទៃរាបស្មើ ស្ថិតនៅចម្ងាយ១៣០០ម ខាងលិចប្រាសាទមេបុណ្យក្នុងបាតបារាយណ៍ទឹកថ្លាដ៏ធំល្វឹងល្វើយ។ ដំណើរការសិក្សានៅកោះតាមាសនេះ នាំឲ្យគេរកឃើញតឹកតាងនៃការតាំងភូមិករនៅយុគសំរិទ្ធក៏ដូចជាសម្គាល់ឃើញទីកប់សពបុរាណមួយដែលអាចមានអាយុកាលប្រហែល៣ ០ ០ ០ ឆ្នាំមុន។ ការធ្វើកំណាយក្នុងឆ្នាំ២០០៤-២០០៥ ដែលមានការចូលរួមពីក្រុមកំណាយបុរាណវិទូខ្មែរ និងបារាំង បានរកឃើញកុលាលភាជន៍ល្អវិចិត្រ គ្រឿងអលង្ការ ឧបករណ៍ប្រើប្រាស់ ឆ្អឹងសត្វចតុប្បាទ និងឆ្អឹងត្រី ដែលកប់នៅជាមួយសពជាច្រើន។ រីឯព្រៃក្មេង ជាឈ្មោះប្រាសាទឥដ្ឋតូចមួយនៅក្បែរទំនប់ខាងលិច នៃបារាយណ៍ទឹកថ្លា ដែលនៅទីនោះគេបានរកឃើញកន្លែងកប់សពបុរាណ និងភូមិករបុរាណ។







### ពិព័រណ៍ភាជន៍ដាក់ធាតុ (ប្រាសាទតោកប៉ាទ្រី)

នៅឆ្នាំ២០០៥ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបានធ្វើកំណាយនៅប្រាសាទតោកប៉ាទ្រី និងបានរកឃើញភាជន៍ជាង៦០ ព្រមទាំងវត្ថុសិល្បៈផ្សេងៗទៀត។ កុលាលភាជន៍ដែលធ្វើកំណាយបាន ជាប្រភេទវត្ថុដែលអ្នកស្រុកប្រើបញ្ចុះអដ្ឋិធាតុ។ ភាជន៍ខ្លះនាំចូលមកពីប្រទេសចិន ជប៉ុន និងថៃ ហើយខ្លះទៀតជាភាជន៍ក្នុងស្រុក។ តាមការវិភាគកាលបរិច្ឆេទវិទ្យុសកម្មកាបូន ភាជន៍ទាំងនេះមានអាយុកាលចាប់ពី ស.វទី ១៥ - ១៧ នៃគ.ស ប៉ុន្តែការប្រើប្រាស់ភាជន៍ទាំងអស់មានអាយុកាលចាប់ពីចុង ស.វទី១៥-១៩នៃ គ.ស។








## សារមន្ទីរសព្វទស្សន៍អង្គរ

សព្វទស្សន៍អង្គរគឺជាសារមន្ទីរគំនូរជាំវិចិត្រខ្នាតធំក្នុងទម្រង់៣៦០ដឺក្រេ ដែលមានលក្ខណៈទំនើបស្តង់ដារអន្តរជាតិនៅតំបន់អាស៊ី ដែលបង្ហាញពីប្រវត្តិសាស្ត្រខ្មែរនាសម័យអង្គរ ជាពិសេសក្រោមរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧។ ឈរនៅលើទីទួលខ្ពស់ ហាក់ដូចជានៅលើកំពូលភ្នំបាខែង អ្នកទស្សនាអាចចោលចក្ខុជុំវិញខ្លួនរំពៃមើលទស្សនីយភាពដ៏រស់រវើកនៃយុទ្ធសាស្ត្រធ្វើសឹកសង្គ្រាមរវាងកងទ័ពខ្មែរ និងចម្ប៉ា វិធីសាស្ត្រក្នុងការកសាងប្រាសាទ និងជីវភាពរស់នៅសម្បូរណ៍សប្បាយរបស់ប្រជាជននាសម័យអង្គរដ៏រុងរឿង។






## សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា ប្រទេសទាំង០៦ គឺ កម្ពុជា ថៃ ឡាវ វៀតណាម ភូមា និងឥណ្ឌា បានរួមកម្លាំងគ្នាជាធ្លុងមួយ ដើម្បីបង្កើតសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី នៅក្នុងឆ្នាំ២០១០ ក្រោមជំនួយរបស់រដ្ឋាភិបាលឥណ្ឌានៅលើផ្ទៃដីទំហំ០១ ហិកតា ដែលផ្តល់ជូនដោយអាជ្ញាធរជាតិអប្សរា។

សារមន្ទីរនេះស្ថិតនៅចំកណ្តាលបេះដូងនៃមជ្ឈមណ្ឌលទេសចរណ៍និងវប្បធម៌ និងមានសាលពិព័រណ៍ធំៗចំនួន០៤ ដែលតាំងបង្ហាញអំពីវត្ថុធាតុដើម គ្រឿងបរិក្ខារប្រើប្រាស់ ដំណើរការផលិត សមុច្ច័យវាយនភណ្ឌបុរាណ និងសហសម័យ ដែលបានផ្តល់ និងរៀបចំឡើងដោយប្រទេសនីមួយៗ។










## សារមន្ទីរកុលាលភាជន៍ភូមិតានី

ចាប់តាំងពីឆ្នាំ១៩៩៦ ដល់២០០០ អាជ្ញាធរជាតិអប្សរា បានសហការជាមួយវិទ្យាស្ថានណារ៉ា និងសាកលវិទ្យាល័យសូហ្វីយ៉ា បានធ្វើកំណាយស្រាវជ្រាវស្តីពីរចនាសម្ពន្ធឡ ដំណើរការឡបុរាណ និងផលិតផលកុលាលភាជន៍នៅភូមិតានី ដែលស្ថិតក្នុងឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ក្នុងតំបន់ភ្នំបូកប្រមាណ៦០គ.ម ពីប្រាសាទអង្គរវត្ត។ ក្រុមអ្នកស្រាវជ្រាវបានប្រទះឃើញកុលាលភាជន៍ជាច្រើនប្រភេទដូចជា កុលាលភាជន៍មានស្រទាប់រលោង កុលាលភាជន៍គ្មានស្រទាប់រលោង គ្រឿងសម្រាប់ប្រក់ គ្រឿងសម្រាប់ត្រដំបូល គ្រឿងដំស្នួរជាដើម។




ដើម្បីលើកតម្លៃវត្ថុបុរាណ និងស្នាដៃសិល្បៈទាំងនោះ ទើបនៅឆ្នាំ២០០៦ អាជ្ញាធរជាតិអប្សរា បានសហការជាមួយស្ថានទូតជប៉ុន ប្រចាំនៅកម្ពុជា ដើម្បីធ្វើការសាងសង់សារមន្ទីរកុលាលភាជន៍នៅភូមិតានី ដែលជាផ្នែកមួយនៃគម្រោងឡបុរាណវិទ្យានៅភូមិតានី លើផ្ទៃដី ៣៤.១០ ហិចតា ដើម្បីអាចឲ្យភ្ញៀវជាតិ និងអន្តរជាតិ អាចទស្សនាឡបុរាណទាំងមូល និងដើម្បីពង្រីកគម្រោងភូមិជម្ពូជាតិទេសាឯក។


ការស្រាវជ្រាវឡបុរាណ និងវត្ថុសិល្បៈដែលរកឃើញ



ស្ពានបណ្តែតទឹក

© PHANG


ប្រព័ន្ធធារាសាស្ត្រអង្គរ
Angkor Hydraulic Network
Tonlé Sgnuot
PREAH KHAN
NEAK PEAN
BANTEAY SREI
Phnom Kulen
ANGKOR THOM
Phnom Dei
WEST MEBON
TA KEO
EAST MEBON
Pourk River
PHNOM BOK
PHNOM BAKENG
Srah Srang
CHAO SREI VIBOL
TA PROHM
Siem Reap River
BANTEAY KDEI
LOLEI
ANGKOR WAT
PREAH KO
PHNOM KROM
BAKONG
Roluos River
Tonlé Sap Lake




## ការធ្វើឲ្យប្រសើរឡើងវិញ នូវប្រព័ន្ធធារាសាស្ត្រសម័យបុរាណ

ការស្តារឲ្យប្រសើរឡើងវិញនូវប្រព័ន្ធធារាសាស្ត្រសម័យបុរាណ គឺជាការងារប្រឈមដ៏ចម្បងមួយក្នុងចំណោមការងារប្រឈមដទៃទៀតក្នុងរមណីយដ្ឋានអង្គរ។ កិច្ចការនេះមិនត្រឹមតែជាកង្វល់សម្រាប់ការអភិរក្សប្រាង្គប្រាសាទ និងការអភិវឌ្ឍប្រកបដោយចីរភាពនៃរមណីយដ្ឋានអង្គរប៉ុណ្ណោះទេ តែក៏ជាបញ្ហាប្រឈមក្នុងការរក្សាគុណភាពទឹកនៅក្នុងតំបន់សៀមរាបទាំងមូល ព្រោះកំណើនដ៏ឆាប់រហ័សនៃចំនួនភ្ញៀវទេសចរ និងប្រជាជន។ ដំណោះស្រាយគន្លឹះជាចាំបាច់ក្នុងការឆ្លើយតបតម្រូវការក្នុងការប្រើប្រាស់ទឹកប្រចាំថ្ងៃ និងការធានាឲ្យមានស្ថិរភាពចំពោះប្រាង្គប្រាសាទ ដែលសាងសង់នៅលើគ្រឹះខ្សាច់ គឺពង្រីកលទ្ធភាពរក្សាទុកនៅតាមទីតាំងរក្សាទុកសំខាន់ៗក្នុងរមណីយដ្ឋានអង្គរ។

ដើម្បីអនុវត្តនូវផែនការពង្រីកលទ្ធភាពរក្សាទឹកឲ្យបានកម្រិតខ្ពស់បំផុតដែលអាចទៅបាន អាជ្ញាធរជាតិអប្សរាបានធ្វើការវិភាគតាមបែបវិទ្យាសាស្ត្រអំពីប្រភពដើមដែលចេញពីអាងផ្ទុកទឹកភ្លៀងនៅលើភ្នំគូលែន រហូតដល់កន្លែងដែលទឹកហូរចាក់ទៅក្នុងបឹងទន្លេសាប។ ពុំមានសិលាចារឹកណាមួយនាសម័យអាណាចក្រខ្មែរ បានលើកឡើងពាក់ព័ន្ធនឹងបញ្ហាទឹកជំនន់ ឬភាពរាំងស្ងួតឡើយ ហើយប្រជាជនខ្មែរក៏មិនបាននិទានតគ្នាតាមរយៈរឿងព្រេង ឬការចងចាំពីជំនាន់មួយទៅជំនាន់មួយអំពីគ្រោះធម្មជាតិណាមួយនោះដែរ។ តាមរយៈនេះ គេអាចសន្និដ្ឋានថា បញ្ហាទាំងនេះពុំមានកើតឡើងទេនាសម័យអតីតកាល ព្រោះប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រសម័យបុរាណ មានលទ្ធភាពគ្រប់គ្រងទឹកបានយ៉ាងល្អប្រសើរបំផុត។ ការសន្និដ្ឋាននេះគឺចាប់ផ្តើមពីការពិនិត្យតាមបែបធម្មជាតិនិងវិទ្យាសាស្ត្រនៃលំហូរទឹក និងបណ្តាញតភ្ជាប់គ្នាជាទូទៅរវាងប្រព័ន្ធធារាសាស្ត្រក្នុងរមណីយដ្ឋានអង្គរ រួមមានផ្លូវទឹកហូរតាមស្ទឹងពួកនៅផ្នែកខាងលិច ស្ទឹងសៀមរាបនៅផ្នែកកណ្តាល និងស្ទឹងរលួសនៅផ្នែកខាងកើត បារាយណ៍ កសិន្ធុទឹក អូរ អាងទឹក និងប្រឡាយទឹកតូចធំខ្វាត់ខ្វែងផ្សេងៗ។ តាមការពិនិត្យច្បាស់លាស់ ស្ទឹងពួកនិងស្ទឹងរលួស គឺជាស្ទឹងដែលកើតមានតាមលក្ខណៈធម្មជាតិ ចំណែកឯស្ទឹងសៀមរាបវិញហាក់ដូចជាផ្លូវទឹកសិប្បនិម្មិត ព្រោះស្ទឹងនេះត្រូវបានបង្កើតឡើងដើម្បីពង្វាងទឹកពីភ្នំគូលែន ដោយមានការសាងសង់សំណង់បង្វែរទឹកអំពីថ្មបាយក្រៀមនៅសតវត្សទី៩ នៅភូមិបំពេញរាជ្យដែលមានទទឹង៦០ម៉ែត្រ និងបណ្តោយ៣០០ម៉ែត្រ។




ក្នុងជំហានបន្ទាប់ អាជ្ញាធរជាតិអប្សរាបានចំណាយពេលសិក្សាស្រាវជ្រាវជាក់ស្តែងអំពីប្រព័ន្ធធារាសាស្ត្របុរាណរយៈពេល៨ឆ្នាំ។ ក្នុងរយៈពេលនៃការសិក្សាបានបង្ហាញថា ផ្នែកខាងជើងឆៀងខាងកើតនៃបារាយណ៍ខាងជើង មានទំនប់មួយដែលគេសង់ក្នុងទិសពីកើតទៅលិច និងមានស្ពានបុរាណមួយធ្វើពីថ្មបាយក្រៀមដែលមានប្រឡោះបង្ហូរទឹកជាច្រើនសង់លើស្ទឹងសៀមរាប អាចត្រូវបានប្រើប្រាស់សម្រាប់លំហូរទឹក និងគ្រប់គ្រងទ្វារទឹក។ ដោយសារប្រព័ន្ធចែកចាយនិងអូរប្រទាក់ក្រឡាគ្នាជាច្រើននេះហើយ ទើបការបង្វែរទឹកទៅទិសខាងលិច (បារាយណ៍ខាងជើង បារាយណ៍ខាងលិច និងស្ទឹងពួក) ទៅទិសខាងកើត (ស្ទឹងរលួស) និងទិសខាងត្បូង (កសិន្ធុទឹកទីក្រុងអង្គរធំ កសិន្ធុទឹកប្រាសាទអង្គរវត្ត និងស្ទឹងសៀមរាប) អាចធ្វើឡើងបានដោយរលូនពុំមានឧបសគ្គអ្វីទាំងអស់។

ឆ្លងកាត់ការវិភាគទិន្នន័យដំបូង និងការសន្និដ្ឋានវិទ្យាសាស្ត្រនៃទឹកជំនន់ឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១ អាជ្ញាធរជាតិអប្សរាបានអនុវត្តនូវការងារជាក់ស្តែងចាំបាច់មួយចំនួនដូចជា ការជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរឲ្យដំណើរការឡើងវិញជាស្ថាពរ។ ជាពិសេស នៅឆ្នាំ២០១២ ផ្នែកដ៏សំខាន់នៃប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរត្រូវបានស្តារឡើងវិញ ដែលការស្តារនេះធ្វើឲ្យរមណីយដ្ឋានអង្គរនិងទីក្រុងសៀមរាបទាំងមូលបានចៀសផុតពីការរងគ្រោះទឹកជំនន់។ ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរ មិនត្រឹមតែអាចគ្រប់គ្រងនូវធនធានទឹកបានយ៉ាងល្អប៉ុណ្ណោះទេ តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់បានទៀតផង។

### កសិន្ធុទឹកទីក្រុងអង្គរ

កសិន្ធុនេះជាអាងស្តុកទឹកដ៏ធំមួយ ដែលមានប្រវែង១៦គីឡូម៉ែត្រព័ទ្ធជុំវិញទីក្រុងអង្គរធំ និងអាចផ្ទុកទឹកបានជិត២លានម៉ែត្រគូប។ កាលពីពេលមុន មានតែផ្នែកខាងត្បូងឆៀងខាងលិចប្រវែងប្រមាណ៣គីឡូម៉ែត្រប៉ុណ្ណោះដែលអាចរក្សាទឹកបាន ខណៈផ្នែកខាងត្បូងឆៀងខាងកើតពុំមានទឹកទាល់តែសោះក្នុងរដូវប្រាំង។ បន្ទាប់ពីធ្វើការជួសជុលលើកទី១ កំណាត់នៃកសិន្ធុផ្នែកខាងត្បូងឆៀងខាងកើតប្រវែង៣គីឡូម៉ែត្រ អាចរក្សាទឹកបានពេញមួយឆ្នាំ ទាំងរដូវប្រាំងនិងរដូវវស្សា។ ក៏ប៉ុន្តែចាប់ពីឆ្នាំ២០១២មក កសិន្ធុទឹកទីក្រុងអង្គរធំទាំងមូលប្រវែង១៦គីឡូម៉ែត្រ ត្រូវបានជួសជុលរួចរាល់ទាំងស្រុង និងអាចរក្សាទឹកបានពេញក្នុងមួយឆ្នាំជាប្រចាំឡើងវិញ។






## ស្រះស្រង់



ស្រះស្រង់មានទឹកដោយសារទឹកភ្លៀង និងទឹកជ្រាបពីក្រោមដីចេញពីបារាយណ៍ខាងកើត និងទឹកក្រោមដីដែលនៅជុំវិញស្រះនោះ។ ប៉ុន្តែដោយសារបារាយណ៍ខាងកើតរីងស្ងួត ហួតហែងអស់ទៅហើយ និងដោយសារកម្រិតទឹកក្រោមដីបានស្រកចុះ ទឹកក្នុងស្រះស្រង់ក៏បានចាប់ផ្តើមរីងស្ងួតដែរនៅរដូវប្រាំង រហូតដល់គ្មានទឹកទាល់តែសោះនៅខែមេសា ឆ្នាំ២០០៤ ។ នៅខែមីនា ឆ្នាំ២០០៥ នាយកដ្ឋានគ្រប់គ្រងទឹកបានរៀបចំបង្កើតប្រព័ន្ធបន្ថែមមួយដើម្បីបង្ហូរទឹកចូលក្នុងស្រះស្រង់ដោយយកទឹកចេញពីភ្នំបូកនិងរលួស ។

## កសិន្ធុទឹកប្រាសាទអង្គរវត្ត

មុនឆ្នាំ២០១០ ប្រព័ន្ធបង្ហូរទឹកបំពេញកសិន្ធុទឹកប្រាសាទអង្គរវត្ត គឺមានប្រឡាយមួយដែលគេសាងឡើងនៅចន្លោះកសិន្ធុទឹកទីក្រុងអង្គរធំខាងត្បូងឆៀងខាងលិច រហូតដល់ត្រពាំងសេះ ឆ្លងកាត់ខាងក្រោយកន្លែងបង្ហោះបាឡុងក្នុងសម័យថ្មីនេះ។ បន្ទាប់មកយើងបានស្តារប្រព័ន្ធបុរាណឡើងវិញ ដោយភ្ជាប់កសិន្ធុទឹកទីក្រុងអង្គរធំផ្នែកខាងត្បូងឆៀងខាងកើត ទៅកសិន្ធុទឹកប្រាសាទអង្គរវត្តផ្នែកខាងជើងឆៀងខាងលិចផ្ទាល់ ដោយឆ្លងកាត់តាមកសិន្ធុទឹកភ្នំបាខែង និងអូរសំពៅលូន។ ប្រព័ន្ធនេះបានធ្វើឲ្យកម្រិតទឹកក្នុងកសិន្ធុអង្គរវត្តកើនបានកម្ពស់១ម៉ែត្របើធៀបទៅនឹងកម្រិតទឹកអតិបរិមានៅពេលមុន ។

## បារាយណ៍ខាងជើង

បារាយណ៍នេះមានបណ្តោយ ៣៦០០ម៉ែត្រ និង ទទឹង ៩៣០ម៉ែត្រ និងមានសមត្ថភាពផ្ទុកទឹកពីដំបូងរហូតដល់៥លានម៉ែត្រគូប។ ទឹកនៅក្នុងបារាយណ៍មិនត្រូវបានគេប្រើដើម្បីយកទៅស្រោចស្រពដំណាំដូចទឹកបារាយណ៍ផ្សេងទៀតនៅក្នុងតំបន់នេះឡើយ ប៉ុន្តែគេរក្សាទឹកបារាយណ៍នេះសម្រាប់ប្រើនៅក្នុងទីក្រុងអង្គរធំ ប្រាសាទព្រះខ័ន និងនាគព័ន្ធ។ បារាយណ៍នេះបានរីងស្ងួតហួតហែងអស់ជាង៥០០ឆ្នាំមកហើយ ម្យ៉ាងទៀតអ្នកស្រាវជ្រាវមួយចំនួនមិនគិតថា ការធ្វើឲ្យបារាយណ៍ខាងជើងនេះមានទឹកសាជាថ្មីឡើងវិញ មិនអាចទៅរួចនោះឡើយ។ ប៉ុន្តែនៅឆ្នាំ២០០៧ អ្នកស្រាវជ្រាវខ្មែរបានជួសជុលប្រព័ន្ធបង្ហូរទឹកដែលគេបានរកឃើញនៅឆ្នាំ២០០៥ ហើយនៅឆ្នាំ២០០៨









ទឹកក៏ចាប់ផ្តើមហូរចូលក្នុងបារាយណ៍នេះវិញ។ ការបង្ហូរទឹកចូលបំពេញក្នុងបារាយណ៍ខាងជើងដូចបានធ្វើឡើងដូចតទៅនេះ ៖
ចំនួន៧០០.០០០ ម៉ែត្រគូបនៅឆ្នាំ២០០៨ ចំនួន៣.០០០.០០០ ម៉ែត្រគូបនៅឆ្នាំ២០០៩ ចំនួន៣ ៦៧៥.០០០ ម៉ែត្រគូបនៅឆ្នាំ២០១០ ចំនួន៥.០០០.០០០ម៉ែត្រគូបនៅឆ្នាំ២០១១ និង២០១២ ។

តាំងពីនេះក៏មានទឹកពេញឡើងវិញគ្រប់រដូវដែរ។ អាងទាំងនេះដែលភ្ជាប់ទៅនឹងបារាយណ៍ខាងជើង គឺជាការឆ្លុះបញ្ចាំងយ៉ាងល្អជាងគេអំពីប្រព័ន្ធធារាសាស្រ្តនៅក្នុងឧទ្យានអង្គរដែលបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

## អាងស្តុកទឹកប្រាសាទនាគព័ន្ធ




នាគព័ន្ធ គឺជាប្រាសាទនៅលើកូនកោះតូចមួយ ចំកណ្តាលបារាយណ៍ខាងជើង ប្រៀបដូចជាប្រាសាទមេបុណ្យនៅក្នុងបារាយណ៍ផ្សេងទៀតដែរ ប៉ុន្តែនៅសម័យបុរាណ នាគព័ន្ធមានមុខងារផ្សេងមួយទៀត គឺជាភិជាមន្ទីរពេទ្យដែលប្រើប្រាស់រុក្ខជាតិជាឱសថបុរាណ។ នៅជុំវិញប្រាសាទនេះមានអាងចំនួន៥ ដែលនៅក្នុងសម័យក្រោយមកបានរីងស្ងួតអស់ពេញមួយឆ្នាំ លើកលែងតែអាងកណ្តាលដែលមានទឹក តែរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះក្នុងមួយឆ្នាំនៅរដូវវស្សា។ ប៉ុន្តែចាប់តាំងពីបារាយណ៍ខាងជើងមានទឹកសាជាថ្មី ឡើងវិញមក អាង




## កសិន្ធុទឹកប្រាសាទព្រះខ័ន

នៅក្នុងសម័យបុរាណដូចស្រះស្រង់ដែរ កសិន្ធុទឹកប្រាសាទព្រះខ័នគ្មានប្រព័ន្ធទឹកបង្ហូរចូលបំពេញនោះទេ។ នៅសម័យបច្ចុប្បន្ន កសិន្ធុនេះមានទឹកតែក្នុងមួយរយៈពេលប៉ុណ្ណោះក្នុងមួយឆ្នាំ ប៉ុន្តែតាំងពីបារាយណ៍ខាងជើងមានទឹកសាជាថ្មីឡើងវិញមក កសិន្ធុប្រាសាទព្រះខ័នក៏មានទឹកឡើងវិញពេញមួយឆ្នាំដែរ។ បាតុភូតនេះបង្ហាញថា បារាយណ៍ខាងជើង និងប្រាសាទព្រះខ័នមានទំនាក់ទំនងគ្នាតាមរយៈទឹកក្រោមដី ប៉ុន្តែវាក៏បង្ហាញផងដែរថា កសិន្ធុប្រាសាទព្រះខ័នដែលមានទឹកឡើងវិញនេះ គឺជាលទ្ធផលនៃការកើនឡើងនាំកម្រិតទឹកក្រោមដីដោយសារតែបារាយណ៍ខាងជើងមានទឹកឡើងវិញសាជាថ្មី ។



## បារាយណ៍ខាងលិច

នៅក្នុងសតវត្សទី២០ ដើម្បីបំពេញទឹកក្នុងបារាយណ៍ខាងលិច ទឹកស្ទឹងសៀមរាបត្រូវបានគេបង្វែរទៅនៅត្រង់ជ្រុងខាងជើងឆៀងខាងកើតនៃក្រុងអង្គរធំតាមរយៈប្រឡាយមួយ ដែលគេជីកនៅក្នុងកសិន្ធុទីក្រុងអង្គរធំតែម្តង (កសិន្ធុខាងជើង និងខាងជើងឆៀងខាងលិច ) មានបណ្តោយប្រវែង៤៥០០ម៉ែត្រ ភ្ជាប់ទៅបារាយណ៍តាមបណ្តោយផ្លូវចូលខ្លោងទ្វារតាកាវ ដែលជាខ្លោងទ្វារខាងលិចនៃទីក្រុងអង្គរធំ ។ ប្រឡាយទាំងនេះបានធ្វើឲ្យកសិន្ធុ និងផ្នែកខាងកើត នៃបារាយណ៍ខាងលិចគោកគ្មានទឹក ដែលធ្វើឲ្យគេគិតថា ការគោកនេះ គឺបណ្តាលមកពីដីកកនៅក្នុងបាតបារាយណ៍។ នៅឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរា បានរកឃើញប្រព័ន្ធបង្ហូរទឹកនៅក្នុងបារាយណ៍ខាងលិចពីសម័យដើម ដែលក្នុងនោះមានអាងព្រោះទឹកបុរាណមួយ និងអូរមួយលាតសន្ធឹងដល់ជ្រុងខាងជើងឆៀងខាងលិចនៃកសិន្ធុទីក្រុងអង្គរធំ។ នៅឆ្នាំ២០១១ អាជ្ញាធរជាតិអប្សរាបានបើកអូរសម័យបុរាណ បង្ហូរទឹកបារាយណ៍ខាងលិចដើម្បីស្រូបយកទឹកជំនន់ និងការពារភូមិអ្នកស្រុក។ នៅឆ្នាំ២០១២ អាជ្ញាធរជាតិអប្សរាបានស្តារប្រព័ន្ធបង្ហូរទឹកបំពេញបារាយណ៍នេះទាំងមូលឡើងវិញ ហើយសព្វថ្ងៃបារាយណ៍ខាងលិចអាចមានទឹកពេញផ្ទៃក្នុងកម្រិតអតិបរិមា និងបានដើរតួយ៉ាងពេញទំហឹងនៅក្នុងការគ្រប់គ្រងទឹកជំនន់ ។









## ការកសាងប្រព័ន្ធធារាសាស្ត្រ

ប្រព័ន្ធទឹកនៃប្រាសាទចៅស្រីវិបុលត្រូវបានស្តារឡើងវិញក្នុងឆ្នាំ២០១៥ និងបានសាងសង់សំណង់ចំនួន០៤កន្លែងសម្រាប់ធ្វើការគ្រប់គ្រងប្រព័ន្ធទឹកនេះ ដោយអាជ្ញាធរជាតិអប្សរា ដែលមានការជួយពីប្រទេសញូហ្ស៊ីឡែន តាមរយៈគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងបេតិកភណ្ឌអង្គរ (Angkor Community Heritage and Economic Advancement, ACHA ) ដែលជាគម្រោងមួយជួយផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍន៍សហគមន៍ ហើយក៏ជាគោលគំនិតរបស់ប្រជាពលរដ្ឋដែលបានស្នើសុំមកអាជ្ញាធរជាតិអប្សរា ដែលត្រូវការទឹកសម្រាប់ការរស់នៅប្រចាំថ្ងៃ សម្រាប់ស្រោចស្រព និងសត្វចិញ្ចឹមរបស់ពួកគាត់។

















ប្រព័ន្ធទឹកនេះបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជននៅក្នុងតំបន់នេះ ជាពិសេសប្រជាជននៅក្នុងភូមិចំនួន០៣គឺ ភូមិព្រាំកុដិ ភូមិបាល័ង្គ និងភូមិក្រពើ ឃុំបាល័ង្គ ស្រុកប្រាសាទបាគង ដូចជា៖

- សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃសម្រាប់សត្វចិញ្ចឹមរបស់ពួកគាត់និងសម្រាប់ស្រោចស្រពស្រែចំការជាពិសេសនៅរដូវប្រាំង ដែលអាចធានាបាននូវប្រាក់ចំណូលក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។
- ផ្តល់នូវទឹកផ្លែងសម្រាប់ធ្វើការទេសាចរណ៍ដូចបាភយណ៍ខាងលើ។
- ការផ្តួសផុលឡើងវិញនៃទេសភាពវប្បធម៌ ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាឲ្យកាន់តែច្រើន ដែលអាចឲ្យប្រជាពលរដ្ឋក្នុងតំបន់នេះទទួលបានប្រាក់ចំណូលក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ
- អាចការពារនៅពេលដែលមានទឹកជំនន់ គឺអាចស្រូបយកផ្នែកដែលលើសបណ្តោះអាសន្ន ដើម្បីកុំឲ្យមានការលិចក្រុង។




ក្រៅពីផលប្រជាយោជន៍ទាំងនេះ អាជ្ញាធរជាតិអប្សរាបានស្តារប្រព័ន្ធទឹកឡើងវិញដោយមានគោលគំនិតសំខាន់មួយទៀតគឺ ការបង្រៀនដល់សិស្ស និស្សិត និងអ្នកអភិរក្សជំនាន់ក្រោយៗ ឲ្យយល់ពីតួនាទីរបស់ទឹក និងការគ្រប់គ្រងទឹកជាមួយប្រាសាទ និងសហគមន៍។



## ការថែរក្សានិងស្តារឡើងវិញព្រៃឈើនៅរមណីយដ្ឋានអង្គរ

ព្រៃឈើជាធាតុមួយដែលមិនអាចខ្វះបាន និងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លៃ ជាសកលនៃរមណីយដ្ឋានអង្គរ ពោល គឺព្រៃឈើបានរួមគ្រាបាញ់បញ្ចូលគ្នាជាមួយប្រាង្គប្រាសាទ និងសហគមន៍មនុស្សក្លាយជាអត្តសញ្ញាណកំណត់សម្គាល់នៃរមណីយដ្ឋានអង្គរ។ តាមការអង្កេតរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៅឆ្នាំ២០០៦ ព្រៃឈើក្នុងរមណីយដ្ឋានអង្គរមានទំហំតែ២៥៨៥ហិកតាតែប៉ុណ្ណោះ ប៉ុន្តែដោយមានការយកចិត្តទុកដាក់ក្នុងការថែទាំ និងដាំដុះជាបន្តបន្ទាប់នៃនាយកដ្ឋាននេះ ផ្ទៃដីព្រៃឈើសរុបបានកើនឡើងរហូតដល់៦៥០៥ហិកតា នៅឆ្នាំ២០១៦ កើនឡើងចំនួន១៩២០ហិកតា។

ព្រៃឈើក្នុងតំបន់រមណីយដ្ឋានអង្គរ បែងចែកជាបីប្រភេទ គឺប្រភេទព្រៃស្រោង ព្រៃល្បោះ និងព្រៃគុម្ពោតបៃតង និងមានដើមឈើជាង ២០០ ប្រភេទ។ ព្រៃឈើទាំងនេះមានដុះរាយប៉ាយគ្រប់ទីកន្លែង បង្កើតបានជាទេសភាពបៃតងដ៏មានសោភ័ណភាពទាក់ទាញក្រៃលែង និងបានក្លាយជាចំណុចទាក់ទាញយ៉ាងខ្លាំងសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ លើសពីនេះទៀត ព្រៃឈើក៏បានបំពេញការកិច្ចផ្សេងៗទៀតក្នុងការថែរអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ ដោះគឺជារបាំងខ្យល់ជួយទប់ការសឹករេចរិលនៃថ្មតាមរយៈការរក្សាបាននូវសំណើម ឬកម្តៅថ្មឲ្យស្ថិតក្នុងសីតុណ្ហភាពមួយល្អប្រសើរជារបាំងនៃការទប់ការហូរច្រោះនៃទឹកភ្លៀង ជាប្រភពចំណូលរបស់អ្នកស្រុកអង្គរ និងជាជម្រកសត្វព្រៃច្រើនប្រភេទ។





ការបណ្តុះកូនឈើឡូង និងការដាំដើមឈើឡើងវិញ ក៏ជាការកិច្ចដ៏ចម្បងផ្សេងទៀតដែលអាជ្ញាធរជាតិអប្សរាបានកំពុងតែបំពេញហើយជារៀងរាល់ឆ្នាំមានកូនឈើជាងពម៉ឺនដើមត្រូវបានបណ្តុះនិងបានចែកចាយដល់គ្រប់តម្រូវការសម្រាប់ដាំឡើងវិញ ទាំងក្នុងនិងក្រៅរមណីយដ្ឋានអង្គរ។ ក្នុងមួយឆ្នាំៗ អាជ្ញាធរជាតិអប្សរាបានរៀបចំផែនការបណ្តុះកូនឈើមានចំនួន៧៦៥៧០ដើម នៅតាមស្ថានីយ៍បណ្តុះកូនឈើចំនួន៣គឺ៖



១. ស្ថានីយ៍បណ្តុះកូនឈើប្រាសាទតាកែវ មានបណ្តុះកូនឈើសំខាន់ៗដូចជា ដើមគគីរ ដើមឈើទាល ដើមត្រាយេង ដើមអង្គាញ់ ដើមគគោះ ដើមផ្ចឹក។



៣. ស្ថានីយ៍បណ្តុះកូនឈើ០៥ហិកតា មានប្រភេទឈើប្រណិតដូចជា ដើមក្រញូង ដើមនាងនួន ដើមបេង ដើមធ្នង់ ដើមក្រូស។



២. ស្ថានីយ៍បណ្តុះកូនឈើអង្គរធំ មានបណ្តុះកូនឈើហូបផ្លែដូចជា កូនដើមស្វាយចន្ទី ដើមសំរោង ដើមស្វាយ ដើមក្រឡុង និងកូនឈើលម្អដូចជា ដើមផ្កាប៉ោមឡូ ដើមត្របែកព្រៃ ដើមខ្នុរ ដើមរំដួល ដើម ផ្កាលំដួន ដើមកន្ទួតព្រៃ។

ក្នុងមួយឆ្នាំៗ អាជ្ញាធរជាតិអប្សរាបានដាំកូនឈើតាមផែនការសកម្មភាពប្រចាំៗ ជាក់ស្តែងសម្រាប់ឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរា និងអង្គការនានាបានដាំកូនឈើឡើងវិញចំនួន៥២៦៧៤ដើម។ ឆ្នាំ២០១៧ ចំនួន៦០៤៤៤ដើម។

សម្រាប់ឆមាសទី១ នៃឆ្នាំ២០១៨នេះ អាជ្ញាធរជាតិ - អប្សរា បានដាំកូនឈើចំនួន៦១១៤ដើម និងផ្តល់កូនឈើឲ្យអង្គភាពពាក់ព័ន្ធផ្សេងៗដាំសរុបចំនួន២៨៣៧២ដើម។







តាមការសិក្សាស្រាវជ្រាវ របស់អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាបានឲ្យដឹងថា កន្លងមកក្នុងតំបន់អង្គរ ធ្លាប់មានប្រភេទសត្វទោចជាច្រើនរស់នៅ ប៉ុន្តែប្រភេទសត្វទោច និងប្រភេទសត្វផ្សេងៗទៀតត្រូវបានបាត់បង់ផុតពូជដោយសារសង្គ្រាមស៊ីវិល ក្នុងទសវត្ស១៩៧០ រហូតដល់ទសវត្ស១៩៩០។ រមណីយដ្ឋានអង្គរ នៅឆ្នាំ២០១៣ អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Allianc e) និងក្រុមហ៊ុនខ្សែយោងអេកូទេសចរណ៍(Angkor ZipLine) នាំយកប្រភេទសត្វទោចម្កុដជាសត្វដកម្រមកពីតំបន់ផ្សេងៗគ្នា មកព្រលែងឲ្យរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ សត្វទោចម្កុដជាប្រភេទសត្វព្រៃចូលចិត្តរស់នៅដាច់ឆ្ងាយពីគេឯង ឬអាចនិយាយបានថា ចន្លោះព្រៃ២០ហិកតា រស់បានមួយគូ។

ព្រៃក្នុងតំបន់អង្គរភាគច្រើនជាព្រៃស្រោង ដែលមានកម្ពស់ចាប់ពី១៨ម៉ែត្រ ទៅ២០ម៉ែត្រ និងមានដើមរុក្ខជាតិរហូតដល់ ៥០ ប្រភេទអាចធ្វើជាអាហាររបស់សត្វប្រភេទនេះ រួមមាន ផ្លែសាម៉ាវ ផ្លែមផ្សិតព្រៃ ផ្លែគុយ ស្លឹកឈើ និងប្រភេទសត្វល្អិតផ្សេងៗជាច្រើនទៀត។

ចំណែកឯការបន្តពូជវិញ សត្វទោចម្កុដអាចចាប់ផ្តើមមានកូនពីអាយុ៥ឆ្នាំឡើង ហើយវាអាចនឹងមានកូនម្តងទៀតបន្ទាប់ពីកូនដំបូងមានអាយុចាប់ពី៣ឆ្នាំឡើង។

មកដល់បច្ចុប្បន្ន អាជ្ញាធរជាតិអប្សរា បានព្រលែងសត្វទោចម្កុដចំនួន៦ក្បាល(៣គូ) ឲ្យរស់នៅដោយសុខសាន្តក្នុងព្រៃរមណីយដ្ឋានអង្គរ ហើយសត្វទោចទាំងអស់នោះក៏បានបង្កើតកូនចំនួន៤ក្បាលបន្ថែមទៀត។




# គោលនយោបាយបរិស្ថានរបស់អាជ្ញាធរអប្សរា

## ទស្សនៈបរិស្ថាន

តំបន់អង្គរ-សៀមរាប គឺជាទីតាំងនៃក្រុមប្រាសាទសិលា-និមិត្តរូបនៃប្រទេសជាតិយើង និងជាបេតិកភណ្ឌវប្បធម៌ពិភពលោក ហើយក៏ជាតំបន់ដែលរក្សាទូវទំនៀមទម្លាប់ផ្ទាល់របស់អ្នកស្រុក ព្រមទាំងជាតំបន់ដែលគ្របដណ្តប់ដោយព្រៃព្រឹក្សា ស្មៅ បឹងបួ សម្បត្តិធម្មជាតិដ៏ប្រពៃ ។

យើងខ្ញុំ "អាជ្ញាធរជាតិគ្រប់គ្រងរមណីយដ្ឋានអង្គរ និងរៀបចំដែនដីតំបន់អង្គរ" ហៅថា "អាជ្ញាធរអប្សរា" ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ទទួលបន្ទុកគ្រប់គ្រងតំបន់អង្គរ ប្តេជ្ញាចិត្ត ជំរុញការស្ថាបនាសង្គមមួយ លើកស្ទួយការអភិវឌ្ឍន៍ស៊ីសង្វាក់គ្នារវាង "ធម្មជាតិ ប្រាសាទ និងអ្នកស្រុក" គោលគឺរវាង "បរិស្ថាន វប្បធម៌ និងសហគមន៍" ដើម្បីឈានទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាពសំរាប់ជំនាន់ក្រោយ តាមរយៈសកម្មភាពជួសជុលថែរក្សាប្រាសាទ និងសកម្មភាពអភិវឌ្ឍន៍តំបន់ ដោយសហការជិតស្និទ្ធជាមួយ ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរពាក់ព័ន្ធនានា និងជាមួយប្រជាជនក្នុងតំបន់ទាំងមូល ។

## គោលនយោបាយបរិស្ថាន

១.ជំរុញពិតនការថែរក្សាបរិស្ថានដោយផ្អែកទៅលើទស្សនៈខាងលើ

យើងខ្ញុំនឹងទិន្នន័យនូវផលប៉ះពាល់ទៅលើបរិស្ថាន តាមរយៈការអនុវត្តយ៉ាងសកម្មនូវវិធានការថែរក្សាបរិស្ថានតំបន់ឲ្យស្របទៅតាមកំណើនភ្ញៀវទេសចរ និងការរីកចំរើនក្នុងវិស័យទេសចរណ៍ ។

២.ចូលរួមធ្វើសកម្មភាពថែរក្សាបរិស្ថានទាំងអស់គ្នាផ្តោតទៅលើ

-ការរៀបចំទន្លាកអង្គរឲ្យបានស្អាតល្អ និងបង្កើនប្រព័ន្ធគ្រប់គ្រងសំរាមមួយដើម្បីកាត់បន្ថយសំរាម

-ការសម្អាត និងថែរក្សាទឹកស្ទឹង បឹងបួ បារាយណ៍ កសិណជាដើម នៅក្នុងតំបន់ឲ្យបានប្រសើរឡើងវិញ

-ការថែរក្សាការពារបរិយាកាសឲ្យបានល្អជាប្រចាំ

-ការថែរក្សាការពារព្រៃឈើ សម្បត្តិធម្មជាតិដែលមានតម្លៃនៅក្នុងតំបន់ឲ្យបានគង់វង្ស

៣.ធ្វើការអប់រំផ្សព្វផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់

យើងខ្ញុំនឹងធ្វើការអប់រំផ្សព្វផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់ ក៏ដូចជាចំពោះបុគ្គលិករបស់ខ្លួនដែលដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងនូវសារៈសំខាន់នៃការថែរក្សាបរិស្ថានក្នុងតំបន់ ។

៤.គោរពច្បាប់បញ្ញត្តិ និងកម្មវិធីការងារថែរក្សាទៀងទាត់បរិស្ថាន

យើងខ្ញុំនឹងគោរពច្បាប់បញ្ញត្តិ ព្រមទាំងកិច្ចការប្រឹក្សាទាំងឡាយពាក់ព័ន្ធនឹងបរិស្ថាន ហើយនិងជួយណែនាំប្រជាជនក្នុងតំបន់ឲ្យគោរពច្បាប់បញ្ញត្តិ និងវិធានទាំងនេះ ។

៥.ជំរុញឲ្យមានការកែលម្អឲ្យប្រសើរឡើងជាប្រចាំ

យើងខ្ញុំនឹងស្វែងយល់នូវផលប៉ះពាល់ទៅលើបរិស្ថានដែលកើតចេញពីសកម្មភាព និងចេញពីវិធានការការងាររបស់ខ្លួន រួចហើយយើងខ្ញុំនឹងរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានមួយ ដោយកំណត់យ៉ាងជាក់លាក់នូវគោលបំណង គោលដៅ និងផែនការការពារបរិស្ថាន ដោយពិនិត្យឡើងវិញជាប្រចាំដើម្បីធ្វើឲ្យមានភាពប្រសើរឡើងជាបន្តទៀត។

៦.គោលនយោបាយបរិស្ថាននេះនិងត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយទៅគ្រប់បុគ្គលិកអាជ្ញាធរអប្សរាទាំងអស់ និងផ្សព្វផ្សាយជាសាធារណៈ។

សៀមរាប ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥

**អគ្គនាយកអាជ្ញាធរអប្សរា**

**ស៊ុំ ម៉ាប់**



## ហេដ្ឋារចនាសម្ព័ន្ធទូទៅ

កិច្ចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ស្ពាន ផ្លូវថ្នល់ លូទឹក ប្រឡាយទឹក ស្ថិតនៅក្នុងចំណុចអាទិភាពយ៉ាងសំខាន់មួយ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**។ ស្របតាមទស្សនវិស័យនេះ អាជ្ញាធរជាតិអប្សរា តាមរយៈក្រុមការងារសហគមន៍ បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៅទីជនបទ ជាពិសេសតំបន់ដែលស្ថិតក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ។

ដាក់ស្តែងដោយពិនិត្យឃើញភាពចាំបាច់ និងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរាបានកសាងផ្លូវថ្នល់ ស្ពាន លូទឹក ប្រឡាយទឹកតូចធំជាច្រើនកន្លែង។ រាល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បានបង្កើតជាឱកាសដ៏ល្អប្រសើរ សម្រាប់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីទទួលផលប្រយោជន៍ពីការរីកចម្រើននៃវិស័យទេសចរណ៍ ហើយអាចធ្វើដំណើរ និងការប្រាស្រ័យទាក់ទងរវាងសហគមន៍ ប្រជាពលរដ្ឋកាន់តែល្អប្រសើរ ដែលកត្តាទាំងនេះបាននាំមកនូវលទ្ធភាពជាច្រើនជូនប្រជាពលរដ្ឋ ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់។ ប្រជាពលរដ្ឋអាចស្វែងរកឱកាសក្នុងការពង្រីកមុខរបរ និងជំនួញដោយសមរម្យព្រមទាំងអាចដឹកជញ្ជូនផលិតផលកសិកម្មធម្មជាតិ សិប្បកម្មរបស់ខ្លួនមកផ្គត់ផ្គង់ទីផ្សារ។

ស្ពានបេតុងនៅភូមិបង្កោង



ស្ពានបេតុងប្រវែង២៨ម៉ែត្រ ទទឹង៥ម៉ែត្រ កសាងឡើងក្នុងភូមិបង្កោង សង្កាត់អំពិល ក្រុងសៀមរាប ខេត្តសៀមរាប ដើមឡើយទីនេះមានស្ពានឈើចាស់ទ្រុឌទ្រោមខ្លាំងមួយ ដែលសូម្បីតែម៉ូតូក៏លំបាកក្នុងការឆ្លងកាត់ផង។ ការសាងសង់ស្ពានថ្មីនេះបានក្លាយជាប្រយោជន៍យ៉ាងសំខាន់ ដល់ការដឹកជញ្ជូនភោគផលដំណាំរបស់បងប្អូនប្រជាពលរដ្ឋពីភូមិបង្កោង ទៅកាន់ទីផ្សារកាន់តាមស្ថិតិល្អសបានកាន់តែងាយស្រួល។

ស្ពានបេតុងនៅភូមិត្រាច



ស្ពានបេតុងប្រវែង២៤ម៉ែត្រ ទទឹង៥ម៉ែត្រ ជាសំណើរសុំរបស់ប្រជាពលរដ្ឋក្នុងភូមិត្រាច ឃុំបាល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ស្ពាននេះសាងសង់ឡើងដើម្បីបញ្ចៀសការធ្វើដំណើរដោយរថយន្តធំៗ ដែលធ្វើដំណើរដោយឆ្លងតាមស្ពានថ្មបុរាណទៅផ្លូវជាតិលេខ៦៧ ដោយប្រើស្ពានថ្មីជំនួសវិញ ក្នុងការដឹក ជញ្ជូនកសិផលរបស់ប្រជាពលរដ្ឋ ហើយរក្សាអភិរក្សស្ពានបុរាណ ៗ

ស្ពានបេតុងនៅភូមិដូនទ្រ



ស្ពានបេតុង បណ្តោយ២០ម និងទទឹង ៣,៥ម ស្ថិតក្នុងភូមិដូនទ្រ ឃុំល្វា ស្រុកពួក សាងសង់នៅលើប្រឡាយអូរតាប្រាក់ ភ្ជាប់ពីស្រែសហគមន៍របស់ប្រជាពលរដ្ឋទៅផ្លូវលំភូមិដូនទ្រ ស្រុកពួក និងផ្លូវជាតិលេខ៦៧ ស្ពាននេះបម្រើផលប្រយោជន៍ អ្នកភូមិក្នុងឃុំល្វា ក្នុងការដឹកកសិផលស្រែចម្ការ ដូចជា ភូមិដូនទ្រ ភូមិគោកស្រម៉ ភូមិព្រះអង្គទ្រង់ជាដើម។

ស្ពានបេឡេនៅមណ្ឌលសុខភាពបង្កោង



ស្ពានដែកបេឡេសាងសង់ជូនប្រជាពលរដ្ឋភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ដើម្បីសម្រួលការធ្វើដំណើររបស់បងប្អូន ដែលត្រូវការមកមណ្ឌលសុភាពភូមិបង្កោង ជាពិសេសស្ត្រី ដែលពពោះត្រូវមកសម្រាលកូននៅមណ្ឌលសុខភាព។ អាជ្ញាធរជាតិអប្សរា បានការសម្រេចសាងសង់ស្ពានបេឡេជំនួសស្ពានឈើចាស់ ដែលទ្រុឌទ្រោមខ្លាំង ហើយស្ពានបង្កោងនេះបានភ្ជាប់ទំនាក់ទំនងរវាងភូមិតាកុយ និងភូមិបង្កោងក្នុងការប្រកបរបរផ្សេងៗ ផងដែរ។

ស្ពានបេតុងនៅភូមិពាម និងភូមិតាស្នេហ៍



ស្ពានបេតុងទទឹង៣,៥ម៉ែត្រ និងបណ្តោយ២៥ម៉ែត្រ ជាសំណូមពររបស់ប្រជាពលរដ្ឋភូមិពាម និងភូមិតាស្នេហ៍ ឃុំដូនកែវ ស្រុកពួក អាជ្ញាធរជាតិអប្សរាបានសាងសង់រួចរាល់ក្នុងឆ្នាំ២០១៥។ ពីមុនស្ពាននេះជាស្ពានឈើមានសភាពចាស់ទ្រុឌទ្រោម ហើយប្រជាពលរដ្ឋនៅភូមិទាំង២ខាងលើមានការលំបាក ក្នុងការធ្វើដំណើរឆ្លងកាត់។ ដោយមើលឃើញពីភាពលំបាកនេះ អាជ្ញាធរជាតិអប្សរាបានសម្រេចសាងសង់ជាស្ពានបេតុងជំនួសស្ពានឈើចាស់ ដើម្បីធានាការប្រើប្រាស់បានយូរអង្វែង ។




## វិថីសម្តេចវិបុលបញ្ញា **សុខ អាន**

វិថីសម្តេចវិបុលបញ្ញា **សុខ អាន** កន្លងមកពលរដ្ឋខ្លះនៅក្នុងក្រុងសៀមរាបនិយមហៅថា ផ្លូវ៦០ម៉ែត្រ ព្រោះយោងតាមទំហំផ្លូវដែលមានទទឹងប្រវែង៦០ម៉ែត្រ ។ ស្ថាបនាឡើងកាលពីឆ្នាំ២០០៤ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារបារាំង (ADF)។ នៅឆ្នាំ២០០៦ អាជ្ញាធរជាតិអប្សរាបានចំណាយថវិកាមួយចំនួន ដើម្បីធ្វើផ្លូវគ្រួសក្រហមសងខាងផ្លូវ និងបន្តសង់ផ្លូវមកខាងកើតហួសរង្វង់មូលចំនួន៤គីឡូម៉ែត្របន្ថែមទៀត។ ក្រោយមកនៅឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរាក៏បានស្ថាបនាកំណាត់ផ្លូវនេះបន្ថែមទៀត មានប្រវែង៩.៦៧៩ម៉ែត្រ សាងសង់ស្របផ្លូវជាតិលេខ៦ ពីលិចទៅកើតត្រង់ចំណុចបំបែកផ្លូវត្រាំនាគមកទល់នឹងផ្លូវទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

ផ្លូវនេះមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងបញ្ចៀសការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវជាតិលេខ៦ ជាពិសេសនោះ គឺបានជួយកាត់បន្ថយថិរៈវេលាក្នុងការធ្វើដំណើរពីទីក្រុងសៀមរាប មកស្រុកប្រាសាទបាគង និងស្រុកបន្ទាយស្រី។ ចាប់ពីផ្លូវបំបែកត្រាំនាគរហូតដល់បុរីរដ្ឋបាលខេត្តសៀមរាប បច្ចុប្បន្នជាទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ បើគិតមកដល់ពេលនេះវិថីសម្តេចវិបុលបញ្ញា **សុខ អាន** បានបម្រើផលប្រយោជន៍ដល់ប្រជាជន និងទេសចរទាំងឡាយ និងដឹកជញ្ជូនទំនិញអស់រយៈពេល១៦ឆ្នាំមកហើយ។












ផ្លូវក្រាលគ្រួសក្រហមប្រវែង១.៦០០ម៉ែត្រ ទទឹង៥ម៉ែត្រនៅឃុំលាងដៃ ស្រុកអង្គរធំ ត្រូវបានសាងសង់ឡើងចេញពីភូមិលាងដៃមកទល់នឹងផ្លូវវង់ធំត្រង់ចំណុចខាងកើតប្រាសាទព្រះខ័ន ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ និងគ្រួសារនៅក្នុង ភូមិលាងដៃ ភូមិដូនឪ ភូមិតាប្រុក ភូមិសំពង និងភូមិក្ងង។ ផ្លូវមួយខ្សែនេះក៏បានជួយសម្រួលដល់ការធ្វើដំណើរ ការដឹកជញ្ជូនភ្ញៀវទេសចរ និងផលិតផលកសិកម្មផ្សេងៗទៅកាន់ទីផ្សារ។




សាងសង់ផ្លូវលំដីសនៅលើខ្នងទំនប់អូរតាប្រាក់ប្រវែង៣គីឡូម៉ែត្រ ដើម្បីជួយសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋសហគមន៍នៅតាមប្រឡាយនេះមានឃុំដូនកែវ និងឃុំពួក ស្រុកពួក។ ផ្លូវនេះក៏សម្រាប់ប្រើជាទំនប់ការពារស្រុកពួកពីទឹកជំនន់ផងដែរ។





ផ្លូវពីភូមិបង្កោងទៅផ្លូវជាតិលេខ៦ជាផ្លូវក្រាលគ្រួសក្រហមប្រវែង៣គីឡូម៉ែត្រ ចាប់ពីចំណុចក្បាលស្ពានលេខ៧ក្នុងភូមិបង្កោង សង្កាត់អំពិលក្រុងសៀមរាប ដល់ផ្លូវជាតិលេខ៦ត្រង់ភូមិតាកុយ ឃុំបាល្ល័ង្ក ស្រុកប្រាសាទបាគង។ ផ្លូវនេះដើមឡើយជាផ្លូវដីសដែលពិបាកក្នុងការធ្វើដំណើរខ្លាំង ព្រោះមានដីផុសនៅរដូវប្រាំង និងរអិលខ្លាំងក្នុងរដូវវស្សា ។

ផ្លូវបេតុងមួយខ្សែប្រវែង៩៣០ម៉ែត្រត្រង់ផ្សារគោកស្នួល ភ្ជាប់ពីផ្លូវជាតិលេខ៦ ចូលទៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក ត្រូវបានអាជ្ញាធរជាតិអប្សរាសាងសង់ជូនប្រជាពលរដ្ឋ ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនកសិផលផ្សេងៗ ។ ផ្លូវមួយខ្សែនេះ ជាសំណូមពររបស់ប្រជាពលរដ្ឋភូមិប្រឡាយ ឃុំខ្នាត ដែលបានស្នើសុំមកអាជ្ញាធរជាតិអប្សរាឲ្យជួយជួសជុលផ្លូវក្រាលគ្រួសក្រហម ប៉ុន្តែដោយមើលឃើញថាដើម្បីធានាការធ្វើដំណើរ និងប្រើប្រាស់បានយូរអង្វែងនោះទើបអាជ្ញាធរជាតិអប្សរាបានឯកភាពជាមួយអាជ្ញាធរមូលដ្ឋាន សាងសង់ជាផ្លូវបេតុងជូនតែម្តង ។




សាងសង់ផ្លូវដីសប្រវែង៤.០០០ម៉ែត្រ អមសងខាងស្ទឹងព្រះស្រុក ស្ថិតក្នុងភូមិស្ទឹងព្រះស្រុក ឃុំល្វា ស្រុកពួក។



ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ជាជំនួយឥតសំណងរបស់សាធារណរដ្ឋកូរ៉េ តាមរយៈ KOICA បានកែប្រែកំណាត់ផ្លូវនេះ ជាផ្លូវក្រាលកៅស៊ូ គឺងាយស្រួលដល់ប្រជាជនធ្វើដំណើរឆ្លងកាត់បានយ៉ាងល្អប្រសើរ។



ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ
- សាងសង់: ២០០៩-២០១២
- ប្រវែង: ៣៤,៥គីឡូម៉ែត្រ
- ចំណុចឆ្លងកាត់: សង្កាត់សៀមរាប សង្កាត់គោកចក ស្រុកឧត្តរគ្រៅ ស្រុកអង្គរធំ ស្រុកបន្ទាយស្រី
- សារៈប្រយោជន៍: បញ្ចៀសថយន្តធំៗពីរមណីយដ្ឋានអង្គរ និង ដឹកជញ្ជូនកសិផល។









## ការជួសជុលកំណាត់ផ្លូវវង់ធំ



អាជ្ញាធរជាតិអប្សរា បានជួសជុលកំណាត់ផ្លូវវង់ធំ ដើម្បីសម្រួលចរាចរណ៍ឲ្យប្រសើរជាងមុន កំណាត់ផ្លូវក្រាលកៅស៊ូនៅវង់ធំក្នុងតំបន់ឧទ្យានអង្គរ ដែលមានប្រវែងជាង២០គីឡូម៉ែត្រ ជាផ្នែកមួយដ៏សំខាន់សម្រាប់ការធ្វើដំណើររបស់អ្នកស្រុកផង និងបម្រើឲ្យវិស័យទេសចរណ៍ផង។



គម្រោងជួសជុលផ្លូវវង់ធំនេះ បានសិក្សាបច្ចេកទេសចាប់តាំងពីឆ្នាំ២០១៦ ហើយកន្លងមកក្រុមអ្នកជំនាញការលើផ្នែកអភិរក្សបុរាណវិទ្យា នៃគណៈកម្មការអាយស៊ីស៊ី-អង្គរ បានចុះពិនិត្យនិងផ្តល់យោបល់នៅនឹងកន្លែង ព្រមទាំងផ្តល់ការគាំទ្រអនុម័តឲ្យធ្វើការជួសជុលក្នុងកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ កាលពីខែធ្នូ ឆ្នាំ២០១៧ ការជួសជុលកែលម្អផ្លូវវង់ធំវិញ បានប្រវែង២០៦០ម៉ែត្រ និងសម្រាប់ឆ្នាំ២០១៨ អាចជួសជុលបន្ថែមបានប្រវែង៥០០០ម៉ែត្រទៀត។បច្ចុប្បន្នកំណាត់ផ្លូវក្រាលកៅស៊ូចាប់ពីក្លោងទ្វារជើងនាំង រហូតដល់ទ្វារទឹកប្រាសាទព្រះខ័ន កំពុងជួសជុលកែលម្អឡើងវិញទាំងស្រុងតាមបច្ចេកទេសដោយអាជ្ញាធរជាតិអប្សរា ។





## ភូមិធម្មជាតិរុនតាឯក ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព

ភូមិធម្មជាតិរុនតាឯកបានបង្កើតឡើងក្នុងគោលបំណងទទួលយកគ្រួសារថ្មីរបស់កូនចៅអ្នកស្រុកអង្គរដែលស្ម័គ្រចិត្តទៅរស់នៅទីនោះ បន្ទាប់ពីបានបំបែកផ្ទះពីឪពុកម្តាយក្រោយពេលរៀបការរួចៗ ភូមិធម្មជាតិរុនតាឯកនេះត្រូវបានអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ទាំងស្រុង ដែលមានទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្ទះ សាលារៀន សាឡុំ មជ្ឈមណ្ឌលបណ្ដុះបណ្ដាល ប៉ុស្តិ៍សុខភាព និងផ្សារក្នុងភូមិជាដើមៗ

ផ្ទៃដីសរុបនៃភូមិធម្មជាតិនេះមានចំនួន១.០១២ហិកតា ក្នុងនោះមានប្រឡាយ ផ្លូវជុំវិញ និងផ្លូវខាងក្នុង ប្រមាណ ១៦០ហិកតា ចំណែកដីសម្រាប់សាងសង់លំនៅដ្ឋាន និងកសិកម្មមានប្រមាណ៨៥២ហិចតា ដែលអាចទទួលប្រជាពលរដ្ឋ៨៥០គ្រួសាររស់នៅទីនេះ។ បច្ចុប្បន្នភូមិធម្ម-ជាតិរុនតាឯកទទួលបានប្រជាពលរដ្ឋមករស់នៅ១០៣គ្រួសារ។

ដើម្បីលើកស្ទួយជីវភាពរបស់បងប្អូន អាជ្ញាធរជាតិអប្សរាបានផ្តល់ការងារ ថែមទាំង បណ្តុះបណ្តាលជំនាញកសិកម្ម និងសិប្បកម្មដល់ពួកគាត់ បូកបញ្ចូលទាំងការបង្កើតមុខរបរជូនពួកគាត់ទៀតផង។



### អគារសិក្សា អាក អូហ្សាក់ ជាណាធំ



សាលារៀនមួយខ្នងមាន០៥បន្ទប់ ត្រូវបានសាងសង់បន្ថែមក្រោមជំនួយពីសប្បុរសជប៉ុន ដើម្បីជាថ្នាលបណ្តុះចំណេះដឹងកូនចៅប្រជាពលរដ្ឋក្នុងភូមិ និងភូមិជិតខាងដែលក្នុងនោះបានដាក់ឲ្យមានថ្នាក់ចំណេះដឹងទូទៅ ថ្នាក់ភាសាអង់គ្លេស និងថ្នាក់អក្ខរកម្ម។

### សហគ្រាសម្រុំ ក្នុងភូមិធម្មជាតិរុនតាឯក



សហគ្រាសម្រុំ SPLE បាននិងកំពុងដើរតួសំខាន់ ក្នុងការរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋ ភូមិ-ធម្មជាតិ តាមរយៈការផ្តល់បច្ចេកទេសដាំម្រុំ និងទទួលទិញទាំងស្រុង ផ្តល់ទុនកម្ចីគ្មានការប្រាក់រយៈពេលវែងដល់ប្រជាកសិករដាំម្រុំ និងដាំតាមបែបបច្ចេកទេសសរីរាង្គដែលត្រូវបានទទួលស្គាល់ស្តង់ដារជប៉ុន។ សហគ្រាសក៏ពង្រីកបន្ថែមនូវកសិកផលផ្សេងទៀត ដែលជាតម្រូវការទីផ្សារ។ សហគ្រាសម្រុំ SPLE ក៏បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន IMWSO ពីប្រទេសជប៉ុន ដើម្បីនាំចេញផ្កាចំមុខម្សៅម្រុំសរីរាង្គពីភូមិធម្មជាតិរុនតាឯកចូលទៅកាន់ប្រទេសជប៉ុន។

### សំណង់សាសនា ឧបោសថាគារ (សាឡុំ)



ដើម្បីថែរក្សាទំនៀមទម្លាប់ប្រពៃណីរបស់អ្នកស្រុកអង្គរដែលបានស្ម័គ្រចិត្តទៅរស់នៅភូមិធម្មជាតិរុនតាឯក អាជ្ញាធរជាតិអប្សរាបានគិតគូរកសាងទីកន្លែងសម្រាប់គោរពបូជាព្រះពុទ្ធសាសនា និងធ្វើកិច្ចពិធីផ្សេងៗដែលហៅថា សាឡុំមានទំហំប្រមាណ៨ម៉ែត្រ×១២ម៉ែត្រ ធ្វើពីថ្មប្រក់ដំបូលក្បឿងតាមរចនាប័ទ្មខ្មែរ ត្រូវបានកសាងឡើងនៅក្បែរមាត់បឹងជាណា។



ដំណាំម្រុំលេម (Rozela) ក្នុងភូមិធម្មជាតិរុនតាឯក



ផែនទីអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក

## អ្នកបន្តវេននៅអង្គរ




នៅពេលដែលបានដាក់អង្គរចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកភ្លាមៗអ្វីដែលត្រូវធ្វើជាចម្បងនៅពេលនោះគឺ ការស្រោចស្រង់អង្គរឲ្យផុតពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការអំពើលួចជួញដូរវត្ថុបុរាណ និងការដួលរលំដោយធម្មជាតិជាដើម។ មកទល់នឹងបច្ចុប្បន្នស្ថានភាពអង្គរបានធូរស្បើយច្រើនដោយសារប្រាសាទជាច្រើនបានទទួលការអភិរក្សជួសជុល ហេដ្ឋារចនាសម្ព័ន្ធរបស់វាក៏ត្រូវបានកែលម្អជាបន្តបន្ទាប់ ដើម្បីបម្រើដល់ការអភិវឌ្ឍដោយចីរភាព។

ក៏ប៉ុន្តែ បើយើងក្រលេកមើលសកម្មភាពជាក់ស្តែងនៅការដ្ឋានវិញ កាលពីទើបចាប់ផ្តើម ទាំងការជួសជុលអភិរក្ស និងកិច្ចការស្រាវជ្រាវផ្សេងៗភាគច្រើនគឺដឹកនាំអនុវត្តគម្រោងដោយស្ថាប័នបរទេស ដោយហេតុថាធនធានមនុស្សរបស់យើងនៅមានកម្រិតទាប នៅឡើយទាំងបច្ចេកទេស និងធនធានថវិកា។

ដើម្បីឲ្យការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ អាចដំណើរការទៅល្អ និងទទួលបានផលជាយូរអង្វែងនោះ អាជ្ញាធរជាតិអប្សរាក្នុងឋានៈជាស្ថាប័នទទួលខុសត្រូវលើកិច្ចការនេះ បានគិតគូរដល់អ្នកបន្តវេនជារឿងចាំបាច់។ អ្នកបន្តវេនថែរក្សាមរតកខ្មែរ គឺត្រូវតែធ្វើឡើងដោយកូនខ្មែរទើបមាននិរន្តរភាពទៅបាន។

កត្តានេះហើយ ដែលថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា បានចាត់ទុកការបណ្តុះបណ្តាលធនធានមនុស្សជាបញ្ហាអាទិភាពមួយ ក្នុងចំណោមការងារអាទិភាពផ្សេងៗទៀត។ យោងលើគំនិតនេះ អាជ្ញាធរជាតិអប្សរាតែងតែកំណត់ឲ្យភាគីបរទេស ដែលអនុវត្តគម្រោងនានានៅក្នុងតំបន់អង្គរ ត្រូវតែបញ្ចូលមន្ត្រីខ្មែរដើម្បីធ្វើការជាមួយ ដើម្បីរៀនសូត្រ និងអនុវត្តជាក់ស្តែងជាមួយអ្នកជំនាញការបរទេស។

ក្រៅពីអនុវត្តជាក់ស្តែងនៅតាមការដ្ឋាន អាជ្ញាធរជាតិអប្សរាក៏បានសហការជាមួយស្ថាប័នបរទេសមួយចំនួន ដើម្បីផ្តល់ការបណ្តុះបណ្តាលមន្ត្រីជំនាញខ្មែរឲ្យទទួលបានការសិក្សានៅក្រៅប្រទេស ចាប់យកជំនាញសំខាន់ៗដែលពាក់ព័ន្ធការងារអភិរក្សជួសជុល និងអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ។

តាមរយៈគម្រោងនេះ មន្ត្រីជំនាញមួយចំនួនបានបញ្ចប់ថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងជំនាញផ្សេងៗជាច្រើន។ ចំណែកមន្ត្រីជំនាញជាច្រើនទៀត ដែលមិនបានទៅបន្តការសិក្សានៅក្រៅប្រទេសក៏ទទួលបានការបណ្តុះបណ្តាលដោយសាស្ត្រាចារ្យល្បីៗលើពិភពលោកជាច្រើន ដោយការបណ្តុះបណ្តាលវគ្គខ្លីៗ ទៅតាមភាពចាំបាច់នៃការងារ បូករួមនឹងការចុះអនុវត្តជាក់ស្តែងនៅតាមការដ្ឋានផងដែរ។

ដោយការងារគ្រប់គ្រងអង្គរ ជាការងារចម្រុះទាមទារមន្ត្រីជំនាញ និងបុគ្គលិកបច្ចេកទេសមានសមត្ថភាពច្បាស់លាស់ ទើបនៅឆ្នាំ២០១៥ អាជ្ញាធរជាតិអប្សរាបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរឡើង។ មជ្ឈមណ្ឌលនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពាក់បំប៉នសមត្ថភាពរបស់មន្ត្រី និងបុគ្គលិកជំនាញគ្រប់ប្រភេទទាំងកម្រិតជាតិ និងអន្តរជាតិ។ ឆ្លងកាត់បទពិសោធន៍ការងារជាក់ស្តែងនៅតាមការដ្ឋាន និងការបណ្តុះបណ្តាលជាបន្តបន្ទាប់រយៈពេលជាង២០ឆ្នាំមកនេះ មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាចាប់ផ្តើមមានសមត្ថភាពគ្រប់គ្រាន់ អាចកាន់ការអនុវត្តគម្រោងអភិរក្សជួសជុល និងគម្រោងអភិវឌ្ឍន៍នានាបានដោយខ្លួនឯង។ មិនត្រឹមតែប៉ុណ្ណោះ មន្ត្រីជំនាញខ្មែរថែមទាំងអាចចែករំលែកបទពិសោធន៍ការងារគ្រប់គ្រងបេតិកភណ្ឌពិភពលោក ទៅកាន់ប្រទេសផ្សេងៗលើឆាកអន្តរជាតិទៀតផង។

ក្រៅពីបណ្តុះបណ្តាលមន្ត្រី បុគ្គលិកជំនាញ អាជ្ញាធរជាតិអប្សរាក៏បានបណ្តុះបណ្តាល អប់រំដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ ដែលកំពុងរស់នៅក្នុងតំបន់អង្គររួមនឹងសិស្សានុសិស្សនៅតាមសាលា ដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីបណ្តុះចិត្តគំនិតឲ្យពួកគេស្គាល់ ស្រឡាញ់ និងចូលរួមថែរក្សាទាំងអស់គ្នា។






## មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ

ការសម្រេចបង្កើតឡើងនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនេះ គឺឆ្លើយតបទៅនឹងអនុសាសន៍លើកឡើងរបស់កិច្ចប្រជុំលើកទី២៣ នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដើម្បីអភិវឌ្ឍន៍ ធនធានមនុស្សសម្រាប់ថែរក្សាការពារ និងអភិរក្សនូវសម្បត្តិបេតិកភណ្ឌវប្បធម៌។ វត្ថុបំណងសំខាន់នៃការបង្កើតឡើងនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនេះ គឺដើម្បីធ្វើកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីពង្រឹងការងារ បណ្តុះបណ្តាលអំពីជំនាញបច្ចេកទេស-បេតិកភណ្ឌ ដល់បុគ្គលិកជំនាញរបស់អាជ្ញាធរជាតិ-អប្សរារួមទាំងអ្នកពាក់ព័ន្ធទាំងឡាយឲ្យគេទទួលបាននូវចំណេះដឹង វិធីសាស្ត្រ និងបច្ចេកទេសក្នុងការការពារថែទាំ និងអភិរក្សសម្បត្តិបេតិកភណ្ឌឲ្យបានត្រឹមត្រូវល្អ ក្នុងភាពច្បាស់លាស់ និងមានការទទួលខុសត្រូវខ្ពស់ ដើម្បីអាចទប់ស្កាត់បាននូវការបំផ្លិចបំផ្លាញទាំងឡាយ ទាំងកត្តាមនុស្សក៏ដូចជា កត្តាធម្មជាតិមកលើសម្បត្តិវប្បធម៌ជាតិយើង។ កិច្ចការនេះមានភាពចាំបាច់ណាស់ដែលទាមទារឲ្យអាជ្ញាធរជាតិអប្សរាខិតខំជាប្រចាំ លើការងារពង្រឹងសមត្ថភាពឲ្យដល់មន្ត្រី និងបុគ្គលិករបស់ខ្លួន ដើម្បីអាចបំពេញការកិច្ចក្នុងការការពារថែរក្សា និងអភិរក្សទ្រព្យសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ ឲ្យបានគង់វង្សល្អប្រកបដោយប្រសិទ្ធភាព។







© LIM-BUNHONG


Introduction to Conservation Science –
stone, deterioration, conservation,
case studies
© LIM-BUNHONG


© LIM-BUNHONG


© LIM-BUNHONG


© LIM-BUNHONG








© LIM-BUNHONG



កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗរូប